

# សិស្ស ដ៏ពិតរបស់ ព្រះយេស៊ូវ

## true discipleship

លោកគ្រូ វិលាម មេកដានុល

**William MacDonald**

# សិស្ស ដ៏ពិតរបស់ព្រះយេស៊ូវ

## true discipleship

លោកគ្រូ វិលាម មេកដានុល
**William MacDonald**

បោះពុម្ពលើកទី១ ឆ្នាំ១៩៦២
បោះពុម្ពជាភាសាខ្មែររក្សាសិទ្ធិ ២០១៤
លោកគ្រូ វិលាម មេកដានុល
រក្សាសិទ្ធិគ្រប់បែបយ៉ាង
First printing 1962
This edition in Khmer copyright 2014
William MacDonald
All rights reserved

អ្នកនិពន្ធសៀវភៅ សិស្សដ៏ពិតរបស់ព្រះយេស៊ូវ មិនអាចផ្តល់នូវម្ចាស់ដើមនៃសម្រង់សម្តីមួយចំនួននៅក្នុងសៀវភៅនេះបានទៀតទេ។ ប្រសិនបើ គាត់អាចរកឃើញនូវម្ចាស់ដើមនៃសម្រង់សម្តីទាំងនោះ យើងនឹងបញ្ចូលទៅក្នុងការបោះពុម្ពលើកក្រោយៗទៀត។ សម្រាប់សម្រង់សម្តីតែមួយឃ្លាៗ គាត់បានដាក់តែឈ្មោះអ្នកនិពន្ធតែប៉ុណ្ណោះ។

ផលិតដោយ៖ សកម្មភាពកម្ពុជា resources@actioncambodia.org
ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

បកប្រែដោយ៖ លោក ផេង វណ្ណៈ, លោកអនុបណ្ឌិត ផេង ភារៈ និងលោក វើល ណាថាន

អ្នកបកប្រែកំណាព្យ៖ លោក ហេង ពិសិដ្ឋ

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ជួប ប៊ុនហាក់, លោក ឈាង បូរ៉ា និងលោក វើល ណាថាន

សូមថ្លែងអំណរគុណចំពោះ៖ លោកស្រី សំ ថាវី, លោកស្រី អ៊ែរិនសិន វន្នី, លោកស្រី កង សុគន្ធវ័ត្ត, កញ្ញា សុគន្ធ ចិន្តាមណី និងលោក ផុន ស្រីអែម

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួលឆ្នាំ២០១៤ (គកស), ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន (គខប), ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ (គគខ), ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

For ordering information please visit:
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖
http://www.cambodianchristianresources.com/truediscipleship/

បោះពុម្ពលើកទី១ ចំនួន១.០០០ក្បាល គ.ស២០១៤ នៅព្រះរាជាណាចក្រកម្ពុជា

# មាតិកា


បុព្វកថា ....................................................................................៥

សេចក្ដីផ្ដើម...................................................................................៧

លក្ខខណ្ឌនៃភាពជាសិស្ស .................................................... ១១

ការលះអាល័យអ្វីៗទាំងអស់ចោល ......................................២៥

ឧបសគ្គនៃភាពជាសិស្ស........................................................៤៣

សិស្សគឺជាអ្នកមើលខុសត្រូវ................................................. ៥៥

ភាពឧស្សាហ៍ .......................................................................... ៦៧

ជំនឿ ............................................................................................ ៨១

ការអធិស្ឋាន ............................................................................ ៩៥

សឹកសង្គ្រាម ......................................................................... ១១១

អំណាចគ្រប់គ្រងផែនដី.......................................................១២៣

គ្រីស្ទបរិស័ទ និងអាពាហ៍ពិពាហ៍.................................... ១៤១

ការលៃលកមើលជាមុន....................................................... ១៥១

ស្រមោលនៃការស្លាប់ដោយសារជំនឿ ................................ ១៦១

រង្វាន់របស់គ្រីស្ទបរិស័ទ..................................................... ១៦៩

កំណត់យោង .........................................................................១៧៤

# បុព្វកថា

សៀវភៅនេះកើតចេញមកពីការខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ ដើម្បីស្រង់យកនូវគោលការណ៍សំខាន់ៗនៃភាពជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទតាមកណ្ឌគម្ពីរសញ្ញាថ្មី។ ប្រហែលជាមានអ្នកខ្លះបានឃើញពីគោលការណ៍ទាំងនេះនៅក្នុងព្រះបន្ទូលជាយូរឆ្នាំមកហើយ ប៉ុន្តែទោះជាយ៉ាងនេះក្តីយើងខ្ញុំសន្និដ្ឋានថា គោលការណ៍ទាំងនេះហាក់ដូចជាខ្លាំងក្លា ហើយពិបាកអនុវត្តនៅយុគសម័យដ៏ស្មុគស្មាញដែលយើងខ្ញុំកំពុងរស់នៅសព្វថ្ងៃនេះ។ ហេតុដូច្នេះហើយបានជាយើងខ្ញុំមិនរវីរវល់នឹងព្រះបន្ទូលរបស់ទ្រង់។

ក្រោយមក យើងខ្ញុំក៏បានជួបយុវជនជាអ្នកជឿមួយក្រុមដែលបានប្តេជ្ញាចិត្តរស់នៅ  តាមលក្ខខណ្ឌនៃភាពជាសិស្សរបស់ព្រះសង្គ្រោះ ដោយសារពួកគេជឿថា លក្ខខណ្ឌទាំងនោះមិនគ្រាន់តែមានប្រយោជន៍យ៉ាងក្រៃលែងដល់យើងប៉ុណ្ណោះនោះទេ ប៉ុន្តែវាថែមទាំងជាផ្លូវតែមួយគត់ដែលយើងអាចផ្សាយដំណឹងល្អដល់មនុស្សលោកទាំងអស់បាន។

យើងខ្ញុំទទួលស្គាល់ថា យើងខ្ញុំអាចនិពន្ធសៀវភៅនេះបាន ដោយសារតែមានយុវជនទាំងនោះជាជំនួយ តាមរយៈគំរូដ៏រស់រវើករបស់ពួកគេទាក់ទងនឹងសេចក្ដីពិតដែលមានបញ្ជាក់នៅក្នុងសៀវភៅនេះ។

ទោះបើសេចក្ដីពិតទាំងនេះខ្ពស់ហួសពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់យើងខ្ញុំក៏ដោយ ក៏យើងខ្ញុំនៅតែចង់បង្រៀនសេចក្ដីពិតទាំងនេះ ទុកដូចជាអ្វីដែលយើងខ្ញុំចង់ប្រព្រឹត្តតាមដែរ។

— លោក វិលាម មេកដានុល

(William MacDonald)

# សេចក្តីផ្តើម

ផ្លូវដែលមនុស្សអាចឈានទៅដល់ភាពជាគ្រីស្ទបរិស័ទដ៏ពិតបាន ចាប់ផ្តើមនៅពេលដែលមនុស្សម្នាក់នោះកើតជាថ្មី។ ផ្លូវនោះអាចចាប់ផ្តើមបាន នៅពេលដែលបុគ្គលម្នាក់បានព្រឹត្តិការណ៍ដូចខាងក្រោម៖

- នៅពេលដែលគាត់ទទួលស្គាល់ថា ខ្លួនមានបាប បានវង្វេងបាត់ ខ្វាក់ងងឹតសូន្យសុង ហើយនៅអាក្រាតចំពោះព្រះជាម្ចាស់។
- នៅពេលដែលគាត់បានទទួលស្គាល់ថា គាត់មិនអាចសង្គ្រោះខ្លួនឯងដោយសារចរិតល្អ ឬអំពើល្អរបស់គាត់បានឡើយ។
- នៅពេលដែលគាត់ជឿថា ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានសុគតជំនួសគាត់នៅលើឈើឆ្កាង។
- នៅពេល ដែលគាត់បានសម្រេចចិត្តយ៉ាងច្បាស់លាស់ដោយជឿថា ព្រះយេស៊ូវគ្រីស្ទពិតជាព្រះអម្ចាស់ ហើយជាព្រះសង្គ្រោះតែមួយអង្គគត់របស់គាត់។

ព្រឹត្តិការណ៍ទាំងប៉ុន្មានមុននេះ គឺជារបៀបដែលមនុស្សម្នាក់អាចក្លាយទៅជាគ្រីស្ទបរិស័ទ។ ការបញ្ជាក់សេចក្តីទាំងនេះជាមុន គឺជាការសំខាន់ណាស់ ពីព្រោះមនុស្សជាច្រើនគិតថា ការក្លាយជាគ្រីស្ទបរិស័ទ គឺគ្រាន់តែអាស្រ័យទៅលើការរស់នៅបែបជាគ្រីស្ទបរិ-ស័ទប៉ុណ្ណោះ។ ប៉ុន្តែតាមពិតមិនដូច្នោះទេ! ជាដំបូង លោកអ្នកត្រូវតែក្លាយទៅជាគ្រីស្ទបរិស័ទជាមុនសិន មុននឹងលោកអ្នកអាចរស់នៅបែបជាគ្រីស្ទបរិស័ទបាន។

ជីវិតនៃភាពជាសិស្សដែលបានរៀបរាប់ជូនក្នុងទំព័របន្តបន្ទាប់ គឺជាជីវិតអធិធម្មជាតិមួយ។ យើងគ្មានអំណាចអាចរស់នៅបែបនោះដោយខ្លួនយើងផ្ទាល់បានទេ។ យើងត្រូវការអំណាចដែលមកពីព្រះជាម្ចាស់។ មានតែនៅពេលដែលយើងបានកើតជាថ្មីតែប៉ុណ្ណោះ ទើបអាចឲ្យយើងទទួលអំណាច ហើយរស់នៅស្របតាមសេចក្តីបង្រៀនរបស់ព្រះយេស៊ូវបាន។

មុននឹងលោកអ្នកអានបន្តទៅមុខទៀត សូមសួរខ្លួនឯងជាមុនសិនថា៖ «តើខ្ញុំបានកើតជាថ្មីហើយឬនៅ? តើខ្ញុំបានក្លាយជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ដោយសារជំនឿនៅក្នុងព្រះអម្ចាស់យេស៊ូវហើយឬនៅ?»

ប្រសិនបើលោកអ្នកមិនទាន់ទេ ចូរទទួលទ្រង់ធ្វើជាព្រះអម្ចាស់

និងជាព្រះអង្គសង្គ្រោះរបស់លោកអ្នកឥឡូវនេះចុះ។ បន្ទាប់មក ប្តេជ្ញាចិត្តនឹងស្តាប់បង្គាប់ទ្រង់នូវគ្រប់ការទាំងអស់ដែលទ្រង់បានបង្គាប់បញ្ជាមក ទោះបីជាការនោះទាមទារឲ្យលោកអ្នកលះបង់យ៉ាងណាក៏ដោយ។

## ជំពូកទី១

# លក្ខណៈនៃ ភាពជាសិស្ស

ភាពជាគ្រីស្ទបរិស័ទដ៏ពិត គឺជាការប្តូរផ្តាច់ចំពោះព្រះអម្ចាស់យេស៊ូវគ្រីស្ទយ៉ាងអស់ពីកាយពីចិត្ត។

ព្រះសង្គ្រោះមិនមែនរកអស់បុរសស្ត្រីទាំងឡាយណាដែលនឹងថ្វាយពេលទំនេរនាពេលល្ងាចរបស់ពួកគេ ឬក៏ថ្ងៃចុងសប្តាហ៍របស់ពួកគេ ឬក៏អំឡុងឆ្នាំនៃការចូលនិវត្តន៍របស់ពួកគេនោះទេ តែទ្រង់ស្វែងរកអស់អ្នកទាំងឡាយណាដែលនឹងយកទ្រង់ជាអាទិភាពចម្បងនៅក្នុងជីវិតរបស់ពួកគេវិញ។

សព្វថ្ងៃនេះទ្រង់នៅតែបន្តស្វែងរកដូចជាកាលដែលទ្រង់ធ្លាប់បានស្វែងរកជាយូរមកហើយនោះដែរ ទ្រង់មិនមែនរកហ្វូងមនុស្ស ដែលអណ្តែតត្រ-សែតឥតគោលដៅនៅក្នុងការដើរតាមគន្លងរបស់ទ្រង់នោះទេ ប៉ុន្តែទ្រង់រកអស់បុគ្គលទាំងឡាយណា ដែលមានភក្តីភាពជាអមតៈចំពោះទ្រង់ ហើយ

ភក្ដីភាពនោះកើតមានឡើងនៅពេលដែលបុគ្គលទាំងនោះទទួលស្គាល់ថា ទ្រង់សព្វព្រះហឫទ័យចំពោះអ្នកទាំងឡាយណាដែលបានត្រៀមខ្លួនដើម្បីដើរតាមគន្លងនៃការលះកាត់ចិត្តខ្លួនឯង។ គន្លងនោះទ្រង់បានដើរមុនពួកគេរួចជាស្រេចហើយ។

— លោក អេឆ. អេ. អ៊ែវិន ហប់គិនស៍
(H. A. Evan Hopkins)[១]

ការឆ្លើយតបដ៏ត្រឹមត្រូវទៅនឹងយញ្ញបូជារបស់ព្រះគ្រីស្ទនៅលើភ្នំលលាដ៍ក្បាលមានតែមួយគត់គឺ យើងត្រូវចុះចូលចំពោះព្រះគ្រីស្ទទាំងស្រុងដោយឥតលក្ខខណ្ឌ។ ការថ្វាយព្រលឹង ជីវិត និងគ្រប់ទាំងអស់របស់យើងដល់ព្រះជាម្ចាស់ គឺជាផ្លូវតែមួយគត់ដែលយើងអាចឆ្លើយតបចំពោះសេចក្ដីស្រឡាញ់ដ៏អស្ចារ្យក្រៃលែងរបស់ទ្រង់បាន។

ព្រះអម្ចាស់យេស៊ូវបានទាមទារយ៉ាងតឹងរ៉ឹងលើពួកអ្នកដែលនឹងក្លាយទៅជាសិស្សរបស់ទ្រង់ ប៉ុន្តែមនុស្សគ្រប់គ្នាក្នុងសម័យដ៏ហ៊ឺហានាពេលបច្ចុប្បន្ននេះ ស្ទើរតែមើលរំលងលើការទាមទារទាំងអស់នោះបាត់ទៅហើយ។ ជារឿយៗយើងច្រឡំដោយស្មានថា ការធ្វើជាគ្រីស្ទបរិស័ទគឺដូចជាការរត់គេចពីស្ថាននរក ហើយធានាថានឹងបានទៅស្ថានសួគ៌។ លើសពីនេះទៅទៀត យើងគិតថា គ្រីស្ទបរិស័ទ

មានសិទ្ធិធ្វើអ្វីៗគ្រប់យ៉ាងតាមចិត្ត ដើម្បីធ្វើឲ្យជីវិតសប្បាយរីករាយ។ យើងបានដឹងហើយថា មានខគម្ពីរតឹងរ៉ឹងមួយចំនួនស្តីពីភាពជាសិស្សនៅក្នុងព្រះគម្ពីរ ប៉ុន្តែយើងមានការលំបាកណាស់ក្នុងការធ្វើឲ្យខគម្ពីរទាំងនោះស្របទៅនឹងគំនិតរបស់យើងដែលគិតថា ជីវិតជាគ្រីស្ទបរិស័ទគួរមានលក្ខណៈល្អបែបនេះ ឬបែបនោះ។

យើងព្រមទទួលយកការពិតដែលថា ពួកទាហានហ៊ានប្តូរជីវិតរបស់ពួកគេដោយបុព្វហេតុស្នេហាជាតិ ហើយយើងមិនគិតថាវាជារឿងចម្លែកនោះទេ ដែលពួកអ្នកកាន់លទ្ធិកុម្មុយនីស្ត (Communists) ឬពួកអ្នកកាន់សាសនាអ៊ីស្លាម ហ៊ានប្តូរជីវិតរបស់ពួកគេដោយសារហេតុផលនយោបាយ ឬសាសនារបស់ពួកគេនោះ។ ប៉ុន្តែបើថា ជីវិតគ្រីស្ទបរិស័ទត្រូវតែទទួលរងនូវភាពវេទនានោះ ស្តាប់ទៅហាក់បីដូចជាមិនទំនង ហើយពិបាកនឹងយល់។

ទោះបើយ៉ាងនេះក្តី  ព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូវបានបញ្ជាក់យ៉ាងច្បាស់លាស់ហើយពីលក្ខខណ្ឌនៃភាពជាសិស្សរបស់ទ្រង់។ វាមិនគួរនឹងពិបាកយល់សោះ ប្រសិនបើយើងព្រមទទួលស្គាល់នូវអត្ថន័យជាក់ស្តែងនៃខគម្ពីរទាំងនោះ។ ខាងក្រោមនេះគឺជាលក្ខខណ្ឌនៃភាពជាសិស្សដូចដែលព្រះសង្គ្រោះរបស់មនុស្សលោកបានចែងទុកមក៖

## សិស្សដ៏ពិតត្រូវមានសេចក្តីស្រឡាញ់ដ៏ធំក្រៃលែងចំពោះព្រះយេស៊ូវគ្រីស្ទ

*«បើអ្នកណាមកឯខ្ញុំ ដោយមិនស្អប់ឪពុកម្តាយ ប្រពន្ធកូន បងប្អូនប្រុសស្រី និងសូម្បីតែជីវិតរបស់ខ្លួនទេ  អ្នកនោះមិនអាចធ្វើជាសិស្សរបស់ខ្ញុំបានឡើយ»* (លូកា ១៤:២៦ គបខ)។ នេះមិនមែនមានន័យថា យើងត្រូវតែមានសម្អប់ ឬបំណងអាក្រក់ចំពោះញាតិសន្តានរបស់យើងនោះទេ ប៉ុន្តែមានន័យថា សេចក្តីស្រឡាញ់របស់យើងចំពោះព្រះគ្រីស្ទគឺធំក្រៃលែង ហើយសេចក្តីស្រឡាញ់ចំពោះញាតិសន្តានមិនអាចប្រៀបស្មើនឹងសេចក្តីស្រឡាញ់ដែលយើងមានចំពោះទ្រង់បានឡើយ។ តាមពិតឃ្លាដែលពិបាកជាងគេនៅក្នុងខគម្ពីរនេះគឺ៖ *«សូម្បីតែជីវិតរបស់ខ្លួន»*។ ការស្រឡាញ់ខ្លួន

ឯងគឺជាឧបសគ្គមួយដ៏មុតស្រួចជាងគេក្នុងការធ្វើជាសិស្សរបស់ទ្រង់។ ដរាបណាយើងមិនសុខចិត្តប្រគល់ជីវិតរបស់យើងដើម្បីទ្រង់ទេ នោះយើងក៏មិនទាន់រស់នៅតាមរបៀបដែលព្រះជាម្ចាស់សព្វព្រះហឫទ័យនៅឡើយ។

## សិស្សដ៏ពិតត្រូវតែ
## លះកាត់ចិត្តខ្លួនឯង

*«បើអ្នកណាចង់មកតាមខ្ញុំ នោះត្រូវឲ្យលះកាត់ចិត្តខ្លួនឯងចោលចេញ ហើយផ្ទុកឈើឆ្កាងខ្លួន...»* (ម៉ាថាយ ១៦:២៤)។ ការលះកាត់ចិត្តខ្លួនឯងមិនមែនមានន័យថា ត្រូវប្រព្រឹត្តដូចតាបសនោះទេ។ ការធ្វើដូចជាតាបសមានន័យថា ការតមអាហារមួយចំនួន តមន្ទូវការសប្បាយរីករាយ ឬការលះបង់ទ្រព្យសម្បត្តិផ្សេងៗ។ ផ្ទុយទៅវិញ ការលះកាត់ចិត្តខ្លួនឯងនោះមានន័យថា យើងត្រូវចុះចូលយ៉ាងពេញលេញចំពោះការយកព្រះគ្រីស្ទធ្វើជាម្ចាស់ ហើយខ្លួនឯងមិនមានសិទ្ធិអំណាចអ្វីទាល់តែសោះ នោះមានន័យថា ខ្លួនឯងដាក់រាជ្យថ្វាយទ្រង់។ ការលះកាត់ចិត្តខ្លួនឯងមានបញ្ជាក់នៅក្នុងសម្រង់សម្ដីរបស់លោក ហេនរី ម័រធីន (Henry Martyn)៖ «ឱ! ព្រះជាម្ចាស់អើយ សូមកុំឲ្យទូលបង្គំមានឆន្ទៈដែលកើតចេញដោយខ្លួនឯង ឬក៏ចាត់

ទុកសុភមង្គលពិតរបស់ខ្លួន ដោយការពឹងផ្អែកទៅលើស្ថានភាពខាងសាច់ឈាមទូលបង្គំនោះឡើយ ទោះបើវាស្ថិតនៅក្នុងកម្រិតដ៏តូចយ៉ាងណាក៏ដោយ ប៉ុន្តែសូមឲ្យទាំងអស់កើតមានឡើងដោយអនុលោមទៅតាមព្រះហឫទ័យរបស់ទ្រង់វិញ»។

*ព្រះអម្ចាស់ខ្ញុំរុងរឿងអស្ចារ្យ ទ្រង់ឱបក្រសោបក្នុងព្រះហត្ថា*
*ឆន្ទៈនៃខ្ញុំគឺអង្គក្សត្រា អំណារគ្រប់គ្រាបានបម្រើទ្រង់។*

— លោក អេឆ. ជី. ស៊ី. ម៉ូល
(H. G. C. Moule)

## សិស្សដ៏ពិតត្រូវតែជ្រើសយក
## ឈើឆ្កាងដោយចេតនា

*«បើអ្នកណាចង់មកតាមខ្ញុំ នោះត្រូវឲ្យលះកាត់ចិត្តខ្លួនឯងចោលចេញ ហើយផ្ទុកឈើឆ្កាងខ្លួន...»* (ម៉ាថាយ ១៦:២៤)។ ឈើឆ្កាងមិននឹងពិការភាពខាងផ្លូវកាយ ឬក៏ការឈឺចាប់ខាងផ្លូវចិត្តនោះទេ ព្រោះបញ្ហាទាំងនេះវាកើតមានជាធម្មតាចំពោះមនុស្សគ្រប់ៗរូបទៅហើយ។ ផ្លូវនៃឈើឆ្កាងគឺជាគន្លងមួយដែលយើងត្រូវជ្រើសរើសដើរដោយចេតនា គឺដូចដែលលោក ស៊ី. អេ. ខូតស៍ (C. A. Coates)

បានលើកឡើងថា «ផ្លូវនៃឈើឆ្កាង គឺជាគន្លងមួយដែលលោកីយ៍បានគិតថា ជាគន្លងនៃសេចក្ដីអាប់យស និងសេចក្ដីបន្ទោស»។ ឈើឆ្កាងតំណាងពី ភាពអាម៉ាស់ ការបៀតបៀន និងការធ្វើទុក្ខទោសដែលលោកីយ៍បានផ្ទុកលើព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ហើយដែលលោកីយ៍នឹងផ្ទុកលើអស់អ្នកទាំងឡាយណាដែលសម្រេចចិត្តក្រោកឈរ ប្រឆាំងនឹងទំនោរដែលនៅជុំវិញពួកគេ។ យើងអាចគេចពីភាពអាម៉ាស់នៃឈើឆ្កាងបានយ៉ាងងាយ ដោយគ្រាន់តែត្រាប់តាមរបៀបនៃលោកីយ៍។

## សិស្សដ៏ពិតត្រូវតែចំណាយជីវិត ដើរតាមព្រះគ្រីស្ទ

*«បើអ្នកណាចង់មកតាមខ្ញុំ នោះត្រូវឲ្យលះកាត់ចិត្តខ្លួនឯងចោលចេញ ហើយផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំចុះ»* (ម៉ាថាយ ១៦:២៤)។ ដើម្បីឲ្យយើងយល់ពីអត្ថន័យពីថាសេចក្ដីទាំងនេះមានន័យយ៉ាងដូចម្ដេច គឺយើងគ្រាន់តែត្រូវសួរខ្លួនឯងថា «តើជីវិតរស់នៅរបស់ព្រះអម្ចាស់យេស៊ូវមានលក្ខណៈបែបណា?» ជីវិតរស់នៅរបស់ទ្រង់មានលក្ខណៈពេញដោយ ការស្ដាប់បង្គាប់តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ការរស់នៅក្នុងអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធ

ការបម្រើមនុស្សដទៃដោយមិនមានភាពអាត្មានិយម ព្រមទាំងចេះអត់ធ្មត់ និងការស៊ូប្រឈមមុខចំពោះសេចក្តីអាក្រក់ដ៏ធ្ងន់ធ្ងរ មានភាពឆេះឆួល ចេះចំណាយប្រាក់កាស និងពេលវេលាបានយ៉ាងត្រឹមត្រូវ ដឹងខ្មាត ស្លូតបូត ហើយសប្បុរស និងស្មោះត្រង់ ព្រមទាំងមានភក្តីភាព (កាទ្បាទី ៥:២២-២៣)។ ដើម្បីធ្វើជាសិស្សរបស់ទ្រង់ យើងត្រូវតែដើរឲ្យដូចជាទ្រង់បានដើរដែរ។ យើងត្រូវតែបង្ហាញផលផ្លែដូចជាព្រះគ្រីស្ទ (យ៉ូហាន ១៥:៨)។

## សិស្សដ៏ពិតត្រូវមានសេចក្តីស្រឡាញ់ដ៏ក្លៀវក្លា ចំពោះអ្នកដែលជាកម្មសិទ្ធិរបស់ព្រះគ្រីស្ទ

*“គេនឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំដោយសារសេចក្តីនេះឯង គឺដោយអ្នករាល់គ្នាមានសេចក្តីស្រឡាញ់ដល់គ្នាទៅវិញទៅមក”* (យ៉ូហាន១៣:៣៥)។ នេះគឺជាសេចក្តីស្រឡាញ់ដែលចាត់ទុកអ្នកដទៃប្រសើរជាងខ្លួនឯង។ ហើយនេះក៏ជាសេចក្តីស្រឡាញ់ដែលគ្របបាំងអំពើបាបជាអនេកអនន្ត (១ពេត្រុស ៤:៨)។ សេចក្តីស្រឡាញ់បែបនេះតែងតែអត់ធ្មត់ ហើយសប្បុរស ក៏មិនចេះអួតខ្លួន ហើយមិនមានចិត្តធំផង មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង និងមិនដែល

មានគំនិតអាក្រក់ទេ គឺគ្របបាំងទាំងអស់ ទ្រាំទ្រទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ (១កូរិនថូស ១៣:៤-៧)។ ប្រសិនបើគ្មានក្ដីស្រឡាញ់បែបនេះទេ ភាពជាសិស្សច្បាស់ជាគ្មានប្រយោជន៍ ហើយបដិសេធខ្លួនឯងចោលទទេ ដោយគ្រាន់តែទៅតាមបញ្ញត្តិរបស់សាសនាតែប៉ុណ្ណោះ។

## សិស្សដ៏ពិតត្រូវតែបន្តរស់នៅក្នុង ព្រះបន្ទូលទ្រង់ដោយមិនរាថយ

*«...បើអ្នករាល់គ្នានៅជាប់ក្នុងពាក្យខ្ញុំ នោះអ្នករាល់គ្នាជាសិស្សខ្ញុំមែន»* (យ៉ូហាន ៨:៣១)។ ការធ្វើជាសិស្សដ៏ពិតតម្រូវឲ្យបុគ្គលនោះបន្តរស់នៅក្នុងភាពជាសិស្សជាដរាប។ ការចាប់ផ្ដើមធ្វើជាសិស្សល្អគឺងាយស្រួលទេ ប្រៀបបានដូចជាអណ្ដាតភ្លើងកាំជ្រួចដែលបានផ្ទុះបែកផ្កាភ្លើងយ៉ាងស្អាត រួចក៏រលាយបាត់ទៅវិញមួយរំពេច។ ប៉ុន្តែការសាកល្បងជាក់ស្ដែង ដើម្បីឲ្យដឹងថា បុគ្គលម្នាក់បានក្លាយជាសិស្សដ៏ពិត គឺគាត់ត្រូវស៊ូទ្រាំរហូតដល់ទីបំផុត។ បុគ្គលណាដែលបានដាក់ដៃកាន់នង្គ័លហើយងាកមើលទៅក្រោយគឺមិនស័ក្តិសមទៅនឹងនគររបស់ព្រះជាម្ចាស់ឡើយ (លូកា ៩:៦២)។ ការស្ដាប់បង្គាប់តាមបទគម្ពីរតែម្ដងម្កាលនោះមិនគ្រប់គ្រាន់ទេ។ ព្រះគ្រីស្ទសព្វព្រះ

ហឫទ័យឲ្យអ្នកដែលចង់ដើរតាមទ្រង់ ស្តាប់បង្គាប់ឲ្យខ្ជាប់ខ្ជួនដោយមិនប្រឆាំង ឬសង្ស័យអ្វីឡើយ។

*សូមកុំឲ្យខ្ញុំ បែរចេញពីទ្រង់  ដងនង្គ័លជន់ ដោយទឹកនេត្រា*
*កណ្តៀវវិនាស ច្រែសចាប់យ៉ាងណា សូមទ្រង់រក្សា កុំឲ្យបែកបែរ។*

— មិនស្គាល់អ្នកនិពន្ធ

## សិស្សដ៏ពិតត្រូវតែលះអាល័យអ្វីៗ ទាំងអស់ដើម្បីតាមទ្រង់

*«ដូច្នេះ  អស់អ្នកណានៃអ្នករាល់គ្នាដែលមិនលះអាល័យពីរបស់ទ្រព្យខ្លួនទាំងអស់នោះនឹងធ្វើជាសិស្សខ្ញុំមិនបានទេ»* (លូកា ១៤:៣៣)។ មនុស្សភាគច្រើនគិតថា លក្ខខណ្ឌនៃភាពជាសិស្សរបស់ព្រះគ្រីស្ទក្នុងខគម្ពីរមួយនេះពិបាកអនុវត្តជាងគេ។ តាមពិតមានមនុស្សជាច្រើនមិនសូវចូលចិត្តខគម្ពីរនេះនោះទេ។ អ្នកទេវវិទូអាចបង្កើតលេសបានជាងមួយពាន់ហេតុផលដែលថា ខគម្ពីរនេះមិនមែនមានន័យថា ត្រូវលះអាល័យពីរបស់ទ្រព្យខ្លួនទាំងអស់នោះទេ ប៉ុន្តែយើងដែលជាសិស្សសាមញ្ញៗងាយនឹងទទួលយកខគម្ពីរនេះ ហើយទទួលស្គាល់ថា ព្រះគ្រីស្ទជ្រាបពីអ្វីដែលទ្រង់បាន

មានបន្ទូល។ តើការលះអាល័យពីរបស់ទ្រព្យខ្លួនទាំងអស់មានន័យយ៉ាងដូចម្ដេច? នេះមានន័យថា សិស្សរបស់ទ្រង់ត្រូវលះ-បង់ទ្រព្យសម្បត្តិដែលមិនចាំបាច់របស់ខ្លួនទាំងអស់ចោល ដើម្បីយកវាមកប្រើប្រាស់ក្នុងការផ្សាយដំណឹងល្អ។ បុគ្គលណាដែលលះបង់គ្រប់អ្វីៗទាំងអស់ចោល នោះមិនមែនមានន័យថា គាត់ចំណាយពេលដោយឥតប្រយោជន៍នោះទេ។ គាត់នៅតែខំប្រឹងធ្វើការ ដើម្បីផ្គត់ផ្គង់តម្រូវការចាំបាច់នាពេលបច្ចុប្បន្នរបស់គ្រួសារគាត់ និងខ្លួនគាត់ផ្ទាល់។ ប៉ុន្តែ ចាប់តាំងពីគាត់បានមានចិត្តឆេះ-ឆួល ដើម្បីផ្សព្វផ្សាយពីព្រះគ្រីស្ទមក គាត់បានដាក់ចិត្តដាក់កាយទាំងស្រុងក្នុងការងាររបស់ព្រះជាម្ចាស់ខ្ពស់ជាងការផ្គត់ផ្គង់តម្រូវការបច្ចុប្បន្នរបស់គាត់ទៅទៀត ហើយបានផ្ញើអនាគតទាំងស្រុងនឹងព្រះជាម្ចាស់តែម្ដង។ នៅក្នុងការស្វែងរកនគរ និងសេចក្ដីសុចរិតនៃព្រះជាម្ចាស់ជាចម្បង គាត់ជឿថា គាត់នឹងមិនចេះខ្វះម្ហូបអាហារ និងសំលៀកបំពាក់សោះឡើយ។ គាត់មិនសុខចិត្តក្ដោបលុយរបស់គាត់ស្របពេលដែលគាត់ដឹងថា មានមនុស្សដែលត្រូវការដំណឹងល្អជាច្រើនកំពុងតែវិនាស។ គាត់មិនចង់ខ្ជះខ្ជាយជីវិតរបស់គាត់ដោយការបង្កើតទ្រព្យសម្បត្តិដែលនឹងធ្លាក់ក្នុងកណ្ដាប់ដៃរបស់អារក្ស នៅពេលដែលព្រះគ្រីស្ទយាងមកយកពួកបរិសុទ្ធរបស់ទ្រង់នោះឡើយ។ គាត់

ចង់ស្ដាប់តាមសេចក្ដីបង្គាប់របស់ព្រះអម្ចាស់ដែលទាស់នឹងការប្រមូលទ្រព្យសម្បត្តិទុកនៅលើផែនដីនេះ។ គាត់បានឯកភាពនឹងសម្ដីរបស់លោក ដេវីឌ លីវីងស្តូន (David Livingstone) ទាក់ទងនឹងការលះអាល័យអ្វីៗទាំងអស់ចោលថា «ខ្ញុំសោកស្ដាយណាស់ដែលខ្ញុំគ្មានអ្វីសេសសល់ថ្វាយទៅទ្រង់ទៀត»។

សេចក្ដីទាំងនេះ គឺជាលក្ខខណ្ឌទាំងប្រាំពីរយ៉ាងនៃភាពជាសិស្សរបស់ព្រះគ្រីស្ទ។ លក្ខខណ្ឌទាំងប្រាំពីរនេះមានភាពច្បាស់លាស់ហើយក៏មិនមានមន្ទិលសង្ស័យអ្វីនោះដែរ។ ពិតប្រាកដណាស់យើងបានដាក់ទោសខ្លួនឯងថាជាអ្នកបម្រើដែលគ្មានបានផលចំ-ណេញ ដោយសារយើងមិនបានអនុវត្តតាមលក្ខខណ្ឌទាំងនេះបានទាំងស្រុង។ ប៉ុន្តែ តើសេចក្ដីពិតរបស់ព្រះជាម្ចាស់នឹងត្រូវបង្ខាំងជារៀងរហូតដោយសារការបរាជ័យនៃប្រជារាស្ត្ររបស់ទ្រង់ឬ? តើវាមិនមែនជាការពិតទេឬអីដែលថា សារលិខិតតែងតែធំជាងអ្នកនាំសារនោះ? តើវាមិនមែនជាការត្រឹមត្រូវទេឬអីដែលថា ព្រះជាម្ចាស់ទ្រង់ពិតត្រង់ ហើយមនុស្សគ្រប់ៗគ្នាគឺជាអ្នកភូតភរ? តើយើងមិនគួរនិយាយឲ្យដូចអ្វីដែលអ្នកជឿជំនាន់មុនលើកឡើងថា «សូមឲ្យព្រះហឫទ័យទ្រង់បានសម្រេច ទោះបើខ្ញុំត្រូវវិនាសក៏ដោយ» ទេឬអី?

ស្របពេលដែលយើងសារភាពពីការបរាជ័យកន្លងមករបស់

យើង នោះចូរឲ្យយើងហ៊ានប្រឈមមុខនឹងបញ្ញត្តិរបស់ព្រះគ្រីស្ទ ចំពោះយើង ហើយសូមឲ្យយើងទាំងអស់គ្នាព្យាយាមធ្វើជាសិស្សដ៏ពិតប្រាកដរបស់ព្រះអម្ចាស់ដ៏រុងរឿងនៃយើងចាប់ពីពេលនេះតទៅ។

*ឱ! ម្ចាស់ខ្ញុំអើយនាំខ្ញុំទៅទ្វារទ្រង់ផង*
*ខ្ញុំត្រៀមក្រាប់ត្រងចោះត្រចៀកសាជាថ្មី*
*សូមចងខ្ញុំឲ្យជាប់នូវចំណងសេរី*
*ស៊ូទ្រាំឃ្នាតខ្មីនឿយហត់ស្ដាប់បង្គាប់ទ្រង់។*

— លោក អេឆ. ជី. ស៊ី. ម៉ូល
(H. G. C. Moule)

## ជំពូកទី២

# ការលះអាល័យអ្វីៗ ទាំងអស់ចោល

*«ដូច្នេះអស់អ្នកទាំងឡាយណានៃអ្នករាល់គ្នាដែលមិនលះអាល័យពីរបស់ទ្រព្យទាំងអស់នោះនឹងធ្វើជាសិស្សខ្ញុំមិនបានទេ»*

(លូកា ១៤:៣៣)។

ដើម្បីធ្វើជាសិស្សរបស់ព្រះអម្ចាស់យេស៊ូវបាន យើងត្រូវតែលះអាល័យអ្វីៗទាំងអស់ចោល។ នេះហើយគឺជាអត្ថន័យដ៏ច្បាស់លាស់នៃព្រះបន្ទូលរបស់ព្រះសង្គ្រោះ។ ទោះបីជាយើងបដិសេធចំពោះការទាមទារដែលយើងគិតថា ហួសហេតុយ៉ាងណាក៏ដោយ ឬក៏បះបោរប្រឆាំងនឹងច្បាប់នេះដែលយើងយល់ថា ជាច្បាប់ល្ងង់ខ្លៅ ហើយជាច្បាប់ដែលមិនអាចធ្វើបានយ៉ាងណាក៏ដោយ ក៏ការទាមទារនេះនៅតែជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយទ្រង់ពិតជាចង់មានន័យតាមពាក្យដែលទ្រង់បានមានបន្ទូលមែន។

យើងត្រូវតែទទួលយកការពិតដែលមិនអាចបត់បែនទាំងនេះជាមុនសិន៖

- ព្រះយេស៊ូវមិនមែនគ្រាន់តែត្រាស់ហៅមនុស្សមួយចំនួនចេញពីអ្នកបម្រើព័ន្ធកិច្ចរបស់ទ្រង់នោះទេ តែទ្រង់បានត្រាស់ហៅ៖ *«អស់អ្នកទាំងឡាយ...»*។
- ទ្រង់មិនបានមានបន្ទូលថា យើងគ្រាន់តែត្រូវមានឆន្ទៈព្រមលះអាល័យអ្វីៗទាំងអស់ចោលនោះទេ តែទ្រង់បានមានបន្ទូលថា៖ *«អស់អ្នកទាំងឡាយណានៃអ្នករាល់គ្នាដែលមិនលះអាល័យ...»*។
- ទ្រង់មិនបានមានបន្ទូលថា យើងគ្រាន់តែត្រូវលះអាល័យផ្នែកណាមួយនៃទ្រព្យសម្បត្តិរបស់យើងចោលនោះទេ តែទ្រង់បានមានបន្ទូលថា៖ *«អស់អ្នកទាំងឡាយណានៃអ្នករាល់គ្នាដែលមិនលះអាល័យពីរបស់ទ្រព្យទាំងអស់...»*។
- ទ្រង់មិនបានមានបន្ទូលថា បុគ្គលណាដែលមិនព្រមលះបង់ទ្រព្យសម្បត្តិអាចនឹងធ្វើជាសិស្សតូចទាបម្នាក់របស់ទ្រង់បាននោះទេ តែព្រះយេស៊ូវបានមានបន្ទូលថា៖ អ្នកនោះ *«នឹងធ្វើជាសិស្សខ្ញុំមិនបានទេ»*។

តាមពិត យើងមិនគួរភ្ញាក់ផ្អើលចំពោះការទាមទារដ៏ជាក់លាក់នេះទេ ព្រោះវាមិនមែនជាសំណូមពរយ៉ាងជាក់លាក់តែមួយគត់នៅក្នុងព្រះគម្ពីរឯណា!

តើព្រះយេស៊ូវមិនបានមានបន្ទូលទេឬអីថា៖ «*កុំឲ្យប្រមូលទ្រព្យសម្បត្តិ ទុកសំរាប់ខ្លួននៅផែនដីជាកន្លែងដែលមានកន្លាតនឹងច្រែះស៊ីបំផ្លាញ ហើយចោរទំលុះប្លន់នោះឡើយ ត្រូវប្រមូលទ្រព្យសម្បត្តិ ទុកសំរាប់ខ្លួន នៅឯស្ថានសួគ៌វិញ ដែលជាកន្លែងគ្មានកន្លាត ឬច្រែះស៊ីបំផ្លាញឡើយ ក៏គ្មានចោរទំលុះ ឬប្លន់ផង*» (ម៉ាថាយ ៦:១៩-២០)?

ដូចដែលលោក ចន វេស្លី (John Wesley) បានមានប្រសាសន៍ត្រង់ៗថា៖ «ព្រះជាម្ចាស់របស់យើងបានហាមឃាត់ចំពោះការប្រមូលទ្រព្យសម្បត្តិទុកនៅលើផែនដីនេះយ៉ាងច្បាស់លាស់ដូចដែលទ្រង់បានហាមចំពោះការផិតក្បត់ និងការធ្វើឃាតយ៉ាងដូច្នោះដែរ»។

តើព្រះយេស៊ូវមិនបានមានបន្ទូលទេឬអីថា៖ «*លក់របស់ដែលអ្នករាល់គ្នាមានទាំងប៉ុន្មាន ហើយចែកឲ្យទៅជាទានចុះ*» (លូកា ១២:៣៣)? តើទ្រង់មិនបានប្រាប់នាម៉ឺនក្មេងដែលជាអ្នកមានទេឬអីថា៖ «*...លក់របស់ទ្រព្យអ្នកទាំងប៉ុន្មានចែកទានឲ្យដល់ពួកអ្នកក្រីក្រទៅ នោះអ្នកនឹងមានទ្រព្យសម្បត្តិនៅលើស្ថានសួគ៌វិញ រួចមកតាមខ្ញុំចុះ*» (លូកា ១៨:២២)?

ប្រសិនបើព្រះបន្ទូលរបស់ទ្រង់នៅត្រង់ចំណុចនេះមិនមានន័យត្រង់ៗយ៉ាងដូច្នេះ នោះ តើទ្រង់ចង់មានន័យយ៉ាងម៉េចវិញ?

តើវាមិនពិតទេឬអីចំពោះអ្នកជឿទាំងអស់នៃក្រុមជំនុំដំបូងដែលពួកគេបាន *«...លក់ទ្រព្យសម្បត្តិ និងរបស់គេទាំងប៉ុន្មាន ចែកដល់គ្នាតាមដែលគ្រប់គ្នាត្រូវការ»* (កិច្ចការ ២:៤៥)? តើការដែលពួកបរិសុទ្ធជាច្រើនរបស់ព្រះជាម្ចាស់នាឆ្នាំកន្លងទៅបានលះបង់អ្វីៗទាំងអស់ចោល ដើម្បីដើរតាមព្រះយេស៊ូវ នោះមិនមែនជាការពិតទេឬអី?

លោក អែនថូនី នូរីស៍ ហ្គ្រូវស៍ (Anthony Norris Groves) និងភរិយារបស់គាត់ជាបេសកជនក្នុងចំណោមបេសកជនដំបូងនៅទីក្រុង បាដាដ (Baghdad) បានសម្រេចចិត្តថា «ពួកគេត្រូវតែបញ្ឈប់ការប្រមូលទ្រព្យសម្បត្តិទុកនៅលើផែនដី ហើយគួរតែសុខចិត្តលះ-បង់ប្រាក់ចំណូលដ៏ច្រើនទាំងអស់នោះថ្វាយចំពោះព័ន្ធកិច្ចរបស់ព្រះជាម្ចាស់»។[១] យើងអាចមើលឃើញពីជំនឿស៊ប់របស់លោក ហ្គ្រូវស៍ (Groves) នៅក្នុងកូនសៀវភៅរបស់គាត់ដែលមានចំណងជើងថា *Christian Devotedness*។[២]

លោក ស៊ី. ធី. ស្ទឹដ (C. T. Studd) បានសម្រេចចិត្តប្រគល់ទ្រព្យសម្បត្តិដ៏មហាសាលរបស់គាត់ទាំងអស់ថ្វាយដល់ព្រះគ្រីស្ទ ហើយមកយកឱកាសមាសដែលនៅខាងមុខគាត់ ដើម្បីធ្វើអ្វីដែល

នាម៉ឺនក្មេងនៅក្នុងព្រះគម្ពីរមិនព្រមធ្វើ។ វាគឺជាការស្តាប់បង្គាប់ដ៏សាមញ្ញតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។[៣]

បន្ទាប់ពីបានថ្វាយលុយរាប់លានដុល្លារទៅដល់ព័ន្ធកិច្ចរបស់ព្រះជាម្ចាស់គាត់បានទុកប្រាក់បម្រុងដែលមានចំនួនប្រមាណជា ៤00,000ដុល្លារ[៤]សម្រាប់ប្រពន្ធរបស់គាត់។ នាងក៏មិនឲ្យចាញ់ស្វាមីរបស់នាងដែរ ដូច្នេះនាងបានសួរថា «បង! តើព្រះជាម្ចាស់បានប្រាប់នាម៉ឺនក្មេងឲ្យធ្វើយ៉ាងម៉េច?»

គាត់បានឆ្លើយឡើងថា «លក់អ្វីៗទាំងអស់»។

ប្រពន្ធបានតបថា «បើអញ្ចឹង ចាប់ពីថ្ងៃនេះទៅយើងនឹងចាប់ផ្តើមស្តាប់បង្គាប់ព្រះជាម្ចាស់ឲ្យពេញទី»។

ហើយពួកគេក៏បានប្រគល់ប្រាក់ទាំងអស់នោះទៅឲ្យក្រុមបេសក-កម្មគ្រីស្ទបរិស័ទ។

គំនិតនៃភក្តីភាពដូចគ្នានេះបានដាស់សតិលោក ជីម អេលាត (Jim Elliot)។ គាត់បានសរសេរនៅក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់គាត់ថា៖

> ឱ! ព្រះវរបិតាអើយ សូមឲ្យទូលបង្គំចុះខ្សោយ ដើម្បីឲ្យទូលបង្គំអាចរបូតចេញពីការឱបក្រសោបរបស់ទូលបង្គំទៅលើអ្វីៗទាំងអស់ដែលជារបស់បណ្តោះអាសន្ននេះទៅ។ ព្រះអម្ចាស់អើយ សូមឲ្យទូលបង្គំរួចពីកណ្តាប់

ដែដ៏តានតឹង ចំពោះជីវិតរបស់ទូលបង្គំ កេរ្តិ៍ឈ្មោះរបស់ទូលបង្គំ និងទ្រព្យ-សម្បត្តិរបស់ទូលបង្គំនេះចុះ ហើយថែមទាំងឲ្យទូលបង្គំលះបង់ចោលនូវចិត្តចង់មានចង់បានរបស់ឥតប្រយោជន៍ទាំងនេះផង។ ម្តងហើយម្តងទៀតទូលបង្គំបានលះបង់ការចាប់កាន់លើអ្វីដែលទូលបង្គំចង់បានចោល ប៉ុន្តែទូលបង្គំបានចាប់វាមកវិញដោយចិត្តចង់មានចង់បានជាខ្លាំង ហើយស្មានថា វាគ្មានគ្រោះថ្នាក់ បើគ្រាន់តែស្ទាបអង្អែល។ ប៉ុន្តែផ្ទុយទៅវិញនោះ ឱ! ព្រះវរបិតាអើយ សូមលាតដៃរបស់ទូលបង្គំ ដើម្បីទទួលដែកគោលនៃភ្នំលលាដ៍ក្បាលដូចដែលព្រះហស្តរបស់ព្រះគ្រីស្ទបានលាត ដើម្បីឲ្យការលះបង់នេះនាំឲ្យទូលបង្គំបានរួច ហើយលែងជាប់ចំណងនេះទៀត។ ទ្រង់មានព្រះតម្រិះថា នគរស្ថានសួគ៌ និងភាពដែលស្មើនឹងព្រះជាម្ចាស់នោះមិនមែនជាអ្វីដែលទ្រង់ត្រូវកាន់ខ្ជាប់នោះឡើយ។ ដូច្នេះ សូមឲ្យទូលបង្គំបានលាតដៃរបស់ទូលបង្គំដែលកាន់ក្តោបនោះចេញទៅ។[៩]

ចិត្តដែលមិនចេះជឿរបស់យើងប្រាប់យើងថា យើងមិនអាចធ្វើតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ត្រង់ៗនោះបានទេ។ ប្រសិនបើយើងបានលះអាល័យអ្វីៗទាំងអស់ចោល នោះយើងនឹងដាច់ពោះស្លាប់ជាមិនខាននោះឡើយ។ មិនដឹងទេឬអីថា យើងត្រូវតែផ្គត់ផ្គង់អនាគតរបស់យើងផ្ទាល់ និងអនាគតរបស់មនុស្សដែលយើងស្រ-

ឡាញ់នោះ? ប្រសិនបើគ្រីស្ទបរិស័ទទាំងអស់បានលះអាល័យអ្វីៗ ទាំងអស់ចោលហើយ ចុះតើអ្នកណានឹងផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុដល់ ព័ន្ធកិច្ចរបស់ព្រះអម្ចាស់ទៅ? ហើយប្រសិនបើមិនមានគ្រីស្ទបរិស័ទ មួយចំនួនដែលមានស្តុកស្តម្ភទេនោះ ចុះតើធ្វើដូចម្តេចទើបដំណឹងល្អ នឹងអាចទៅដល់មនុស្សថ្នាក់ខ្ពស់ទាំងអស់នោះបាន? ដូច្នេះពួកគេ បានឲ្យជាលេសជាច្រើន ដើម្បីបដិសេធពីអត្ថន័យដើមរបស់ព្រះ អម្ចាស់យេស៊ូវត្រង់ខគម្ពីរនេះ។

ធាតុពិតត្រង់នោះគឺថា ការស្តាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះ ជាម្ចាស់ គឺជាការឆ្លាតវៃ និងសមហេតុផលបំផុតក្នុងជីវិត ហើយ អស់អ្នកដែលប្រព្រឹត្តតាមនោះនឹងទទួលបានអំណរដ៏អស្ចារ្យក្រៃ-លែង។ ស្មរបន្ទាល់នៃបទគម្ពីរ និងបទពិសោធន៍មនុស្សផ្សេងទៀត បានបង្ហាញឲ្យយើងឃើញថា គ្មាននរណាម្នាក់ដែលពលីសម្រាប់ ព្រះគ្រីស្ទ ហើយជួបនឹងការខ្វះខាតនោះទេ។ នៅពេលដែលបុគ្គល ណាម្នាក់ស្តាប់បង្គាប់ព្រះជាម្ចាស់ នោះទ្រង់នឹងថែរក្សាអ្នកនោះ។

បុគ្គលដែលលះអាល័យអ្វីៗទាំងអស់ចោល ដើម្បីដើរតាមព្រះគ្រីស្ទមិនមែនសំដៅលើអ្នកក្រខ្សត់ដែលមិនធ្វើការអ្វីសោះ ហើយរំពឹងទៅលើគ្រីស្ទបរិស័ទនៅជុំវិញគាត់ដើម្បីទទួលការឧបត្ថម្ភនោះទេ ប៉ុន្តែ៖

- **គាត់គឺជាមនុស្សម្នាក់ដែលខំប្រឹងធ្វើការ។** គាត់ធ្វើការយ៉ាងឧស្សាហ៍ ដើម្បីផ្គត់ផ្គង់តម្រូវការបច្ចុប្បន្នរបស់គាត់ និងតម្រូវការរបស់គ្រួសារគាត់។
- **គាត់គឺជាមនុស្សម្នាក់ដែលចេះសន្សំសំចៃ។** គាត់រស់នៅដោយមិនសូវចំណាយប្រាក់ច្រើនតាមដែលគាត់អាចធ្វើបាន ដើម្បីឲ្យគាត់អាចថ្វាយអ្វីៗទាំងអស់ដែលលើសពីតម្រូវការរបស់គាត់ដល់ព័ន្ធកិច្ចរបស់ព្រះអម្ចាស់។
- **គាត់គឺជាមនុស្សម្នាក់ដែលចេះគិតគូរវែងឆ្ងាយពីអនាគត។** ជំនួសឲ្យការប្រមែប្រមូលទ្រព្យសម្បត្តិនៅលើផែនដីនេះ គាត់ប្រមូលទ្រព្យសម្បត្តិរបស់គាត់ទុកនៅស្ថានសួគ៌វិញ។
- **គាត់គឺជាមនុស្សម្នាក់ដែលជឿទុកចិត្តទៅលើព្រះជាម្ចាស់ពីអនាគតរបស់គាត់។** គាត់សុខចិត្តថ្វាយអ្វីៗដែលល្អជាងគេរបស់គាត់ទៅឯព័ន្ធកិច្ចរបស់ព្រះគ្រីស្ទជំនួសការទុកអ្វីៗដែលល្អជាងគេរបស់គាត់នោះសម្រាប់ភាពងាយស្រួល

នៅពេលចាស់ជរា ពីព្រោះគាត់ជឿទុកចិត្តទៅលើទ្រង់ពីអនាគតរបស់គាត់។ គាត់ជឿថា ប្រសិនបើគាត់ស្វែងរកនគររបស់ព្រះជាម្ចាស់ និងសេចក្ដីសុចរិតរបស់ទ្រង់ជាចម្បងលើសអ្វីៗទាំងអស់ នោះគាត់នឹងមិនចេះខ្វះម្ហូបអាហារ និងសំលៀកបំពាក់ឡើយ (ម៉ាថាយ ៦:៣៣)។

- **គាត់គិតថាការប្រមែប្រមូលទ្រព្យសម្បត្តិសម្រាប់ថ្ងៃដែលមានគ្រោះអាសន្នកើតឡើងវាមិនសមហេតុផលទេ។** គំនិតគាត់គឺយ៉ាងដូច្នេះ៖

តើឲ្យយើងព្រមនឹងមិនចំណាយលុយទាំងនោះយ៉ាងដូចម្ដេចបាន នៅពេលដែលយើងដឹងថា យើងអាចយកលុយនោះទៅប្រើប្រាស់ភ្លាមៗក្នុងព័ន្ធកិច្ច ដើម្បីសង្គ្រោះព្រលឹងមនុស្សជាច្រើននោះ? “*បើអ្នកណាមានភោគសម្បត្តិរបស់លោកីយ៍នេះហើយឃើញបងប្អូនណាដែលខ្វះខាតតែមិនចេះអាណិតមេត្តាសោះនោះធ្វើដូចម្ដេចឲ្យសេចក្ដីស្រឡាញ់នៃព្រះបានស្ថិតនៅក្នុងអ្នកនោះបាន?*” (១យ៉ូហាន ៣:១៧)។

ចូរពិចារណាអំពីសេចក្ដីបង្គាប់ដ៏សំខាន់នេះម្តងទៀត *“គឺត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯងវិញ”* (លេវីវិន័យ ១៩:១៨)។ តើយើងអាចហៅខ្លួនឯងថាជាអ្នកស្រឡាញ់អ្នកជិតខាងដូចខ្លួនឯងយ៉ាងពិតប្រាកដដូចម្ដេចបាន បើយើងបណ្ដោយឲ្យពួកគេឃ្លានស្ទើរស្លាប់ នៅពេលដែលយើងមានគ្រប់គ្រាន់ ហើយថែមទាំងមានបម្រុងទុកសម្រាប់ថ្ងៃក្រោយទៀតផងនោះ? សូមឲ្យខ្ញុំសួរសំណួរមួយចំពោះអ្នកដែលធ្លាប់មានអំណរដោយសារគេស្គាល់អំណោយទានដែលមិនអាចកាត់ថ្លៃបានពីព្រះជាម្ចាស់ថា៖ *“តើលោកអ្នកសុខចិត្តដូរអំណរនោះជាមួយនឹងការធ្វើជាស្ដេចលើនគររាប់រយដែរឬទេ?”* បងប្អូនអើយ សូមកុំឲ្យយើងដកយកឱកាសដែលនាំឲ្យអ្នកដទៃទៀតបានទទួលនូវអំណរដែលញែកពួកគេទៅជាវិសុទ្ធ ហើយជាទីកម្សាន្តចិត្តដែលមកពីស្ថានសួគ៌នោះឡើយ។[៦]

ប្រសិនបើយើងជឿជាក់ថា ព្រះគ្រីស្ទពិតជាជិតយាងមកវិញហើយ នោះយើងប្រាកដជានឹងចង់យកលុយរបស់យើងទៅចំណាយភ្លាមៗជាមិនខាន។ បើមិនដូច្នោះទេ លុយដែលគួរនឹងបានប្រើដើម្បីបានព្រះពរអស់កល្បជានិច្ចនឹងធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់អារក្ស។

តើយើងអាចអធិស្ឋានសូមឲ្យព្រះជាម្ចាស់ផ្ដត់ផ្គង់ថវិកាសម្រាប់ព័ន្ធកិច្ចរបស់គ្រីស្ទបរិស័ទយ៉ាងណាបាន នៅពេលដែលខ្លួនយើង

ផ្ទាល់មានប្រាក់ តែមិនព្រមប្រើប្រាស់វាសម្រាប់ព័ន្ធកិច្ចទ្រង់ផង នោះ? ការលះអាល័យអ្វីៗទាំងអស់ចោលថ្វាយព្រះគ្រីស្ទនោះនឹង ជួយយើងឲ្យចាកផុតពីការមានពុតត្បុតពេលយើងអធិស្ឋាន។

តើយើងអាចនឹងបង្រៀនឱវាទទាំងអស់របស់ព្រះជាម្ចាស់ទៅអ្នក ដទៃយ៉ាងដូចម្ដេច ប្រសិនបើយើងនៅមានចំណុចខ្លះៗនៃសេចក្ដីពិត ដែលយើងមិនព្រមធ្វើតាមដូចជាការលះបង់អ្វីៗចោលជាដើមនោះ? បើអញ្ចឹងមែន ចូរឲ្យយើងបិទមាត់ទៅចុះ ដ្បិតយើងខ្លួនឯងមិនបាន ទាំងស្ដាប់បង្គាប់តាមឱវាទព្រះជាម្ចាស់ផង។

មនុស្សឆ្លាតវៃក្នុងលោកីយ៍នេះប្រមូលប្រាក់សន្សំជាច្រើនក្រៃ-លែងទុកសម្រាប់ថ្ងៃអនាគត។ ការនេះមិនមែនជាការដើរដោយ ជំនឿទេ  ប៉ុន្តែជាការដើរតាមអ្វីដែលពួកគេមើលឃើញទៅវិញ។ ព្រះជាម្ចាស់បានត្រាស់ហៅគ្រីស្ទបរិស័ទឲ្យរស់នៅក្នុងជីវិតដែល ពឹងផ្អែកទៅលើទ្រង់ទាំងស្រុង។ ប្រសិនបើ គ្រីស្ទបរិស័ទណាម្នាក់ ប្រមូលទ្រព្យសម្បត្តិទុកនៅលើផែនដីនេះ នោះគាត់ក៏ដូចមនុស្ស លោកីយ៍ដែរ។

មានអ្នកជជែកវែកញែកជាញឹកញាប់ត្រង់ចំណុចនេះថា យើង ត្រូវតែផ្គត់ផ្គង់ តម្រូវការអនាគតរបស់គ្រួសារយើង ហើយបើមិន ដូច្នោះទេ យើងនឹងទៅជាអាក្រក់ជាងអ្នកអត់សាសនាទៅទៀត។

អ្នកជជែកវែកញែកនោះតែងតែប្រើខគម្ពីរពីរខាងក្រោមនេះ ដើម្បីគាំទ្រទស្សនៈរបស់ខ្លួន៖

> ...ដ្បិតមិនគួរឲ្យកូនចៅត្រូវប្រមូលទុកឲ្យឪពុកម្តាយទេ គឺឪពុកម្តាយទេតើដែលត្រូវប្រមូលទុកឲ្យកូនវិញ (២កូរិនថូស ១២:១៤)។
>
> បើមានអ្នកណាដែលមិនផ្គត់ផ្គង់ឲ្យពួកញាតិសន្តានខ្លួន គឺឲ្យពួកអ្នកផ្ទះខ្លួនជាដើម អ្នកនោះឈ្មោះថាបានបោះបង់ចោលសេចក្តីជំនឿហើយក៏អាក្រក់ជាងមនុស្សដែលមិនបានជឿទៅទៀត (១ធីម៉ូថេ ៥:៨)។

បើយើងសិក្សាខគម្ពីរទាំងនេះយ៉ាងយកចិត្តទុកដាក់ នោះយើងនឹងយល់ថា ខគម្ពីរទាំងនេះទាក់ទងនឹងតម្រូវការនាពេលបច្ចុប្បន្នមិនមែនទាក់ទងនឹងតម្រូវការអនាគតនោះទេ។

នៅក្នុងកណ្ឌគម្ពីរ ២កូរិនថូស ១២:១៤ សាវ័ក ប៉ុល បានប្រើពាក្យបង្កប់ន័យ។ គាត់ប្រៀបធៀបខ្លួនឯងដូចជាឪពុក ហើយអ្នកក្រុងកូរិនថូសទាំងអស់ប្រៀបដូចជាកូនរបស់គាត់។ គាត់មិនបានដាក់បន្ទុកលើពួកគេក្នុងរឿងលុយនោះទេ ទោះបីជាគាត់មានសិទ្ធិគ្រប់បែបយ៉ាង ដើម្បីធ្វើដូច្នោះក្នុងនាមជាអ្នកបម្រើព្រះអម្ចាស់យ៉ាងណាក៏ដោយ។ ពិតណាស់ គាត់គឺជាឪពុកខាងឯជំនឿរបស់ពួកគេ

ហើយជាធម្មតាឪពុកម្ដាយតែងតែផ្គត់ផ្គង់ដល់កូនរបស់ខ្លួន មិនមែនកូនដែលត្រូវផ្គត់ផ្គង់ដល់ឪពុកម្ដាយខ្លួននោះឡើយ។ ខគម្ពីរនេះមិនមែនទាក់ទងទៅនឹងការដែលឪពុកម្ដាយប្រមូលទ្រព្យសម្បត្តិទុកសម្រាប់អនាគតកូនរបស់ខ្លួនទាល់តែសោះ។ ខគម្ពីរនេះទាក់ទងទៅនឹងការផ្គត់ផ្គង់តម្រូវការបច្ចុប្បន្នរបស់លោកសាវ័ក ប៉ុល មិនមែនតម្រូវការអនាគតរបស់គាត់នោះទេ។

នៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ៥:៨ សាវ័ក ប៉ុល ចង់និយាយពីការផ្គត់ផ្គង់ស្ត្រីមេម៉ាយក្រីក្រទៅវិញទេ។ គាត់ចង់និយាយថា សាច់ញាតិរបស់ស្ត្រីមេម៉ាយទាំងនោះគឺជាអ្នកដែលត្រូវទទួលខុសត្រូវក្នុងការផ្គត់ផ្គង់ ហើយថែរក្សាពួកគាត់។ ប្រសិនបើ ស្ត្រីមេម៉ាយនោះគ្មានសាច់ញាតិ ឬក៏សាច់ញាតិរបស់គាត់មិនទទួលខុសត្រូវ នោះក្រុមជំនុំត្រូវតែផ្គត់ផ្គង់ថែរក្សាស្ត្រីមេម៉ាយដែលជាគ្រីស្ទបរិស័ទនោះ។ ប៉ុន្តែដូចគ្នាទៅនឹងកណ្ឌគម្ពីរ ២កូរិនថូស ១២:១៤ ខគម្ពីរនេះក៏និយាយអំពីតម្រូវការបច្ចុប្បន្ន មិនមែនតម្រូវការអនាគតនោះឡើយ។

ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យអវយវៈនៃរូបកាយរបស់ព្រះគ្រីស្ទធ្វើជាអ្នកផ្គត់ផ្គង់តម្រូវការបន្ទាន់របស់អ្នកជឿដូចគ្នា៖

> ដើម្បីកាលណាគេមានបរិបូរ នោះនឹងបានបំពេញការ ដែលអ្នករាល់គ្នាខ្វះខាតវិញ ប្រយោជន៍ឲ្យបានស្មើគ្នាឡើង ដូចជាសេចក្តីដែលចែងទុកមក

ថា *"អ្នកណាដែលរើសបានច្រើន នោះគ្មានសល់ឡើយ ឯអ្នកដែលរើសបានតិច នោះមិនបានខ្វះទេ"* (២កូរិនថូស ៨:១៤-១៥)។

គ្រីស្ទបរិស័ទណាដែលគិតថា គាត់ត្រូវតែផ្គត់ផ្គង់នូវតម្រូវការនាពេលអនាគត នោះគាត់នឹងត្រូវប្រឈមមុខនឹងបញ្ហាថា តើគាត់មានតម្រូវការប៉ុណ្ណាទើបគ្រប់គ្រាន់សម្រាប់ថ្ងៃអនាគត។ ដូច្នេះ គាត់ចំណាយពេលពេញមួយជីវិត ដើម្បីស្វែងរកលុយដែលគាត់មិនដឹងថាមានប៉ុណ្ណាទើបគ្រប់គ្រាន់ ព្រមទាំងបោះបង់អភ័យឯកសិទ្ធិនៃការថ្វាយអ្វីៗដែលល្អជាងគេរបស់គាត់ដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទចោលចេញ។ នៅពេលដែលជីវិតនៃការប្រមូលទ្រព្យសម្បត្តិទុកសម្រាប់អនាគតដ៏ឥតប្រយោជន៍របស់គាត់ជិតដល់ទីបញ្ចប់ នោះគាត់បានភ្ញាក់ខ្លួនថា ព្រះជាម្ចាស់អាចផ្គត់ផ្គង់តម្រូវការអស់មួយជីវិតរបស់គាត់បានយ៉ាងបរិបូរ បើគាត់គ្រាន់តែរស់នៅសម្រាប់ព្រះសង្គ្រោះយ៉ាងស្មោះអស់ពីចិត្ត តែឥឡូវហួសពេលហើយ។

ប្រសិនបើ គ្រីស្ទបរិស័ទទាំងអស់បានទទួលយកព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូវតាមន័យត្រង់ៗ នោះព័ន្ធកិច្ចរបស់ព្រះជាម្ចាស់នឹងមិនខ្វះខាតថវិកានោះឡើយ ហើយដំណឹងល្អក៏នឹងត្រូវផ្សាយចេញទៅដោយមានអំណាច ហើយក៏នឹងមានមនុស្សជាច្រើនបានឮផង

ដែរ។ ប្រសិនបើ សិស្សណាម្នាក់មានការខ្វះខាត នោះសិស្សផ្សេងទៀតនឹងមានអំណរ ហើយរាប់ការជួយផ្គត់ផ្គង់ដល់សិស្សដែលខ្វះខាតនោះជាអភ័យឯកសិទ្ធិ។

ប្រសិនបើយើងឲ្យយោបល់ថា ត្រូវតែមានគ្រីស្ទបរិស័ទខ្លះជាអ្នកមាន ដើម្បីឈោងចាប់ពួកអ្នកមានដូចគ្នានៃលោកីយ៍នេះ នោះវាជារឿងដែលគួរឲ្យអស់សំណើចណាស់។ សូមចងចាំថា សាវ័ក ប៉ុលបានឈោងចាប់អ្នកនៅក្នុងដំណាក់ស្តេច សេសារ ក្នុងអំឡុងពេលដែលគាត់កំពុងជាប់គុកនៅឡើយ (ភីលីព ៤:២២)។ ប្រសិនបើយើងស្តាប់បង្គាប់ព្រះជាម្ចាស់ យើងអាចជឿទុកចិត្តថា ទ្រង់នឹងរៀបចំអនាគតរបស់យើងបានយ៉ាងល្អិតល្អន់។

គំរូរបស់ព្រះអម្ចាស់យេស៊ូវនៅត្រង់ចំណុចនេះ គួរតែបានបង្ហាញឲ្យយើងឃើញយ៉ាងច្បាស់រួចទៅហើយ។ អ្នកបម្រើមិនលើសជាងចៅហ្វាយរបស់ខ្លួននោះទេ។ លោក ជច ម្យូល័រ (George Müller) បានជឿថា *«វាមិនមែនជារឿងសមរម្យនោះទេ បើអ្នកបម្រើព្រះយេស៊ូវម្នាក់ៗខំស្វះស្វែងដើម្បីក្លាយជាអ្នកមាន ជាអ្នកធំ និងជាអ្នកមានកិត្តិយសនៅលើផែនដី ជាកន្លែងដែលព្រះអម្ចាស់របស់ពួកគេ ធ្លាប់ជាអ្នកក្រីក្រ លំបាកលំបិន ហើយមានគេស្អប់ខ្ពើមនោះ»*។

លោក អែនថូនី នូរីស៍ ហ្គ្រូវស៍ (Anthony Norris Groves) បាន

លើកឡើងថា៖

ការរងទុក្ខរបស់ព្រះគ្រីស្ទ រួមបញ្ចូលទាំងភាពក្រីក្រផងដែរ (២កូរិនថូស ៨:៩)។ ប្រាកដហើយថា ភាពក្រីក្រនេះមិនមែនមានន័យថា យើងត្រូវស្លៀកកន្ទប ហើយរស់នៅ យ៉ាងគគ្រិចនោះទេ ប៉ុន្តែភាពក្រីក្រត្រង់នេះសំដៅទៅលើការមិនយកទ្រព្យសម្បត្តិ និងភាពហ៊ឺហាជាធំ។ លោក អេនឌ្រូ មឺរេយ (Andrew Murray) ក៏បានលើកឡើងដែរថា ព្រះអម្ចាស់ និងសាវ័ករបស់ទ្រង់មិនអាចសម្រេចការងារដែលពួកគេត្រូវធ្វើនោះបានទេ ប្រសិនបើពួកគេមិនមែនជាអ្នកក្រ។ អស់អ្នកណាដែលចង់លើកអ្នកដទៃឡើង ត្រូវតែបន្ទាបខ្លួនឯងជាមុនសិន ដូចដែលព្រះគម្ពីរបានចែងពីសាសន៍សាម៉ារី។ តាំងតែពីដើមរហូតមកដល់សព្វថ្ងៃនេះ មនុស្សច្រើនក្រៃលែងលើលោកីយ៍នេះ គឺសុទ្ធតែជាអ្នកក្រ។[៧]

មនុស្សទូទៅតែងតែទទូចថា យើងចាំបាច់ត្រូវមានទ្រព្យសម្បត្តិខ្លះៗសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃនេះ។ នេះគឺជាការពិតមែន។

មនុស្សតែងតែទទូចថា អ្នកជំនួញដែលជាគ្រីស្ទបរិស័ទត្រូវតែមានដើមទុនមួយចំនួនដើម្បីបន្តអាជីវកម្មរបស់ខ្លួនក្នុងពេលបច្ចុប្បន្ន។ នេះក៏ជាការពិតដែរ។

មនុស្សតែងតែទទូចថា មានទ្រព្យសម្បត្តិផ្សេងៗដូចជាឡាន

ម៉ូតូដែលអាចប្រើសម្រាប់សិរីល្អរបស់ព្រះជាម្ចាស់បាន។ ហើយនោះក៏ជាការពិតដែរ។ ប៉ុន្តែលើសពីតម្រូវការទាំងអស់នេះ គ្រីស្ទបរិស័ទគួរតែរស់នៅចេះសន្សំសំចៃ ហើយលះបង់ទ្រព្យសម្បត្តិនោះដើម្បីដំណឹងល្អវិញ។ បាវចនារបស់គ្រីស្ទបរិស័ទគួរតែដូចលោក អែនថូនី នូរីស៍ ហ្គ្រូវស៍ (Anthony Norris Groves) ដែលគាត់បានលើកឡើងថា *«ចូរខំប្រឹងប្រែងធ្វើការ ចាយវាយតិច ធ្វើទានច្រើន ហើយថ្វាយអ្វីៗទាំងអស់ដល់ព្រះគ្រីស្ទ»*។

ពួកយើងម្នាក់ៗត្រូវតែទទួលខុសត្រូវចំពោះព្រះជាម្ចាស់ទាក់-ទងទៅនឹងការលះអាល័យអ្វីៗទាំងអស់ចោល។ អ្នកជឿម្នាក់មិនអាចបង្កើតច្បាប់ទាក់ទងនឹងការលះអាល័យសម្រាប់នរណាម្នាក់ផ្សេងទៀតបានទេ។ បុគ្គលម្នាក់ៗត្រូវតែសម្រេចចិត្តដោយខ្លួនឯងក្នុងការថ្វាយដល់ព្រះអម្ចាស់។ នេះគឺជាការសម្រេចចិត្តផ្ទាល់ខ្លួន។

ប្រសិនបើ ព្រះអម្ចាស់បានដឹកនាំអ្នកជឿម្នាក់ទៅដល់កម្រិតនៃភក្តីភាពដ៏ខ្ពង់ខ្ពស់ អ្នកជឿនោះមិនគួរអួតពីការនោះឡើយ។ យើងនឹងដឹងថាការលះបង់របស់យើងនៅលោកីយ៍នេះមិនមែនជាការលះបង់ទាល់តែសោះនៅពេលដែលយើងប្រៀបធៀបការលះបង់របស់យើងទៅនឹងយញ្ញបូជារបស់ទ្រង់នៅភ្នំលលាដ៍ក្បាល។ អ្វីដែលយើងថ្វាយដល់ព្រះអម្ចាស់គឺគ្រាន់តែជារបស់ដែលយើងមិន

អាចរក្សាទុកនៅលោកីយ៍នេះ និងជារបស់ដែលយើងលែងស្រឡាញ់ហើយប៉ុណ្ណោះ។

## ជំពូកទី៣

# ឧបសគ្គ
# នៃភាពជាសិស្ស

អស់អ្នកណាដែលចាប់ផ្ដើមដើរតាមព្រះគ្រីស្ទនឹងដឹងច្បាស់ថា ពួកគេនឹងឃើញផ្លូវគេចចេញពីការដើរតាមទ្រង់ជាច្រើន។ ពួកគេនឹងមានឱកាសដើរចេញពីព្រះគ្រីស្ទជាច្រើនដង។ ហើយមានពុំសំឡេងផ្សេងទៀតប្រាប់ពួកគេថា *«យើងចង់ជួយដកលក្ខខណ្ឌខ្លះៗនៃឈើឆ្កាងចេញ»*។ មានទេវតាដប់ពីរកងឈរត្រៀមខ្លួនជាស្រេចចាំរំដោះពួកគេចេញពីការលះកាត់ចិត្តចេញពីខ្លួនឯង និងការពលីជីវិត។

ផ្លូវគេចចេញនេះបង្ហាញយ៉ាងច្បាស់ចេញពីរឿងមនុស្សបីនាក់ដែលប៉ងធ្វើជាសិស្សរបស់ព្រះយេស៊ូវ តែពួកគេបានអនុញ្ញាតឲ្យសំឡេងដទៃមានអាទិភាពជាងការត្រាស់ហៅរបស់ព្រះគ្រីស្ទវិញ។ កាលកំពុងតែទៅតាមផ្លូវនោះមានម្នាក់ទូលទ្រង់ថា ព្រះអម្ចាស់អើយ ទូលបង្គំនឹងតាមទ្រង់ ទោះបើទ្រង់យាងទៅក្នុងទីណាក៏ដោយ ព្រះយេស៊ូវមានព្រះបន្ទូលតបថា កញ្ជ្រោង

មានរូងវា ហើយសត្វហើរលើអាកាសក៏មានសំបុកដែរ តែកូនមនុស្សគ្មានកន្លែងណានឹងកើយក្បាលទេ ទ្រង់មានព្រះបន្ទូលទៅម្នាក់ទៀតថា ចូរមកតាមខ្ញុំ អ្នកនោះទូលឆ្លើយថា ព្រះអម្ចាស់អើយ សូមទ្រង់អនុញ្ញាតឲ្យទូលបង្គំទៅកប់ខ្មោចឪពុកទូលបង្គំសិន តែទ្រង់មានព្រះបន្ទូលទៅអ្នកនោះថា ទុកឲ្យពួកមនុស្សស្លាប់កប់ខ្មោចពួកគេចុះ ឯអ្នក ចូរទៅផ្សាយដំណឹងពីនគរព្រះវិញ មានម្នាក់ទៀតទូលថា ព្រះអម្ចាស់អើយ ទូលបង្គំនឹងតាមទ្រង់ទៅដែរ តែសូមអនុញ្ញាតឲ្យទូលបង្គំទៅលាពួកផ្ទះទូលបង្គំសិន ទ្រង់មានព្រះបន្ទូលទៅអ្នកនោះថា អ្នកណាដែលដាក់ដៃកាន់នង្គ័ល ហើយងាកបែរទៅមើលក្រោយ អ្នកនោះមិនគួរនឹងនគរព្រះទេ (លូកា ៩:៥៧-៦២)។

មានបុរសបីនាក់បានមកជួបព្រះយេស៊ូវគ្រីស្ទដោយផ្ទាល់ តែអ្នកនិពន្ធកណ្ឌគម្ពីរលូកាមិនបានប្រាប់ឈ្មោះពួកគេទេ។ ពួកគេមានគំនាបសង្កត់នៅក្នុងចិត្តក្នុងការដើរតាមទ្រង់។ ប៉ុន្តែពួកគេបានអនុញ្ញាតឲ្យរឿងផ្សេងទៀតចូលមកជ្រៀតជ្រែកព្រលឹងរបស់ខ្លួន និងការថ្វាយខ្លួនទាំងស្រុងចំពោះទ្រង់។

## បុរសផ្ដេកបន្ទោរ

បុរសដំបូង យើងអាចឲ្យឈ្មោះថាបុរសផ្ដេកបន្ទោរ។ គាត់ស្ម័គ្រចិត្តយ៉ាងអន្ទះអន្ទែងក្នុងការដើរតាមព្រះអម្ចាស់ទៅគ្រប់ទីកន្លែង។

គាត់បានមានប្រសាសន៍ថា *«ព្រះអម្ចាស់អើយ ទូលបង្គំនឹងតាមទ្រង់ ទោះបើទ្រង់យាងទៅក្នុងទីណាក៏ដោយ»*។ មើលទៅដូចជាគ្មានតម្លៃអ្វីដែលថ្លៃពេកសម្រាប់គាត់នោះសោះ ហើយគ្មានឈើឆ្កាងណាដែលធ្ងន់ពេកនោះទេ ហើយក៏គ្មានផ្លូវណាដែលរលាក់ពេកនោះដែរ។

ចម្លើយរបស់ព្រះសង្គ្រោះ ពីដំបូងហាក់បីដូចជាមិនមានភាពស៊ីគ្នាជាមួយនឹងការស្ម័គ្រចិត្តរបស់បុរសឆ្លេកបន្ទោរសោះ។ ព្រះយេស៊ូវមានបន្ទូលថា៖ *«កញ្ជ្រោងមានរូងវា ហើយសត្វហើរលើអាកាសក៏មានសំបុកដែរ តែកូនមនុស្សគ្មានកន្លែងណានឹងកើយក្បាលទេ»*។ តាមពិតទៅ ចម្លើយរបស់ព្រះអម្ចាស់នៅត្រង់នេះមានភាពស័ក្តិសមណាស់។ ទ្រង់ហាក់បីដូចជាមានបន្ទូលថា៖ *«លោកបានអះអាងថានឹងតាមខ្ញុំទៅគ្រប់ទីកន្លែង ប៉ុន្តែតើលោកហ៊ានលះ-បង់សម្ភារៈកម្សាន្តចិត្តក្នុងជីវិតរបស់លោកដែរឬទេ? សត្វកញ្ជ្រោងរស់នៅលោកីយ៍នេះស្រួលជាងខ្ញុំទៅទៀត។ ហើយសត្វស្លាបមានសម្បុកផ្ទាល់ខ្លួនរបស់វា ប៉ុន្តែឯខ្ញុំវិញ ជាអ្នកត្រាច់ចរក្នុងលោកីយ៍ដែលខ្ញុំបានបង្កើតនេះ ខ្ញុំគ្មានទីលំនៅពិតប្រាកដឡើយ។ តើលោកតាំងចិត្តនឹងលះបង់ផ្ទះសំបែងដ៏សុខសាន្ត ដើម្បីតាមខ្ញុំមែនអ៎? តើលោកតាំងចិត្តចាកចោលភាពស្រណុកសុខស្រួលនៃជីវិតលោកដើម្បីបម្រើខ្ញុំអស់ពីចិត្តមែនឬ?»*។

មើលទៅ ទំនងជាគាត់នោះមិនបានតាំងចិត្តសោះ ពីព្រោះយើងមិនបានឮអ្វីផ្សេងទៀតអំពីគាត់នៅក្នុងព្រះគម្ពីរទេ។ គាត់ស្រឡាញ់ភាពស្រណុកសុខស្រួលនៅលោកីយ៍នេះជាជាងការប្ដេជ្ញាចិត្តដើរតាមព្រះគ្រីស្ទទៅទៀត។

## បុរសមើកៗ

បុរសទីពីរ យើងអាចឲ្យឈ្មោះថា**បុរសមើកៗ**។ គាត់មិនបានស្ម័គ្រចិត្តដូចបុរសទីមួយទេ ក៏ប៉ុន្តែព្រះសង្គ្រោះបានហៅគាត់ឲ្យតាមទ្រង់វិញ។ ចម្លើយរបស់គាត់មិនបានប្រកែកទាំងស្រុងនោះទេ។ នេះមិនមែនមានន័យថា គាត់មិនចាប់អារម្មណ៍នឹងដើរតាមព្រះអម្ចាស់ទាល់តែសោះនោះទេ ក៏ប៉ុន្តែមានការមួយដែលគាត់ចង់ធ្វើជាមុនសិន។ ហើយការនោះគឺជាអំពើបាបដ៏ធំរបស់គាត់។ គាត់បានឲ្យអាទិភាពលើការអះអាងរបស់គាត់ខ្ពស់ជាងការអះ-អាងរបស់ព្រះគ្រីស្ទទៅទៀត។ សូមកត់សម្គាល់ចម្លើយរបស់គាត់៖ *“ព្រះអម្ចាស់អើយ សូមទ្រង់អនុញ្ញាតឲ្យទូលបង្គំទៅកប់ខ្មោចឪពុកទូលបង្គំសិន”*។ ការដែលកូនត្រូវគោរពឪពុកម្ដាយ គឺជាការស័ក្ដិសមណាស់។ ប្រសិនបើឪពុករបស់គ្រីស្ទបរិស័ទម្នាក់បានបាត់បង់ជីវិតនោះការរៀបចំបញ្ចុះសពឪពុកឲ្យបានត្រឹមត្រូវតាមរបៀបគ្រីស្ទបរិស័ទ

មិនមែនជារឿងដែលខុសទេ។ ប៉ុន្តែការដែលគួរសមដ៏ពេញមុខពេញមាត់ក្នុងជីវិតនោះនឹងក្លាយទៅជាអំពើបាបយ៉ាងជាក់ស្តែង នៅពេលដែលការទាំងនោះដណ្តើមយកអាទិភាពចម្បងនៃបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់យេស៊ូវ។ ភាពលោភលន់ដ៏ពិតរបស់បុរសម្នាក់នេះ ក៏បានបង្ហាញចេញតាមរយៈសំណូមពរដ៏ត្រង់ៗរបស់គាត់ដូចនេះថា៖ *«ព្រះអម្ចាស់អើយ...ទូលបង្គំ...សិន»*។ ពាក្យពេចន៍ផ្សេងទៀតដែលគាត់បាននិយាយ គ្រាន់តែជាពាក្យដើម្បីបិទបាំងនូវបំណងប្រាថ្នាដែលទុកខ្លួនឯងសំខាន់ជាងអ្វីៗផ្សេងទៀត។

វាហាក់បីដូចជាគាត់មិនដឹងខ្លួនសោះពេលគាត់ថា *«ព្រះអម្ចាស់អើយ... ទូលបង្គំ...សិន»*។ ពាក្យដូចនេះជាពាក្យផ្ទុសផ្តាសខុសនឹងសីលធម៌ ហើយមិនអាចទៅរួចនោះទេ។ ប្រសិនបើព្រះគ្រីស្ទពិតជាព្រះអម្ចាស់មែន នោះទ្រង់ត្រូវមានអាទិភាពចម្បងក្នុងជីវិតយើង។ ប្រសិនបើសព្វនាមបុរិសៈ «ខ្ញុំ» នៅលើរាជបល្ល័ង្គ នោះមានន័យថា យើងលែងឲ្យព្រះគ្រីស្ទកាន់កាប់អំណាចលើយើងទៀតហើយ។

បុរសមើកៗ មានការងារដែលគាត់ត្រូវធ្វើ ហើយទុកអាទិភាពការងារនេះជាចម្បង។ ដូច្នេះ វាស័ក្តិសមណាស់ដែលព្រះយេស៊ូវមានបន្ទូលទៅកាន់គាត់ថា៖ *«ទុកឲ្យពួកមនុស្សស្លាប់កប់ខ្មោចពួកគេចុះ ឯអ្នក ចូរទៅផ្សាយដំណឹងពីនគរព្រះវិញ»* យើងអាចពន្យល់ពាក្យ

របស់ទ្រង់ដូចនេះថា៖ *«មានការខ្លះ មនុស្សដែលស្លាប់ខាងវិញ្ញាណក៏អាចធ្វើបានដូចអ្នកជឿផងដែរ។ ប៉ុន្តែមានការខ្លះទៀត មានតែអ្នកជឿទេដែលអាចធ្វើបាន។ ត្រូវដឹងថា លោកមិនចាំបាច់ចំណាយជីវិតរបស់ខ្លួន ដើម្បីធ្វើការដែលអ្នកមិនជឿអាចធ្វើបាននោះទេ។ ចូរទុកឲ្យមនុស្សដែលស្លាប់ខាងវិញ្ញាណកប់សពខាងឯសាច់ឈាមគេទៅចុះ។ ប៉ុន្តែចំពោះលោកផ្ទាល់ ចូរធ្វើជាអ្នកផ្តល់ប្រយោជន៍សម្រាប់ខ្ញុំវិញ។ ចូរយកបុព្វហេតុរបស់ខ្ញុំទុកជាគោលបំណងចម្បងរបស់លោកចុះ ដើម្បីឲ្យនគរខ្ញុំបានរីកចម្រើនឡើងនៅលើផែនដីនេះ»*។

មើលទៅ ការដើរតាមព្រះយេស៊ូវហាក់បីដូចជាថ្លៃហួសហេតុពេកសម្រាប់បុរសមើកៗ។ តាំងពីពេលនោះមក គាត់បានបាត់មុខពីឆាកនៃប្រវត្តិសាស្រ្តសូន្យឈឹង។

ប្រសិនបើបុរសទីមួយជាឧទាហរណ៍ដែលបង្ហាញថា សម្ភារៈកម្សាន្តចិត្តជាឧបសគ្គក្នុងការធ្វើជាសិស្សរបស់ព្រះយេស៊ូវ នោះយើងក៏អាចនិយាយដែរថា បុរសទីពីរបានឲ្យអាទិភាពខ្ពស់ទៅលើការងារជាងការធ្វើជាគ្រីស្ទបរិស័ទ។

បើលោកអ្នកមានការងារធ្វើ នោះមិនមែនជាការខុសឆ្គងទេ ព្រោះព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺចង់ឲ្យយើងធ្វើការ ដើម្បីផ្គត់ផ្គង់តម្រូវការរបស់ខ្លួននិងគ្រួសារ។ ប៉ុន្តែ ជីវិតនៃភាពជាសិស្សដ៏ពិត

ទាមទារការស្វែងរកនគររបស់ព្រះជាម្ចាស់ និងសេចក្ដីសុចរិតរបស់ទ្រង់ជាអាទិភាពចម្បងបំផុត។ ហើយជីវិតនៃភាពជាសិស្សក៏ទាមទារឲ្យអ្នកជឿកុំចំណាយជីវិតរបស់ខ្លួនក្នុងការធ្វើអ្វីដែលអ្នកមិនជឿអាចធ្វើបានដូចគ្នា ឬក៏ល្អជាងទៅទៀតនោះឡើយ។ ដូចគ្នានេះដែរ មូលហេតុនៃការធ្វើការងារគឺគ្រាន់តែដើម្បីផ្គត់ផ្គង់តម្រូវការនាពេលបច្ចុប្បន្នប៉ុណ្ណោះ។ ឯការងារដ៏ចម្បងបំផុតរបស់គ្រីស្ទបរិស័ទគឺការផ្សាយពីនគររបស់ព្រះជាម្ចាស់។

## បុរសគិតងាយ

បុរសទីបី យើងអាចឲ្យឈ្មោះថាបុរសគិតងាយ។ គាត់ស្រ-ដៀងនឹងបុរសទីមួយដែរ ដោយសារគាត់បានស្ម័គ្រចិត្តដើរតាមព្រះអម្ចាស់។ ប៉ុន្តែគាត់ក៏ដូចជាបុរសទីពីរដែរ ដោយសារគាត់ប្រើពាក្យមិនគួរសមដូចគ្នា៖ *«ព្រះអម្ចាស់អើយ...ទូលបង្គំ...សិន»*។ *គាត់ទូលថា «ព្រះអម្ចាស់អើយ ទូលបង្គំនឹងតាមទ្រង់ទៅដែរតែសូមអនុញ្ញាតឲ្យទូលបង្គំទៅលាពួកផ្ទះទូលបង្គំសិន»*។

ជាថ្មីម្ដងទៀត យើងត្រូវតែទទួលស្គាល់ថា បើគ្រាន់តែស្ដាប់សំណើដែលគាត់លើកឡើង វាដូចជាគ្មានអ្វីខុសនោះទេ។ វាក៏មិនមែនប្រឆាំងនឹងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់នោះដែរ ក្នុងការ

ដែលយើងបង្ហាញសេចក្តីស្រឡាញ់ជាមួយនឹងសាច់ញាតិ ឬក៏តាមក្រមសីលធម៌នៅពេលដែលយើងលាពួកគេ។ តើចំណុចណាដែលបណ្តាលឲ្យបុរសម្នាក់នេះមិនបានជោគជ័យលើការសាកល្បងនេះ? វាស្ថិតនៅត្រង់ចំណុចដែលគាត់បានបណ្តោយឲ្យទំនាក់ទំនងរបស់គាត់ជាមួយគ្រួសារចូលមកជំនួសព្រះគ្រីស្ទ។

ដូច្នេះ ព្រះយេស៊ូវបានមានបន្ទូលដោយយោគយល់ត្រង់ៗថា៖ *«អ្នកណាដែលដាក់ដៃកាន់នង្គ័លហើយងាកបែរទៅមើលក្រោយ អ្នកនោះមិនគួរនឹងនគរព្រះទេ»* ត្រង់នេះទ្រង់ចង់មានន័យថា៖ *«សិស្សរបស់ខ្ញុំមិនគួរគិតតែពីខ្លួនឯង ហើយមិនចេះសម្រេចចិត្តដោយខ្លួនឯង។ ខ្ញុំចង់បានសិស្សដែលមានឆន្ទៈលះបង់ចំណង់ផ្ទាល់ខ្លួន ហើយមិនបែកអារម្មណ៍ដោយសារសាច់ញាតិដែលមានមនោសញ្ចេតនានឹងគ្នា។ ហើយខ្ញុំចង់បានសិស្សដែលទុកខ្ញុំខ្ពស់ជាងគេបំផុតក្នុងជីវិត»*។

យើងសន្និដ្ឋានថា បុរសគិតងាយបានចាកចោលព្រះយេស៊ូវ ហើយបានដើរចេញទៅដោយមុខស្រងូតស្រងាត់។ សេចក្តីប្រាថ្នាក្នុងការក្លាយជាសិស្សដ៏លើសលប់របស់គាត់បានបែកខ្ញាយ ដោយសារចំណងនៅក្នុងគ្រួសារគាត់ ប្រៀបបាននឹងកែវបោកផ្ទប់នឹងផ្ទាំងសិលាយ៉ាងដូច្នោះដែរ។ យើងមិនដឹងច្បាស់ថាយ៉ាងណានោះទេ

ប្រហែលជាគាត់មានម្ដាយដែលកំពុងយំខ្សឹកខ្សួលថា *«កូនអើយ! កូននឹងធ្វើឲ្យម្ដាយគ្រាំគ្រាចិត្តស្លាប់បើកូនចាកចោលម្ដាយ ហើយទៅបម្រើបេសកកម្មរបស់ព្រះយេស៊ូវនៅប្រទេសផ្សេងទៀតនោះ»*។ អ្វីដែលយើងដឹងគឺត្រង់ថា ព្រះជាម្ចាស់មានសមានចិត្តក្នុងការមិនឲ្យយើងស្គាល់ឈ្មោះរបស់បុរសដ៏ទន់ខ្សោយខាងឯព្រលឹងវិញ្ញាណម្នាក់នេះ។ គាត់បានបាត់ឱកាសដ៏ធំក្រៃលែងក្នុងជីវិតដោយសារតែការបែរចេញពីព្រះយេស៊ូវ ហើយគាត់សមនឹងទទួលងារចុងក្រោយថា *«មិនគួរនឹងនគរព្រះទេ»*។

## ការសង្ខេប

រឿងទាំងនេះបង្ហាញពីឧបសគ្គដ៏ចម្បងបីយ៉ាងដែលរារាំងបុគ្គលម្នាក់មិនឲ្យធ្វើជាសិស្សរបស់ព្រះយេស៊ូវ។ តាមរយៈបុរសទាំងបីនាក់នេះ យើងឃើញថា ពួកគាត់មិនមានឆន្ទៈមុតមាំក្នុងការដើរតាមព្រះយេស៊ូវទេ។

**បុរសផ្ដេកបន្ទោរ** — ស្រឡាញ់ភាពស្រណុកសុខស្រួលខាងឯលោកីយ៍។

**បុរសមើកៗ** — ឲ្យអាទិភាពចម្បងទៅលើការងារ។

**បុរសគិតងាយ** — ឲ្យអាទិភាពចម្បងទៅលើទំនាក់ទំនង
ជាមួយគ្រួសារ។

ព្រះអម្ចាស់យេស៊ូវនៅតែត្រាស់ហៅបុរស និងស្ត្រីសព្វថ្ងៃនេះ ឲ្យតាមទ្រង់យ៉ាងអង់អាចក្លាហាន ហើយហ៊ានលះបង់អ្វីៗគ្រប់យ៉ាងដូចដែលទ្រង់ធ្លាប់បានត្រាស់ហៅជាយូរមកហើយដែរ។ ផ្លូវគេចចេញនៅតែមានដដែល ហើយតែងតែបន្លឺសំឡេងឡើងថា «ចូរជួយខ្លួនឯងទៅ! ហើយគេចចេញពីផ្លូវរបស់ព្រះយេស៊ូវទៅ!» មានមនុស្សតិចណាស់ដែលមានឆន្ទៈឆ្លើយតបទៅនឹងការត្រាស់ហៅរបស់ទ្រង់ដូចទៅនឹងកំណាព្យខាងក្រោមនេះ៖

ព្រះយេស៊ូវអើយ ខ្ញុំបានលីឈើឆ្កាងរួចហើយ
មិននៅកន្តើយ លះបង់តាមទ្រង់លុះមរណា
ទោះបីអាក្រាត ក្រកី គួរស្អប់ រស់ឯកា
អ្វីខ្ញុំត្រូវការ គឺទ្រង់ចាប់ពីពេលនេះទៅ។
សូមទ្រង់កំចាត់ មហិច្ឆតានៃទូលបង្គំ
អ្វីដែលខ្ញុំខំ ប៉ងប្រាថ្នាសង្ឃឹមនិងស្គាល់
ទោះបីខ្ញុំមាន ទ្រព្យធនហូរហៀរមិនចេះទ័ល
សូមឲ្យខ្ញុំស្គាល់ ព្រះអង្គដែលជាម្ចាស់សួគ៌ា។

សូមឲ្យលោកាចាកចោលទៅណាពីទូលបង្គំ
ដូចគេចោលទ្រង់ព្រះសង្គ្រោះ
ដួងចិត្តរូបកាយបញ្ឆោតមិនលោះ
ទ្រង់មិនមានពុតសោះ ដូចគេឯងឡើយ។
សូមទ្រង់បែរមកញញឹមរកទូលបង្គំ
ព្រះមានក្តីស្រឡាញ់ ចេស្តា និងប្រាជ្ញា។
ទោះមារសត្រូវមិត្រភក្តិនោះនៅស្អប់ទូលបង្គំ
សូមបង្ហាញព្រះភក្ត្រព្រះអង្គឲ្យភ្លឺចាំងចែង។

— លោក អេឆ. អេហ្វ. ឡៃថ៍
(H. F. Lyte )

## ជំពូកទី៤

# សិស្សគឺជាអ្នកមើលខុសត្រូវ

នៅក្នុងកណ្ឌគម្ពីរ លូកា ១៦:១-១៣ ព្រះយេស៊ូវបានមានបន្ទូលប្រាប់រឿងអំពីអ្នកត្រួតត្រាទុច្ចរិតដល់សិស្សរបស់ទ្រង់។ នៅក្នុងរឿងនេះ ព្រះសង្គ្រោះបានដាក់ចេញនូវគោលការណ៍ដែលត្រូវនឹងជីវិតរបស់សិស្សគ្រប់សម័យកាល ក៏ព្រោះតែសិស្សរបស់ព្រះគ្រីស្ទប្រៀបដូចទៅនឹងអ្នកមើលខុសត្រូវ ដោយទ្រង់បានប្រទានឲ្យពួកគេថែរក្សាទ្រព្យសម្បត្តិរបស់ទ្រង់ ក៏ដូចជាអ្វីៗដែលទ្រង់យកចិត្តទុកដាក់លើផែនដីនេះផងដែរ។

រឿងដែលព្រះយេស៊ូវប្រាប់មើលទៅដូចជាមានការខុសឆ្គងជាច្រើន ហើយពិបាកនឹងយល់។ បើគ្រាន់តែមើលត្រួសៗ រឿងនេះហាក់បីដូចជាឲ្យតម្លៃខ្ពស់ទៅលើមនុស្សមានចិត្តមុសា និងវៀចវេរ។ ប៉ុន្តែនៅពេលដែលយើងយល់រឿងនេះឲ្យចំបរិបទ នោះយើងនឹង

ឃើញថា វាមានផ្ទុកនូវសេចក្ដីបង្រៀនដ៏សំខាន់ៗជាច្រើន។

សរុបមក រឿងនេះមានអ្នកមានស្ដុកស្ដម្ភម្នាក់បានជួលខ្ញុំបម្រើម្នាក់ឲ្យមកមើលការខុសត្រូវមុខជំនួញរបស់គាត់។ មួយរយៈកាលកន្លងទៅ ចៅហ្វាយបានឃើញថា ខ្ញុំបម្រើម្នាក់នោះបានចាយវាយទ្រព្យសម្បត្តិរបស់គាត់យ៉ាងខ្ជះខ្ជាយ។ ភ្លាមៗនោះគាត់ក៏ទាមទារឲ្យមានការត្រួតពិនិត្យបញ្ជី ហើយគាត់ក៏បានបណ្ដេញខ្ញុំបម្រើនោះឲ្យឈប់ពីការងារតែម្ដង។

ខ្ញុំបម្រើនោះបានភ្ញាក់ខ្លួនថា អនាគតរបស់គាត់ត្រូវរលាយសាបសូន្យហើយ។ គាត់ក៏មានវ័យចាស់ណាស់ទៅហើយក្នុងការធ្វើការងារដោយប្រើកម្លាំងពលកម្ម ហើយគាត់មានការអៀនខ្មាសក្នុងការសុំទានគេដែរ។ ដូច្នេះគាត់ក៏បានរៀបចំគម្រោងមួយ ដើម្បីឲ្យគាត់អាចនឹងមានមិត្តភក្ដិច្រើននៅពេលខាងមុខ។ គាត់បានទៅជួបអ្នកជំពាក់បំណុលចៅហ្វាយរបស់គាត់ម្នាក់ហើយសួរថា៖ *«តើអ្នកជំពាក់បំណុលចៅហ្វាយខ្ញុំប៉ុន្មាន?»* អ្នកនោះឆ្លើយថា៖ *«ខ្ញុំជំពាក់ប្រេងគាត់ចំនួន២៨៣៩លីត្រ»*។ ខ្ញុំបម្រើនោះនិយាយឡើងថា៖ *«អើបង់ឲ្យខ្ញុំពាក់កណ្ដាលមករួចគ្នាហើយ»*។ គាត់បានបន្តទៅជួបអ្នកជំពាក់បំណុលចៅហ្វាយរបស់គាត់ផ្សេងទៀត ហើយសួរថា៖ *«តើអ្នកជំពាក់ប៉ុន្មាន?»* អ្នកនោះតបវិញថា៖ *«ស្រូវ៨០០ថាំង»*។ ខ្ញុំបម្រើ

នោះនិយាយឡើងថា៖ *«អើ អញ្ចឹងបង់ឲ្យខ្ញុំតែ៦៤០ថាំង ហើយខ្ញុំនឹងលុបបំណុលនេះចោល»*។

ពាក្យសម្ដីខាងក្រោមនេះ គឺវារឹតតែធ្វើឲ្យយើងរន្ធត់ជាងសកម្មភាពរបស់ខ្ញុំបម្រើមិលគុណម្នាក់នេះទៅទៀត៖

> *ចៅហ្វាយ ក៏សរសើរអ្នកត្រួតត្រាទុច្ចរិតនោះ ពីព្រោះគាត់បានប្រព្រឹត្តដោយឆ្លៀវឆ្លាត ដ្បិតមនុស្សរបស់ផងលោកីយ៍នេះ គេមានប្រាជ្ញាចំពោះជំនាន់គេ ជាជាងមនុស្សរបស់ផងពន្លឺទៅទៀត* (លូកា ១៦:៨)។

តើយើងគួរនឹងគិតយ៉ាងណាចំពោះការដែលមើលទៅដូចជាព្រះជាម្ចាស់ក៏ទទួលយល់ព្រមទៅនឹងគំនិតដ៏ទុច្ចរិតនេះនោះ? រឿងជាក់ស្ដែងមួយគឺត្រង់ថា ទាំងចៅហ្វាយរបស់គាត់ និងព្រះជាម្ចាស់របស់យើងមិនបានសរសើរភាពពុតត្បុតនោះទេ។ ផ្ទុយទៅវិញ មកពីរឿងនេះហើយដែលបណ្ដាលឲ្យចៅហ្វាយដេញគាត់ចេញ។ មនុស្សសុចរិតមិនគាំទ្រចំពោះទង្វើបោកប្រាស់ និងភាពមិនស្មោះត្រង់ដូចនេះឡើយ។ ទោះបីសាច់រឿងនេះបង្រៀនពីអ្វីផ្សេងទៀតក៏ដោយ ក៏វាមិនបានស្នើឲ្យយើងយល់ថា ការបន្លំលួចជារឿងដែលត្រឹមត្រូវនោះទេ។

មានតែការមួយប៉ុណ្ណោះដែលអ្នកត្រួតត្រាទុច្ចរិតនេះអាចនឹង

ទទួលការសរសើរបាន គឺត្រង់ថាគាត់បានរៀបគម្រោងសម្រាប់ពេលអនាគត។ គាត់បានរៀបចំផែនការដើម្បីឲ្យដឹងច្បាស់ថា គាត់នៅតែមានមិត្តភក្តិបន្ទាប់ពីគាត់បាត់បង់តំណែងជាអ្នកត្រួតត្រានោះ។ គាត់បានត្រៀមទុកសម្រាប់អនាគតជាជាងបច្ចុប្បន្ន។

នេះហើយគឺជាខ្លឹមសារនៃរឿងនេះ។ មនុស្សក្នុងលោកីយ៍នេះខំប្រឹងព្យាយាមជាខ្លាំង ដើម្បីផ្គត់ផ្គង់សម្រាប់ថ្ងៃខាងមុខ។ ហើយអនាគតដែលពួកគេមានការព្រួយបារម្ភគឺពេលពួកគេមានវ័យចាស់ និងពេលដែលពួកគេចូលនិវត្តន៍។ ដូច្នេះហើយបានជាពួកគេខិតខំធ្វើការយ៉ាងយកចិត្តទុកដាក់ ដើម្បីឲ្យពួកគេអាចរស់នៅយ៉ាងសុខស្រួលនៅពេលដែលពួកគេមិនមានលទ្ធភាពធ្វើការចិញ្ចឹមជីវិតបាន។ ពួកគេបានខំស្វែងរកគ្រប់វិធី ដើម្បីធ្វើយ៉ាងណាឲ្យតែបានសេចក្តីសុខ។

ត្រង់ចំណុចនេះ អ្នកមិនជឿឆ្លាតជាងគ្រីស្ទបរិស័ទទៅទៀត។ ទោះជាយ៉ាងនេះក្តី ដើម្បីឲ្យយើងយល់ពីមូលហេតុដែលអ្នកមិនជឿឆ្លាតជាងគ្រីស្ទបរិស័ទបាន យើងត្រូវដឹងឲ្យច្បាស់ថា អនាគតរបស់គ្រីស្ទបរិស័ទមិនមែននៅលើផែនដីនេះទេ ប៉ុន្តែគឺនៅឯស្ថានសួគ៌ឯនោះវិញទេ។ នេះហើយជាចំណុចស្នូលរបស់វា។ អនាគតរបស់អ្នកមិនជឿ គឺគិតចាប់ពីចន្លោះនៃពេលវេលានាពេលបច្ចុប្បន្ន និង

ពេលដែលចូលក្នុងមឈូស។ អនាគតបុត្រាបុត្រីរបស់ព្រះជាម្ចាស់គឺសំដៅលើការរស់នៅអស់កល្បជានិច្ចជាមួយព្រះគ្រីស្ទ។

ដូច្នេះ រឿងនេះបង្រៀនយើងឲ្យដឹងថា មនុស្សដែលមិនទាន់បានកើតជាថ្មីជាច្រើនមានភាពឆ្លាតវៃ ហើយស្វះស្វែងក្នុងការរៀបចំអនាគតនៅលើផែនដីនេះខ្លាំងជាងគ្រីស្ទបរិស័ទរៀបចំអនាគតរបស់ពួកគេនៅឯស្ថានសួគ៌ទៅទៀត។

ក្រោយពីព្រះយេស៊ូវបានលើកឡើងពីរឿងនេះមក ទ្រង់បានបង្ហាញនូវការអនុវត្តជាក់ស្តែង៖

*ខ្ញុំក៏ប្រាប់អ្នករាល់គ្នាថា ចូរប្រើទ្រព្យសម្បត្តិលោកីយ៍នេះ ឲ្យបានមិត្តសំឡាញ់ដល់ខ្លួន ដើម្បីកាលណាអ្នករាល់គ្នាខាននៅ នោះនឹងមានគេទទួលអ្នករាល់គ្នាឲ្យនៅក្នុងទីលំនៅដ៏ស្ថិតស្ថេរអស់កល្បជានិច្ចវិញ* (លូកា ១៦:៩)។

ទ្រព្យសម្បត្តិលោកីយ៍នេះ គឺជាលុយ ឬកម្មសិទ្ធិលើរបស់របរសព្វសារពើ។ យើងអាចប្រើរបស់ទាំងនេះ ដើម្បីនាំមនុស្សទាំងឡាយឲ្យមានជំនឿលើព្រះគ្រីស្ទ។  អ្នកដែលបានទទួលជឿព្រះគ្រីស្ទតាមរយៈការប្រើប្រាស់លុយដ៏ស្មោះត្រង់របស់យើងនេះហៅថា «*មិត្តសម្លាញ់*»។

ថ្ងៃដែលយើងលែងបាននៅផែនដីនេះនឹងមកដល់ជាមិនខាន

(មិនថាតាមរយៈសេចក្តីស្លាប់ ឬតាមការដែលព្រះគ្រីស្ទយាងមកយកយើងទៅឯស្ថានសួគ៌នៅគ្រាឆក់យក ១ថែស្សាឡូនីច ៤:១៧)។ មិត្តសម្លាញ់ដែលបានទទួលជឿដោយសារយើងប្រើប្រាស់របស់សព្វសារពើ ក្នុងការផ្សាយដំណឹងល្អដល់គាត់ នោះនឹងក្លាយទៅជាអ្នកចាំទទួលស្វាគមន៍យើងនៅពេលដែលយើងចូលទៅកាន់ដំណាក់ដ៏អស់កល្បជានិច្ចនៅឯស្ថានសួគ៌។

នេះហើយគឺជាមធ្យោបាយដែលអ្នកមើលខុសត្រូវដ៏ឆ្លាតវៃត្រូវរៀបគម្រោងរបស់ខ្លួនសម្រាប់អនាគត មិនមែនដោយការចំណាយជីវិតរបស់ខ្លួនក្នុងការស្វែងរកភាពសុខសាន្តក្នុងលោកីយ៍នេះដោយឥតប្រយោជន៍នោះទេ។ តែពួកគេបានរៀបចំដោយការប្តេជ្ញាថានឹងមានមិត្តសម្លាញ់ចាំទទួលស្វាគមន៍ខ្លួននៅឯស្ថានសួគ៌ជាអ្នកដែលពួកគេបាននាំឲ្យជឿព្រះគ្រីស្ទតាមរយៈលុយដែលពួកគេបានចំណាយទិញដូចជា ព្រះគម្ពីរ ព្រះគម្ពីរសញ្ញាថ្មី កូនសៀវភៅខគម្ពីរខិត្តប័ណ្ណ និងឯកសារគ្រីស្ទបរិស័ទផ្សេងទៀត ក៏ដូចជា លុយដែលពួកគេប្រើសម្រាប់ទំនុកបម្រុងបេសកជន និងអ្នកធ្វើការជាគ្រីស្ទបរិស័ទផ្សេងទៀត។ ជាលុយដែលពួកគេប្រើសម្រាប់ជួយផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុដល់កម្មវិធីវិទ្យុគ្រីស្ទបរិស័ទ និងសកម្មភាពដ៏មានសារប្រយោជន៍ផ្សេងៗទៀតជាច្រើន។ សរុបមក គឺជាលុយដែល

ពួកគេប្រើសម្រាប់ការផ្សព្វផ្សាយដំណឹងល្អតាមគ្រប់មធ្យោបាយសព្វបែបយ៉ាង។ «*មធ្យោបាយតែមួយគត់ដែលអាចឲ្យយើងប្រមូលទ្រព្យសម្បត្តិរបស់យើងនៅស្ថានសួគ៌បាន គឺយើងត្រូវវិនិយោគលុយនោះក្នុងអ្វីដែលអាចចូលទៅស្ថានសួគ៌បាន*»។

នៅពេលដែលគ្រីស្ទបរិស័ទឃើញថា កម្មសិទ្ធិលើរបស់របរសព្វសារពើរបស់ពួកគេអាចនឹងប្រើក្នុងការសង្គ្រោះមនុស្សជាច្រើន នោះពួកគេនឹងបាត់បង់នូវអារម្មណ៍ស្រឡាញ់ដល់របស់របរទាំងអស់នោះដោយឯកឯង។ ភាពហ៊ឺហា ទ្រព្យសម្បត្តិ និងសម្ភារៈប្រណីតៗប្រៀបបានទៅនឹងម្ហូបដែលជូរផ្អូមនៅក្នុងពោះរបស់ពួកគេយ៉ាងដូច្នោះដែរ។ ពួកគេអន្ទះសាចង់ឃើញព្រះជាម្ចាស់ប្រើប្រាស់ទ្រព្យសម្បត្តិលោកីយ៍នេះ ដើម្បីនាំមនុស្សជាច្រើនក្លាយទៅជាអ្នកថ្វាយបង្គំព្រះគ្រីស្ទរៀងរហូត។ ពួកគេជាប់ជំពាក់ក្នុងការជួយមនុស្ស ដើម្បីថ្វាយសិរីល្អដល់ព្រះជាម្ចាស់ ព្រមទាំងផ្តល់ពរដ៏អស់កល្បដល់អស់អ្នកដែលពួកគេបានជួយនោះ។ ចិត្តថ្លើមនៃការទន្ទឹងរង់ចាំរបស់ពួកគេប្រហាក់ប្រហែលនឹងចិត្តថ្លើមរបស់លោក សាំយ៉ូអែល រ៉ីទីហ្វត (Samuel Rutherford) ដែលជាគ្រូអធិប្បាយជនជាតិស្កុតឡែន (Scotland) នៅក្នុងទសវត្សរ៍ទី១៦ នៅក្រុងអែនវ៉ោធ (Anwo'th)៖

*ឱ! បើមានមនុស្សណាមកពីក្រុងអែនវ៉ោធ*

*បានមកជួបខ្ញុំនៅព្រះហស្តាទ្រង់ខាងស្តាំ*
*នោះស្ថានសួគ៌នៃខ្ញុំនឹងទ្វេជាពីរ*
*នៅក្នុងទឹកដីទីអេម៉ាញូអែល។*

— លោកស្រី អាន រ៉ស ខឹស៊ីន
(Anne Ross Cousin)

អស់ទាំងមាសពេជ្រកែវកង និងលុយតម្កល់ក្នុងធនាគារ ប័ណ្ណធានារ៉ាប់រង ផ្ទះវីឡា និងនាវាសម្រាប់ជិះលេងកម្សាន្ត ព្រមទាំងឡានថ្លៃៗ ចំពោះគ្រីស្ទបរិស័ទនោះគ្រាន់តែជាទ្រព្យសម្បត្តិលោកីយ៍ដែលបោកបញ្ឆោតចិត្តប៉ុណ្ណោះ។ បើគ្រាន់តែប្រើសម្រាប់រូបកាយ វានឹងរលាយសាបសូន្យទៅ ប៉ុន្តែបើប្រើសម្រាប់ព្រះគ្រីស្ទវិញ វានឹងរីកដុះដាលអស់កល្បជានិច្ច។

របៀបដែលយើងប្រើប្រាស់របស់របរសព្វសារពើ និងកម្រិតនៃការចង់បានវា នោះសបង្ហាញឲ្យឃើញពីចរិតលក្ខណៈរបស់យើង។ ព្រះជាម្ចាស់បានសង្កត់ធ្ងន់ទៅលើចំណុចនេះនៅក្នុងកណ្ឌគម្ពីរលូកា ១៦:១០ថា៖

*អ្នកណាដែលស្មោះត្រង់ក្នុងការតូចបំផុតនោះក៏ឈ្មោះថា ស្មោះត្រង់ក្នុងការធំ ហើយអ្នកណាដែលទុច្ចរិតក្នុងការតូចបំផុត នោះក៏ឈ្មោះថាទុច្ចរិត*

*ក្នុងការដ៏ធំដែរ។*

ការតូចបំផុតដែលមានបង្ហាញនៅក្នុងខគម្ពីរនេះ គឺជាការមើលខុសត្រូវទៅលើរបស់របរសព្វសារពើ។ អស់អ្នកណាដែលព្រះជាម្ចាស់អាចពឹងពាក់បាន គឺជាអ្នកដែលប្រើរបស់របរទាំងនោះដើម្បីថ្វាយសិរីល្អដល់ទ្រង់ និងដើម្បីផ្តល់ជាព្រះពរដល់អ្នកដែលនៅជុំវិញពួកគេ។ ឯអស់អ្នកណាដែលព្រះជាម្ចាស់មិនអាចពឹងពាក់បាន គឺជាអ្នកដែលប្រើទ្រព្យសម្បត្តិរបស់ខ្លួនសម្រាប់តែភាពសុខសាន្ត ការរស់នៅយ៉ាងហ៊ឺហា និងការអរសប្បាយជាមួយនឹងភាពអាត្មានិយមរបស់ខ្លួនប៉ុណ្ណោះ។ បើបុគ្គលម្នាក់មិនអាចធ្វើឲ្យព្រះជាម្ចាស់ទុកចិត្តបានសូម្បីតែការតូចតាចបំផុត (ការមើលខុសត្រូវរបស់របរសព្វសារពើ) ផងនោះ តើឲ្យទ្រង់អាចនឹងទុកចិត្តគាត់ក្នុងការធំ (ការមើលខុសត្រូវខាងឯវិញ្ញាណ) បានយ៉ាងដូចម្តេច? បើបុគ្គលម្នាក់មិនស្មោះនឹងទ្រព្យសម្បត្តិលោកីយ៍នេះ តើគាត់អាចគិតថា ខ្លួនគាត់អាចនឹងស្មោះត្រង់ក្នុងការធ្វើជាអ្នកបម្រើរបស់ព្រះគ្រីស្ទព្រមទាំងធ្វើជាអ្នកមើលខុសត្រូវចំពោះអាថ៌កំបាំងរបស់ព្រះជាម្ចាស់បានយ៉ាងដូចម្តេច (១កូរិនថូស ៤:១)?

ហេតុដូច្នេះហើយព្រះសង្គ្រោះបានបន្ថែមការជជែកវែកញែកទៀតថា៖ *«ដូច្នេះ បើអ្នករាល់គ្នាមិនស្មោះត្រង់ ចំពោះទ្រព្យសម្បត្តិ*

*របស់លោកីយ៍ទេ តើអ្នកណាហ៊ានផ្ញើសម្បត្តិដ៏ពិតទុកនឹងអ្នករាល់គ្នាបាន?»* (លូកា ១៦:១១)។

ទ្រព្យសម្បត្តិខាងលោកីយ៍មិនមែនជាទ្រព្យសម្បត្តិពិតប្រាកដទេ តម្លៃរបស់វា គឺមានដែនកំណត់ ហើយមិនស្ថិតស្ថេរទេ។ ទ្រព្យសម្បត្តិខាងឯវិញ្ញាណ ទើបបានជាទ្រព្យសម្បត្តិពិតប្រាកដ តម្លៃរបស់វាគ្មានដែនកំណត់ ហើយក៏នៅស្ថិតស្ថេរ។ បើបុគ្គលម្នាក់មិនស្មោះត្រង់ក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិលោកីយ៍នេះ នោះគាត់មិនអាចនឹងរំពឹងឲ្យព្រះជាម្ចាស់ទុកចិត្តលើគាត់ជាមួយនឹងទ្រព្យសម្បត្តិខាងឯវិញ្ញាណនៅក្នុងជីវិតសព្វថ្ងៃនេះ ឬក៏នៅស្ថានសួគ៌នោះឡើយ។

ជាថ្មីម្តងទៀត ព្រះអម្ចាស់បានបន្តការជជែករំកញែកទៀតថា៖ *«ហើយបើអ្នករាល់គ្នាមិនស្មោះត្រង់នឹងរបស់គេទេ តើអ្នកណានឹងហ៊ានឲ្យរបស់អ្វីដាច់ជារបស់ផងអ្នកបាន?»* (លូកា ១៦:១២)។

ទ្រព្យសម្បត្តិដែលយើងមាន  នោះយើងមានដោយសារព្រះជាម្ចាស់បានប្រទានមក ដើម្បីឲ្យយើងមើលខុសត្រូវ ប៉ុន្តែអ្វីដែលយើងអាចហៅថាជារបស់ផងខ្លួនបាន គឺចំណេះដឹងនៃការរៀនព្រះគម្ពីរ និងផលផ្លែនៃការបម្រើនៅលោកីយ៍នេះ ព្រមទាំងរង្វាន់ដែលយើងនឹងទទួលនៅឯស្ថានសួគ៌ ដោយសារយើងបានមើលខុសត្រូវរាល់អ្វីដែលទ្រង់បានប្រទានមកយើងយ៉ាងស្មោះត្រង់។ ប្រសិនបើ

យើងមិនបានបង្ហាញថា យើងជាអ្នកដែលព្រះជាម្ចាស់អាចទុកចិត្ត បានក្នុងការទទួលខុសត្រូវលើទ្រព្យសម្បត្តិរបស់ទ្រង់ទេនោះ នោះកុំ រំពឹងថាយើងអាចយល់ពីសេចក្តីពិតនៃព្រះបន្ទូលដ៏ជ្រាលជ្រៅរបស់ ទ្រង់ក្នុងជីវិតនេះ ឬទទួលបានរង្វាន់នៅឯស្ថានសួគ៌នោះឡើយ។

ព្រះអម្ចាស់បានបង្រួមសេចក្តីបង្រៀនអំពីរឿងអ្នកមើលខុសត្រូវ នេះ ដូចខាងក្រោម៖

> *គ្មានបាវណាដែលបំរើចៅហ្វាយ២ បានទេ ពីព្រោះបាវនោះនឹងស្អប់១ ស្រឡាញ់១ ឬនឹងកាន់ខាង១ ហើយមើលងាយ១ ដូច្នេះ អ្នករាល់គ្នាក៏បំរើ ព្រះផង ទ្រព្យសម្បត្តិផងពុំបានដែរ* (លូកា ១៦:១៣)។

សិស្សរបស់ព្រះយេស៊ូវក៏មិនអាចបែងចែកភក្តីភាពបានដែរ។ សិស្សរបស់ទ្រង់មិនអាចរស់នៅដើម្បីសម្បត្តិលោកីយ៍ផង និងសម្បត្តិ ស្ថានសួគ៌ផងនោះទេ។ អ្នកមើលខុសត្រូវអាចស្រឡាញ់បានតែព្រះ ជាម្ចាស់ ឬក៏ទ្រព្យសម្បត្តិតែមួយប៉ុណ្ណោះ។ ប្រសិនបើគាត់ស្រឡាញ់ ទ្រព្យសម្បត្តិ នោះមានន័យថា គាត់ស្អប់ព្រះជាម្ចាស់ហើយ។

ត្រូវចងចាំថាខគម្ពីរទាំងនេះ គឺសរសេរសំដៅទៅកាន់សិស្សព្រះ យេស៊ូវមិនមែនទៅកាន់អ្នកដែលមិនជឿនោះទេ។

## ជំពូកទី៥

# ភាពឧស្សាហ៍

ទោះបើសិស្សរបស់ព្រះយេស៊ូវមិនសូវឆ្លាតវៃយ៉ាងណាក៏ដោយ ក៏ពួកគេនៅតែអាចទទួលបាននូវការអត់ទោសដែរ។ ពួកគេនៅតែអាចទទួលបាននូវការអត់ទោស ទោះបើពួកគេមិនមានកម្លាំងកាយដ៏ខ្លាំងក្លាក៏ដោយ។ ប៉ុន្តែសិស្សមិនអាចយកលេសរួចខ្លួនបានទេ បើពួកគេមិនឧស្សាហ៍សោះ។

ប្រសិនបើ ចិត្តរបស់ពួកគេមិនមានបំណងប្រាថ្នាដ៏ឆេះឆួលចំពោះព្រះសង្គ្រោះ នោះព្រះជាម្ចាស់នឹងថ្កោលទោសពួកគេ។

តាមពិត គ្រីស្ទបរិស័ទគឺជាអ្នកដើរតាមព្រះយេស៊ូវដែលទ្រង់មានបន្ទូលថា៖ *«សេចក្តីឧស្សាហ៍ដល់ដំណាក់ទ្រង់ បានស៊ីបង្ហិនទូលបង្គំ»* (យ៉ូហាន ២:១៧)។ ព្រះសង្គ្រោះរបស់គ្រីស្ទបរិស័ទមានពេញទៅដោយភាពឆេះឆួលចំពោះព្រះជាម្ចាស់ និងបំណងព្រះហឫទ័យរបស់ទ្រង់។ ទ្រង់មិនទទួលមនុស្សចូលក្នុងជួរកងទ័ពទ្រង់ដែលមិនដើរតាមទ្រង់យ៉ាងអស់ពីចិត្តនោះទេ។

ព្រះអម្ចាស់យេស៊ូវបានរស់នៅក្នុងស្ថានភាពប្រទាញប្រទង់ខាងឯវិញ្ញាណ។ យើងអាចយល់ការនេះបានដោយសារទ្រង់មានបន្ទូលថា៖ *«តែខ្ញុំត្រូវទទួលបុណ្យជ្រមុជ១សិន ហើយខ្ញុំត្រូវចង្អៀតចង្អល់យ៉ាងដូចម្តេចទៅហ្ន៎ ទំរាំតែបុណ្យនោះបានសំរេច»* (លូកា ១២:៥០)។ ហើយម្យ៉ាងទៀតតាមរយៈព្រះបន្ទូលក្នុងខគម្ពីរមួយដែលគួរឲ្យកត់សម្គាល់គឺ៖ *«កំពុងដែលថ្ងៃនៅភ្លឺនៅឡើយ នោះត្រូវតែខ្ញុំធ្វើការរបស់ព្រះ ដែលចាត់ឲ្យខ្ញុំមក ដ្បិតយប់ដល់មក នោះគ្មានអ្នកណាអាចនឹងធ្វើការបានទេ»* (យ៉ូហាន ៩:៤)។

ព្រះជាម្ចាស់បានបញ្ជាក់ពីភាពឧស្សាហ៍របស់យ៉ូហាន-បាទីស្ទត្រង់កន្លែងដែលទ្រង់មានបន្ទូលថា៖ *«លោកជាចង្កៀងដែលឆេះហើយភ្លឺ»* (យ៉ូហាន ៥:៣៥)។

សាវ័ក ប៉ុល គឺជាមនុស្សឧស្សាហ៍។ អ្នកនិពន្ធដែលយើងមិនបានស្គាល់ឈ្មោះម្នាក់បានព្យាយាមរៀបរាប់ពីចិត្តក្លៀវក្លារបស់សាវ័ក ប៉ុល យ៉ាងសង្ខេបដូចខាងក្រោម៖

> សាវ័ក ប៉ុល ជាមនុស្សម្នាក់ដែលមិនខ្វល់ខ្វាយអំពីការរាប់ញាតិ មិនរំពឹង ឬប៉ងប្រាថ្នាចង់បានទ្រព្យនៅលោកីយ៍ មិនព្រួយបារម្ភចំពោះការបាត់បង់ទ្រព្យខាងលោកីយ៍មិនខ្វល់ខ្វាយពីជីវិត ហើយមិនភ័យខ្លាចនឹងសេចក្តីស្លាប់នោះទេ។ គាត់ជាមនុស្សដែលរាប់ខ្លួនថា មិនមានឋានៈ ប្រ-

ទេស ឬក៏លក្ខខណ្ឌតម្រូវណាមួយឡើយ។ គាត់មានគោលគំនិតតែមួយ គឺដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ឯគោលបំណងតែមួយ គឺថ្វាយសិរីល្អដល់ព្រះជាម្ចាស់។ គេហៅគាត់ថាជាមនុស្សល្ងីល្ងើ ហើយគាត់ពេញចិត្តឲ្យគេរាប់ខ្លួនថាជាមនុស្សល្ងីល្ងើសម្រាប់ព្រះគ្រីស្ទ។ ចូរឲ្យលោកីយ៍នេះហៅគាត់ថាជាអ្នកងប់ងុលអ្នកជឿស៊ប់ អ្នកនិយាយប៉ប៉ាច់ប៉ប៉ោច ឬឈ្មោះដែលចំឡែកខុសគេផ្សេងៗទៀតតាមន័យអ្វីដែលគេចង់ហៅគាត់ទៅចុះ។ ប៉ុន្តែ កុំហៅគាត់ថាជាអ្នកត្រាប់តាមលោកីយ៍នេះឡើយ។ ដរាបណាគេហៅគាត់ថាជាអ្នកដោះដូរ ម្ចាស់ផ្ទះ ពលរដ្ឋ អ្នកមានទ្រព្យសម្បត្តិ អ្នកតាមខាងលោកីយ៍ អ្នកបានរៀនជ្រៅជ្រះ ឬក៏ជាអ្នកដែលចេះយល់ហេតុការណ៍ នោះខុសឆ្គងនឹងលក្ខណៈដ៏ពិតរបស់គាត់ហើយ។

គាត់ត្រូវតែនិយាយឬក៏គាត់ត្រូវតែស្លាប់ ហើយទោះបើគាត់ត្រូវស្លាប់ក៏គាត់នៅតែនិយាយ។ គាត់មិនមានពេលគ្រប់គ្រាន់ដើម្បីឈប់សម្រាក ប៉ុន្តែគាត់តែងធ្វើដំណើរយ៉ាងរហ័ស លើដី និងសមុទ្រ លើក្រួសថ្ម និងវាលខ្សាច់ដែលគ្មានផ្លូវទៅមក ដើម្បីផ្សាយដំណឹងល្អ។ គាត់ស្រែកខ្លាំងៗឲ្យអ្នកគ្រប់គ្នាបានឮ ហើយពុះពារទៅមុខដោយមិនរួញរា។ នៅក្នុងគុក គាត់បន្លឺសំឡេងឡើង ហើយនៅពេលដែលកំពុងតែប្រឈមមុខនឹងព្យុះសង្ឃរា ក៏គាត់មិននៅស្ងៀមដែរ។ នៅមុខក្រុមមន្ត្រី និងរាជបល្ល័ង្ក គាត់បានធ្វើទីបន្ទាល់បញ្ជាក់ពីសេចក្តីពិត។ គ្មានអ្វីដែលអាចនឹងបញ្ឈប់សំឡេងរបស់

គាត់ក្រៅពីសេចក្តីស្លាប់ប៉ុណ្ណោះ ហើយទោះបើគាត់ត្រូវស្លាប់មុនពេលដែល កាំបិតមកកាត់ក្បាលគាត់ចេញពីរូបកាយក៏ដោយ ក៏គាត់នៅតែនិយាយ អធិស្ឋាន ធ្វើទីបន្ទាល់ ប្រកាស ទទូចអង្វរ និងតយុទ្ធ ហើយនៅទីបញ្ចប់ គាត់បានជូនពរដល់មនុស្សឃោរឃៅទាំងនោះទៀតផង។

មានអ្នកផ្សេងទៀតដែលជឿលើព្រះជាម្ចាស់បានបង្ហាញពីបំណង ប្រាថ្នាដ៏ឆេះឆួលដូចនេះ ដើម្បីឲ្យបានសព្វព្រះហឫទ័យព្រះជាម្ចាស់។ ដូចជាលោក ស៊ី. ធី. ស្ទឹដ (C. T. Studd) បានលើកឡើងថា៖

*អ្នកខ្លះចង់រស់ចំណោមសំឡេងស្គរជួងជាភ្លេងនៃព្រះវិហារ*
*តែរូបខ្ញុំវិញមានចិត្តហានក្លាបើកហាងសង្គ្រោះដ៏វាំ*
*កៀកនឹងទ្វារនរក។*

តាមពិតទៅ វាគឺជាឯកសារដែលសរសេរដោយអ្នកមិនជឿថា មានព្រះ ដែលបណ្តាលឲ្យលោក ស៊ី. ធី. ស្ទឹដ (C. T. Studd) តាក់-តែងឡើងយ៉ាងអស់ពីចិត្តថ្វាយព្រះគ្រីស្ទ។ ឯកសារនេះមានដូចត ទៅ៖

ប្រសិនបើ ខ្ញុំជឿជាក់ថា ចំណេះដឹង និងការធ្វើតាមសាសនានៅក្នុង ជីវិតសព្វថ្ងៃនេះ ជះឥទ្ធិពលដល់ជីវិតនៅលោកខាងមុខ ដូចដែលមនុស្ស

រាប់លាននាក់ជឿ នោះការធ្វើតាមសាសនានឹងក្លាយទៅជាការដែលសំខាន់ជាងគេបំផុតក្នុងជីវិតខ្ញុំ។ ខ្ញុំនឹងបោះបង់ ការកម្សាន្តនៅលោកីយ៍នេះដូចជាសំរាម ការខ្វល់ខ្វាយខាងលោកីយ៍ដូចជាការចំកួត និងគំនិតអារម្មណ៍នៃលោកីយ៍ដូចជាការឥតប្រយោជន៍នេះចោលចេញ។ សាសនានឹងក្លាយជាគំនិតដំបូងគេរាល់ពេលដែលខ្ញុំភ្ញាក់ឡើង ហើយជាគំនិតចុងក្រោយគេបំផុតមុននឹងខ្ញុំលង់លក់ទៅនៅពេលរាត្រី។ ខ្ញុំនឹងពុះពារគ្រប់បែបយ៉ាងសម្រាប់តែប្រយោជន៍សាសនាតែប៉ុណ្ណោះ។ ខ្ញុំនឹងពិចារណាតែពីអនាគតអស់កល្បជានិច្ចតែប៉ុណ្ណោះ។ ខ្ញុំនឹងស្ម័គ្រចិត្តទទួលយកជីវិតដែលពោរពេញដោយការរងទុក្ខនៅលោកីយ៍នេះ ប្រយោជន៍ឲ្យព្រលឹងមនុស្សម្នាក់បានទៅកាន់ស្ថានសួគ៌។ លទ្ធផលអាក្រក់នៅលោកីយ៍នេះ មិនអាចបញ្ឈប់សកម្មភាព ឬបិទមាត់ខ្ញុំបានឡើយ។ អំណរ និងទុក្ខព្រួយរបស់លោកីយ៍មិនអាចជ្រៀតចូលមកក្នុងគំនិតខ្ញុំបានឡើយ។ ខ្ញុំនឹងព្យាយាមស្វែងរកតែភាពអស់កល្បជានិច្ច និងព្រលឹងដ៏អមតៈនៅជុំវិញខ្លួនខ្ញុំដែលគេអាចនឹងមានភាពអរសប្បាយ ឬអាចនឹងរងទុក្ខវេទនាអស់កល្បជានិច្ចនាពេលឆាប់ៗនេះ។ ខ្ញុំនឹងចេញទៅផ្សាយពីសាសនាខ្ញុំដល់លោកីយ៍ទាំងមូល ទោះបើត្រូវរដូវ ឬខុសរដូវក្តី។ ហើយបទគម្ពីរដែលខ្ញុំនឹងផ្សាយនោះគឺ៖ *«បើមនុស្សណានឹងបានលោកីយ៍ទាំងមូល តែបាត់ព្រលឹងទៅ នោះតើមានប្រយោជន៍អ្វីដល់អ្នកនោះ?»*[១]

លោក ចន វេស្លី (John Wesley) គឺជាមនុស្សដ៏ឧស្សាហ៍ម្នាក់។ គាត់បានមានប្រសាសន៍ថា៖ *«ចូរឲ្យអ្នកដែលស្រឡាញ់ព្រះជាម្ចាស់អស់ពីចិត្តចំនួនមួយរយនាក់ ហើយមិនខ្លាចអ្វីទាំងអស់ក្រៅតែពីអំពើបាបមកឯខ្ញុំ នោះខ្ញុំនឹងបំផ្លាស់បំប្រែលោកីយ៍នេះ»*។

លោក ជីម អេលាត (Jim Elliot) ដែលជាមរណសាក្សីនៅប្រទេស អេក្វាទ័រ (Ecuador) គឺជាចន្លុះបំភ្លឺថ្វាយព្រះយេស៊ូវគ្រីស្ទ។ មានថ្ងៃមួយ ពេលដែលគាត់កំពុងតែសញ្ជឹងគិតពីបទគម្ពីរដែលថែងថា៖ *«ទ្រង់យកពួក...អ្នកបំរើទ្រង់ធ្វើជាអណ្តាតភ្លើង»* (ហេព្រើរ ១:៧) នោះគាត់ក៏បានសរសេរការនេះក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់គាត់ដូចតទៅ៖

> តើខ្ញុំមានភាពឆេះឆួលសម្រាប់ព្រះជាម្ចាស់ឬទេ? ព្រះអង្គអើយ សូមទ្រង់ដករនាំងនៃលោកីយ៍នេះដែលរារាំងទូលបង្គំមិនឲ្យមានភាពឆេះឆួលនឹងទ្រង់ចេញផង។ សូមចាក់ប្រេងនៃព្រះវិញ្ញាណទ្រង់តាំងទូលបង្គំឲ្យបានជោគជាំ ដើម្បីឲ្យទូលបង្គំក្លាយជាអណ្តាតភ្លើងដែលងាយនឹងឆេះសម្រាប់ទ្រង់។ ប៉ុន្តែអណ្តាតភ្លើងឆេះបានតែមួយឆាវ។ ធម្មតា វាឆេះតែមួយរយៈពេលខ្លីប៉ុណ្ណោះ។ ឱ! ព្រលឹងខ្ញុំអើយ តើឯងអាចនឹងអត់ទ្រាំនឹងជីវិតដ៏ខ្លីនេះបានដែរឬយ៉ាងណា? ក្នុងរូបកាយខ្ញុំនេះមានព្រះវិញ្ញាណនៃព្រះអង្គដ៏គង់នៅ

ផែនដីនេះក្នុងរយៈពេលដ៏ខ្លី ហើយភាពឧស្សាហ៍របស់ទ្រង់ចំពោះតំណាក់របស់ព្រះជាម្ចាស់បានធ្វើឲ្យទ្រង់ឆេះឆួល។ ឱ! អណ្ដាតភ្លើងព្រះជាម្ចាស់អើយ សូមធ្វើឲ្យទូលបង្គំក្លាយជាប្រេងរបស់ទ្រង់ផង។[២]

ឃ្លាចុងក្រោយនេះ គឺជាឃ្លាដែលគាត់បានបង្រួមពីឃ្លាកំណាព្យដ៏ឆេះឆួលរបស់លោកស្រី អេមី ខរម៉ាយខល (Amy Carmichael)៖

*ចេញពីពាក្យអធិស្ឋាន ខ្ញុំបានទូលសូមទ្រង់*
*ជ្រកក្រោមបារមីព្រះអង្គ គេចពីព្យុះបោកបក់*
*សូមកុំមានចិត្តស្ទាក់ស្ទើរពេលឡើងទីខ្ពស់*
*កុំឲ្យអួតអាងហួស លោះខ្ញុំមានសេរី*
*ដើម្បីឲ្យខ្ញុំស្មោះស្ម័គ្រដើរតាមទ្រង់។*
*ឱព្រះជាម្ចាស់អើយ*
*សូមឲ្យទូលបង្គំក្លាយជាទាហានស្មោះស្ម័គ្រនៃទ្រង់។*

*ចេញពីសេចក្ដីស្រឡាញ់បន្ទន់គ្រប់រឿង*
*ងាយស្រួលនោះឡើងទាំងភាពកម្សោយ*
*ទោះតាមការនេះព្រលឹងមិនមាំក៏ដោយ*

*មិនដោយរបៀបនេះឡើយដែលទ្រង់ត្រូវឆ្កាង។*
*ចេញពីការលោក់ពន្លឺកាល់វ៉ារី*
*កូនចៀមព្រះដ៏មានបារមី សូមសង្គ្រោះខ្ញុំផង!*

*សូមក្ដីស្រឡាញ់ជួយដឹកនាំផ្លូវ*
*ជំនឿដែលត្រូវគ្មានអ្វីអាចផ្ដួលរលំ*
*សេចក្ដីសង្ឃឹមដែលឋិតថេរនៅងំ*
*ក្ដីប្រាថ្នាប៉ងឆេះឆួលដូចភ្លើងគ្មានផ្សែង។*
*សូមកុំឲ្យទូលបង្គំធ្លាក់ទៅជាមនុស្សឆោតល្ងង់ឡើយ*
*ឱ! អណ្ដាតភ្លើងព្រះជាម្ចាស់អើយ*
*សូមធ្វើឲ្យទូលបង្គំក្លាយជាប្រេងរបស់ទ្រង់ផង។*

ភាពអាម៉ាស់របស់ក្រុមជំនុំនៅសតវត្សរ៍ទី២១នេះគឺត្រង់ថា អ្នកបំផ្ទុះគ្រាប់បែកអត្តឃាត និងអ្នកកាន់សាសនាខុសឆ្គងមានភាពឧស្សាហ៍ជាងគ្រីស្ទបរិស័ទទៅទៀត។

នៅឆ្នាំ ១៩០៣ មានបុរសម្នាក់រួមជាមួយនឹងអ្នកដើរតាមគាត់ចំនួនដប់ប្រាំពីរនាក់បានចាប់ផ្ដើមវាយប្រហារពិភពលោក។ គាត់ឈ្មោះ វ្ល៉ាឌីមៀរ លេនីន (Vladimir Lenin)។ មកដល់ឆ្នាំ ១៩១៨

ក្រុមរបស់គាត់បានកើនឡើងរហូតទៅដល់បួនម៉ឺននាក់ ហើយគាត់បានគ្រប់គ្រងមនុស្សចំនួនហុកសិបលាននាក់នៅប្រទេសរុស្ស៊ី (Russia) ជាមួយនឹងក្រុមនោះ។ បើទោះជាចលនានោះមានការថយចុះនាប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ចលនានោះនៅតែគ្រប់គ្រងមនុស្សជាងមួយភាគប្រាំនៃពិភពលោកទាំងមូល។ ទោះបីជាយើងប្រឆាំងនឹងគោលការណ៍របស់គេក៏ដោយ ក៏ភាពឧស្សាហ៍របស់គេគួរឲ្យសរសើរដែរ។

គ្រីស្ទបរិស័ទជាច្រើននាក់មានអារម្មណ៍ថា លោក ប៊ីលី ហ្គ្រាម (Billy Graham) បានស្តីបន្ទោសឲ្យខ្លួន នៅពេលដែលគាត់បានអានសំបុត្រដូចខាងក្រោមនេះដែលសរសេរឡើងដោយនិស្សិតមហាវិទ្យាល័យសញ្ជាតិអាមេរិកម្នាក់ដែលបានផ្លាស់ប្តូរចិត្តគំនិតខ្លួនទៅកាន់លទ្ធិកុម្មុយនីស្ត ខណៈពេលដែលគាត់នៅក្នុងប្រទេសម៉ិកស៊ិកូ (Mexico)។ អត្ថន័យក្នុងសំបុត្រនេះវាប្រហាក់ប្រហែលទៅនឹងគំនិតរបស់ភេរវជននាសម័យបច្ចុប្បន្ននេះដែរ។ គោលបំណងនៃសំបុត្រនេះគឺចង់ពន្យល់ដល់គូដណ្តឹងរបស់គាត់ពីមូលហេតុនៃការដែលគាត់សម្រេចចិត្តផ្តាច់ពាក្យ៖

> យើងដែលជាអ្នកកាន់លទ្ធិកុម្មុយនីស្តប្រឈមមុខនឹងអត្រាស្លាប់ខ្ពស់។ យើងត្រូវគេបាញ់ប្រហារ ព្យួរក ឃុំឃាំង និយាយបង្កាច់បង្ខូច ចំអកឡក-

ឡើយ បណ្ដេញឈប់ពីការងារ និងតាមរបៀបគ្រប់យ៉ាងផ្សេងទៀតដែលគេអាចធ្វើទុក្ខបុកម្នេញបានដោយមិនឲ្យយើងមានសេចក្ដីសុខ។ គេបានសម្លាប់ ឬឃុំឃាំងពួកយើងមួយចំនួន។ យើងរស់នៅក្នុងភាពក្រីក្រ។ យើងផ្ញើរលុយស្ទើរអស់ពីខ្លួនទៅបក្សកុម្មុយនីស្ដ ហើយគ្រាន់តែទុកលុយខ្លះដើម្បីផ្គត់ផ្គង់តម្រូវការចាំបាច់របស់យើងតែប៉ុណ្ណោះ។ យើងដែលជាអ្នកកាន់លទ្ធិកុម្មុយនីស្ដមិនមានពេលវេលា ឬលុយសម្រាប់មើលកុន ការប្រគំតន្ត្រី ញ៉ាំអាហារថ្លៃៗ ឬទិញផ្ទះវីឡា និងឡានថ្មីៗនោះទេ។ គេថាយើងជាអ្នកងប់ងុលនឹងលទ្ធិកុម្មុយនីស្ដខ្លាំង។ ពិតណាស់ យើងពិតជាអ្នកងប់ងុលមែន។ ជីវិតរបស់យើងគ្រប់គ្រងដោយគោលបំណងដ៏ធំបំផុតមួយគឺៈ ការតស៊ូដើម្បីឲ្យលទ្ធិកុម្មុយនីស្ដបានរីកសាយពាសពេញពិភពលោក។

លុយមិនអាចទិញគោលលទ្ធិកុម្មុយនីស្ដរបស់យើងបានទេ ព្រោះវាមានតម្លៃខ្ពស់បំផុត។ យើងមានបុព្វហេតុជាក់លាក់ចង់ឃើញលទ្ធិនេះរីកចម្រើន ហើយយើងក៏មានគោលបំណងដ៏ច្បាស់លាស់ក្នុងជីវិតដែរ។ យើងស្ម័គ្រចិត្តដាក់រូបកាយដែលមិនស្ថិតស្ថេរនេះទៅក្នុងចលនាដ៏អស្ចារ្យរបស់មនុស្សជាតិ។ ហើយទោះបើជីវិតផ្ទាល់ខ្លួនរបស់យើងមានការលំបាក ឬក៏រូបកាយយើងទទួលរងការឈឺចាប់តាមរយៈការស្ថិតនៅក្រោមបង្គាប់បក្សកុម្មុយនីស្ដក៏ដោយ ក៏យើងនៅតែតស៊ូ ដោយសារយើងដឹងថា យើងរាល់គ្នាបានរួមចំណែកជាមួយនឹងការដែលថ្មី ពិត ហើយជាប្រយោជន៍ដ៏ល្អបំផុតដល់

មនុស្សជាតិ។

ខ្ញុំមានបំណងតែមួយប៉ុណ្ណោះ គឺធ្វើយ៉ាងណាដើម្បីបំពេញតាមបុព្វហេតុនៃបក្សកុម្មុយនីស្ត។ បុព្វហេតុនៃបក្សកុម្មុយនីស្តគឺជា ជីវិតខ្ញុំ ការងារខ្ញុំ សាសនាខ្ញុំ ចំណង់ចំណូលចិត្តខ្ញុំ សង្សារខ្ញុំ ប្រពន្ធខ្ញុំ ស្រីកំណាន់ខ្ញុំ និងអាហារដែលខ្ញុំញ៉ាំជាប្រចាំថ្ងៃ។ ពេលថ្ងៃខ្ញុំធ្វើការជាប្រយោជន៍ដល់បុព្វហេតុនៃបក្សកុម្មុយនីស្ត ហើយពេលយប់ខ្ញុំគេងស្រមៃអំពីបុព្វហេតុនៃបក្សកុម្មុយនីស្ត។ ពេលដែលពេលវេលាកាន់តែដើរទៅមុខ បុព្វហេតុនៃបក្សកុម្មុយនីស្តកាន់តែជ្រាបចូលក្នុងគំនិតខ្ញុំជ្រៅទៅៗ វាមិនជ្រាបចេញឡើយ។ ហេតុដូច្នេះហើយ ខ្ញុំមិនអាចបន្តមិត្តភាព ស្នេហា ឬក៏ទំនាក់ទំនងដោយគ្មានការពាក់ព័ន្ធជាមួយនឹងបុព្វហេតុនេះដែលជំរុញ និងដឹកនាំជីវិតខ្ញុំបានទៀតទេ។ ខ្ញុំវាយតម្លៃមនុស្ស សៀវភៅ គំនិត និងសកម្មភាពទាំងឡាយដោយផ្អែកទៅតាមអាកប្បកិរិយា និងការដែលគេមានឥទ្ធិពលមកលើបុព្វហេតុនៃបក្សកុម្មុយនីស្ត។ គេបានឃុំឃាំងខ្ញុំនៅក្នុងគុកម្តងរួចទៅហើយ ដោយសារតែខ្ញុំកាន់តាមលទ្ធិកុម្មុយនីស្ត ហើយប្រសិនបើគេចាំបាច់សម្លាប់ខ្ញុំមែន ខ្ញុំក៏មិនខ្លាចឲ្យក្រុមទាហានពេជ្ឈឃាតបាញ់សម្លាប់ខ្ញុំដែរ។[៣]

ប្រសិនបើអ្នកកាន់លទ្ធិកុម្មុយនីស្តធ្វើសម្រាប់បុព្វហេតុរបស់គេអស់ពីចិត្តយ៉ាងនេះ តើគ្រីស្ទបរិស័ទគួរនឹងលះបង់សម្រាប់សេចក្តី

ស្រឡាញ់ ហើយប្តូរផ្តាច់ចំពោះព្រះជាម្ចាស់របស់គេយ៉ាងណាដែរ? ប្រាកដណាស់ថា ប្រសិនបើព្រះអម្ចាស់យេស៊ូវមានតម្លៃ នោះទ្រង់ត្រូវមានតម្លៃលើសអ្វីៗទាំងអស់។ លោក ហ្វាញឡេ្ល (Findlay) បានមានប្រសាសន៍ថា *«ប្រសិនបើជំនឿរបស់គ្រីស្ទបរិស័ទស័ក្តិសមនឹងឲ្យយើងជឿ នោះវាក៏ស័ក្តិសមនឹងឲ្យយើងជឿអស់ពីចិត្តដែរ ទោះបើត្រូវស្លាប់ក៏ដោយ»*។

លោក ចេមស៍ ដែននី (James Denney) បានមានប្រសាសន៍ថា *«បើព្រះជាម្ចាស់បានរៀបចំផ្លូវដើម្បីសង្គ្រោះលោកីយ៍នេះតាមរយៈព្រះគ្រីស្ទ ព្រមទាំងបានបើកសម្តែងពីដំណឹងនេះពិតប្រាកដមែន នោះគ្រីស្ទបរិស័ទគ្រប់រូបត្រូវប្រឆាំងគ្រប់ទាំងអ្វីដែលមើលងាយ បដិសេធ ឬបង្វែរសេចក្តីពិតនេះ»*។

ព្រះជាម្ចាស់សព្វព្រះទ័យនឹងមនុស្សណាដែលអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធដឹកនាំចិត្តរបស់ពួកគេទាំងស្រុង។ ពេលលោកីយ៍មើលអ្នកទាំងនោះ ពួកគេគិតថា អ្នកទាំងនោះជាអ្នកស្រវឹងខួប ប៉ុន្តែចំពោះអ្នកដែលស្គាល់អ្នកទាំងនោះច្បាស់ គេនឹងដឹងថា អ្នកទាំងនោះកំពុងរស់នៅដោយការស្រេកឃ្លានយ៉ាងខ្លាំងក្រៃដែលមិនចេះស្កប់នឹងព្រះជាម្ចាស់។

ចូរឲ្យអស់អ្នកដែលចង់ធ្វើជាសិស្សរបស់ព្រះយេស៊ូវទទួលស្គាល់

ថា ពួកគេត្រូវតែមានភាពឧស្សាហ៍នៅក្នុងជីវិតរបស់ខ្លួន។ ចូរយើងយកគំរូតាមការពណ៌នាអំពីអ្នកឧស្សាហ៍ដែលគ្រូគង្វាល ចេ. ស៊ី. រ៉ៃល (J. C. Ryle) បាននិពន្ធ៖

អ្នកឧស្សាហ៍នឹងសាសនា គឺជាអ្នកដែលគិតតែពីរឿងសាសនាមួយប៉ុណ្ណោះ។ បើយើងគ្រាន់តែថា គាត់ជាមនុស្សដែលស្មោះអស់ពីចិត្ត រួសរាយរាក់ទាក់ មិនចេះស៊ីសំណូកសូកប៉ាន់ ជាមនុស្សដែលយកចិត្តទុកដាក់ផ្ទង់អារម្មណ៍ខ្ពស់ និងមានស្មារតីក្លៀវក្លា នោះមិនទាន់គ្រប់គ្រាន់នឹងហៅគាត់ជាអ្នកឧស្សាហ៍នៅឡើយទេ។ អ្នកឧស្សាហ៍ផ្តោតអារម្មណ៍តែលើរឿងមួយ ខ្វល់ខ្វាយតែលើរឿងមួយ រស់នៅដើម្បីតែរឿងមួយ ហើយគាត់នៅក្រាញនៀលជាមួយតែរឿងមួយហ្នឹង ហើយរឿងមួយហ្នឹង គឺធ្វើយ៉ាងណាឲ្យតែបានគាប់ព្រះហឫទ័យព្រះជាម្ចាស់។ គាត់មិនខ្វល់ពីរឿងផ្សេងទៀត ទោះបើគាត់រស់ឬស្លាប់ក្តី ឈឺឬជាក្តី ទោះបើគាត់មានឬក្រក្តី ហើយបើទោះជាធ្វើឲ្យគេសប្បាយចិត្ត ឬពិបាកចិត្តក្តី មិនថាគេគិតថាគាត់ឆ្លាតឬល្ងង់ក្តី មិនថាគេស្តីបន្ទោស ឬស្ញើចសរសើរគាត់ក្តី ហើយបើទោះជាគេលើកមុខ ឬបំបាក់មុខក្តី ក៏គាត់មិនខ្វល់ពីការទាំងអស់នោះដែរ ព្រោះគាត់ខ្វល់តែពីការផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ ដើម្បីថ្វាយសិរីល្អដល់ទ្រង់តែមួយប៉ុណ្ណោះ។

ទោះបីជាគាត់ត្រូវលះបង់ជីវិត ក៏គាត់មិនខ្វល់ដែរ ព្រោះគាត់ពេញចិត្ត

ពេញថ្លើមនឹងព្រះជាម្ចាស់។ គាត់មានអារម្មណ៍ថា ខ្លួនគាត់ប្រៀបបានដូចជាចង្កៀងដែលទុកសម្រាប់ដុតអញ្ចឹងដែរ ហើយបើគាត់ត្រូវឆេះអស់ នោះក៏មិនចម្លែកអ្វីដល់គាត់ដែរ  ពីព្រោះគាត់ធ្វើអ្វីតាមតែការកំណត់របស់ព្រះជាម្ចាស់ប៉ុណ្ណោះ។  បុគ្គលប្រភេទនេះប្រាកដជានឹងរកឃើញវិធី ដើម្បីឲ្យភាពឧស្សាហ៍របស់គាត់ចេញជាសកម្មភាពជាមិនខាន។ បើគាត់មិនអាចអធិប្បាយ មិនអាចធ្វើការ ឬក៏មិនអាចថ្វាយតង្វាយ នោះគាត់នឹងអង្គុយយំ ដកដង្ហើមធំ ហើយអធិស្ឋានជាមិនខាន។ មែនហើយ ទោះបើគាត់ក្រីក្រ ឬឈឺធ្ងន់ធ្ងរក្ដី ក៏គាត់នឹងធ្វើឲ្យសេចក្ដីអាក្រក់ជាប់គាំង ដោយសារការអធិស្ឋានដ៏ខ្លាំងក្លារបស់គាត់។ ប្រសិនបើគាត់មិនអាចចូលរួមតយុទ្ធនៅក្នុងជ្រលងភ្នំជាមួយលោក យ៉ូស្វេ ទេ នោះគាត់នឹងធ្វើការដូចលោក ម៉ូសេ លោក អើរ៉ុន  និង លោក ហើរ  នៅលើកំពូលភ្នំ (និក្ខមនំ ១៧:៩-១៣)។ ប្រសិនបើគាត់មិនអាចបន្តធ្វើព័ន្ធកិច្ច នោះគាត់នឹងអធិស្ឋានទៅកាន់ព្រះជាម្ចាស់រហូតទាល់តែទ្រង់ចាត់នរណាម្នាក់ផ្សេងទៀតមកធ្វើជាជំនួយរបស់គាត់ ដើម្បីបំពេញព័ន្ធកិច្ចនោះ។ នេះហើយគឺជាអ្វីដែលខ្ញុំចង់បញ្ជាក់ជូនពីអត្ថន័យនៃពាក្យ “*ឧស្សាហ៍*” ក្នុងជីវិតជាគ្រីស្ទបរិស័ទ។[៤]

## ជំពូកទី៦

# ជំនឿ

ភាពជាសិស្សដ៏ពិតប្រាកដមិនអាចកើតមានឡើងបានដោយគ្មានជំនឿដ៏ស្មោះស្ម័គ្រ ហើយជ្រាលជ្រៅក្នុងព្រះដ៏មានព្រះជន្មគង់នៅនោះឡើយ។ អស់អ្នកដែលចង់ធ្វើព័ន្ធកិច្ចថ្វាយព្រះជាម្ចាស់ជាដំបូងគាត់ត្រូវជឿលើទ្រង់យ៉ាងអស់ពីចិត្តជាមុនសិន។ លោកហ័ដសិន ថេល័រ (Hudson Taylor) បានសរសេរបញ្ជាក់ថា "អស់អ្នកដែលមានជំនឿយ៉ាងមុតមាំលើព្រះជាម្ចាស់សុទ្ធតែជាអ្នកទន់ខ្សោយដែលបានធ្វើកិច្ចការដ៏ធំក្រៃលែងថ្វាយទ្រង់ ដោយសារតែពួកគេជឿថា ទ្រង់គង់នៅជាមួយ"។

ដូច្នេះ  ជំនឿដ៏ពិត គឺតែងតែផ្អែកលើសេចក្ដីសន្យារបស់ព្រះជាម្ចាស់ដែលមានក្នុងព្រះបន្ទូលរបស់ទ្រង់។ នេះហើយគឺជាចំណុចដែលសំខាន់។ មុនដំបូងអ្នកជឿ អាន ឬក៏ឮនូវសេចក្ដីសន្យាមួយរបស់ព្រះជាម្ចាស់ បន្ទាប់មក ព្រះវិញ្ញាណបរិសុទ្ធក៏យកសេចក្ដីសន្យានោះទៅបញ្ជ្រាបក្នុងចិត្ត និងបញ្ញាចិត្តរបស់ពួកគេដោយអង្គទ្រង់

ផ្ទាល់តែម្ដង។ អ្នកជឿនោះក៏បានភ្ញាក់ខ្លួនថា ព្រះជាម្ចាស់បានមានបន្ទូលទៅកាន់ខ្លួនគាត់ដោយផ្ទាល់។ គាត់បានរាប់សេចក្ដីសន្យារបស់ព្រះជាម្ចាស់ទុកដូចជាសេចក្ដីសន្យាដែលទ្រង់បានសម្រេចរួចទៅហើយ ទោះបីជាលោកីយ៍នេះគិតថាវាមិនអាចទៅរួចក៏ដោយ ក៏គាត់នៅតែទុកចិត្តទៅលើភាពស្មោះត្រង់របស់ព្រះជាម្ចាស់យ៉ាងអស់ពីចិត្ត។

ម្យ៉ាងវិញទៀត ព្រះវិញ្ញាណបរិសុទ្ធក៏អាចប្រើបញ្ញត្តិរបស់ទ្រង់ដើម្បីមានបន្ទូលមកកាន់យើងផងដែរ ព្រោះបញ្ញត្តិរបស់ទ្រង់មានជាប់ទាំងសេចក្ដីសន្យាផង។ ប្រសិនបើព្រះជាម្ចាស់បញ្ជា នោះយើងអាចដឹងប្រាកដថា ទ្រង់នឹងប្រទានកម្លាំងដើម្បីឲ្យយើងអាចធ្វើតាមបាន។ បើទ្រង់បញ្ជាឲ្យលោក ពេត្រុស ដើរលើទឹក នោះគាត់ដឹងយ៉ាងច្បាស់ថា ព្រះជាម្ចាស់នឹងប្រទានអំណាចឲ្យគាត់អាចដើរបានជាមិនខាន (ម៉ាថាយ ១៤:២៨)។ បើទ្រង់បញ្ជាយើងឲ្យទៅផ្សាយដំណឹងល្អដល់មនុស្សលោកទាំងអស់ នោះយើងនឹងដឹងយ៉ាងច្បាស់ថា ព្រះជាម្ចាស់នឹងប្រទានព្រះគុណដែលយើងត្រូវការមកជាមិនខាន (ម៉ាកុស ១៦:១៥)។

ជំនឿមិនមែនទាក់ទងជាមួយនឹងរឿងរ៉ាវផ្សេងៗដែលកើតឡើងជាធម្មតាដោយសារកម្លាំងមនុស្សនោះទេ ព្រោះបើកើតចេញពីកម្លាំង

មនុស្ស នោះមិនបានថ្វាយសិរីល្អដល់ព្រះជាម្ចាស់នោះឡើយ។ ជំនឿកើតមានឡើងនៅពេលដែលយើងលែងពឹងផ្អែកលើកម្លាំងខ្លួនឯង។

លោក ជច ម្យូល័រ (George Müller) បានពន្យល់ថា «*ជំនឿចាប់ផ្ដើមឡើងនៅពេលដែលភាពអាចកើតឡើងបានដោយកម្លាំងមនុស្សឈប់ដំណើរការ ហើយចក្ខុវិស័យ និងញាណរបស់មនុស្សត្រូវបាត់បង់ទៅ*»។

បើបញ្ញាពោលថា «*វាមិនអាចទៅរួចទេ*» នោះជំនឿនឹងពោលតបថា «*អត់ទេ យើងអាចធ្វើបាន!* »។ លោក ស៊ី. អេឆ. ម៉ាឃីនថស (C. H. Mackintosh) បានបញ្ជាក់យ៉ាងដូច្នេះថា៖

> ជំនឿនាំព្រះជាម្ចាស់ទៅកាន់ស្ថានភាពមួយ ហើយដឹងថាគ្មានអ្វីលំបាកទាល់តែសោះ ដោយសារទ្រង់គង់ជាជំនួយដល់យើង ហើយជំនឿក៏សើចចំអកឲ្យភាពដែលថាមិនអាចទៅរួចនោះបាន។ តាមទស្សនៈនៃជំនឿគឺថា ព្រះជាម្ចាស់គឺជាចម្លើយដ៏ធំសម្បើមជាងគេដល់គ្រប់អស់ទាំងសំណួរ ហើយក៏ជាដំណោះស្រាយដ៏ចម្បងចំពោះគ្រប់ទាំងការលំបាក។ គ្រប់យ៉ាងគឺសម្រេចនៅលើទ្រង់ ហេតុដូច្នេះហើយ នៅពេលដែលយើងមានជំនឿ មិនខ្វល់ថាយើងត្រូវការប្រាំមួយសែនដុល្លារ ឬក៏ប្រាំមួយលានដុល្លារនោះទេ ព្រោះនៅក្នុងទ្រង់មានគ្រប់ទាំងអស់។ ជំនឿគឺជាការពឹងផ្អែកលើទ្រង់ទាំងស្រុង។ អ្នកមិនមានជំនឿលើកឡើងថា៖ «តើរឿងអញ្ចឹងកើតឡើងយ៉ាង

ម៉េចបាន?» ពួកគេតែងតែលើកឡើងថា «ធ្វើយ៉ាងម៉េចបាន?» ប៉ុន្តែអ្នកដែលមានជំនឿមានចម្លើយមួយដ៏អស្ចារ្យទៅនឹងសំណួរថា «ធ្វើយ៉ាងម៉េចបាន?» ហើយព្រះជាម្ចាស់គឺជាចម្លើយនោះ។[១]

មនុស្សជឿថា លោក អ័ប្រាហាំ និងសារ៉ា មិនអាចមានកូននោះទេ តែលោក អ័ប្រាហាំ ជឿថា ព្រះជាម្ចាស់មិនអាចកុហកទេ ដោយសារទ្រង់បានសន្យារួចហើយ។

*«ដ្បិតកាលលោកអស់ទីសង្ឃឹមហើយ នោះក៏ចេះតែជឿដោយសង្ឃឹមវិញ ដើម្បីឲ្យបានត្រឡប់ជាឪពុកដល់សាសន៍ជាច្រើន ដូចសេចក្តីដែលមានបន្ទូលទុកមកថា «ពូជឯងនឹងបានដូច្នោះ» ហើយដោយព្រោះលោកមិនខ្សោយខាងសេចក្តីជំនឿ បានជាលោកមិនគិតពីរូបកាយលោក ដែលរាប់ដូចជាស្លាប់ ដោយមានអាយុប្រហែលជា១០០ឆ្នាំហើយ ឬពីផ្ទៃសារ៉ា ដែលរាប់ដូចជាស្លាប់ដែរនោះទេ លោកក៏មិនបានសង្ស័យ ចំពោះសេចក្តីសន្យារបស់ព្រះ ដោយចិត្តមិនជឿឡើយ គឺរឹតតែមានសេចក្តីជំនឿខ្លាំងឡើង ទាំងសរសើរដំកើងដល់ព្រះវិញ ហើយក៏ជឿជាក់អស់ពីចិត្តថា សេចក្តីអ្វីដែលទ្រង់សន្យា នោះអាចនឹងធ្វើឲ្យសំរេចបាន» (រ៉ូម ៤:១៨-២១)។*

*ជំនឿ ជំនឿដ៏ហានក្លា ឃើញព្រះសន្យា*
*ឃើញព្រះអង្គតែមួយ*
*ចំអកឲ្យកឡឹយភាពមិនអាចទៅរួចឡើយ*
*ជំនឿស្រែកហើយ «វានឹងសម្រេច»។*

ព្រះជាម្ចាស់នៃយើងទ្រង់អាចធ្វើគ្រប់កិច្ចការទាំងអស់ដែលមនុស្សគិតថាមិនអាចធ្វើបាន (លូកា ១:៣៧)។ គ្មានការណាលំបាកពេកសម្រាប់ទ្រង់ឡើយ (លោកុប្បត្តិ ១៨:១៤)។ «*ទ្រង់មានបន្ទូលថា ការដែលមនុស្សធ្វើមិនកើត នោះព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់*» (លូកា ១៨:២៧)។

អ្នកជឿគ្រប់រូបពឹងផ្អែកលើសេចក្ដីសន្យារបស់ទ្រង់ថា «*...បើអាចនឹងជឿបាននោះ ការទាំងអស់នឹងសម្រេចបាន ដល់អ្នកណាដែលជឿ*» (ម៉ាកុស ៩:២៣) ហើយពួកគេនិយាយជាមួយសាវ័ក ប៉ុល ថា «*ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ*» (ភីលីព ៤:១៣)។

*ភាពមន្ទិលសង្ស័យឃើញតែឧបសគ្គ*
*ជំនឿឃើញជាក់ពីមធ្យោបាយ!*
*មន្ទិលសង្ស័យឃើញតែងងឹតណាស់*
*ជំនឿផ្ទុះឃើញច្បាស់ដូចថ្ងៃចាំងចែង។*
*ភាពមន្ទិលសង្ស័យបន្លាចមិនឲ្យដើរទៅមុខ*
*ជំនឿហោះពឹបងើបឡើងលើ*
*មន្ទិលចោទសួរថា "អ្នកណាជឿ?"*
*ជំនឿឆ្លើយថា "ខ្ញុំ"។*

— មិនស្គាល់អ្នកនិពន្ធ

ពេលខ្លះ ការមានជំនឿមើលទៅដូចជា មិនសមហេតុសមផលសោះ ពីព្រោះវាទាក់ទងនឹងអធិធម្មជាតិ ក៏ដូចជាព្រះជាម្ចាស់ផងដែរ។ ការដែលលោក អ័ប្រាហាំ សម្រេចចិត្តចេញពីស្រុកកំណើតទៅទាំងមិនដឹងថា ខ្លួនគាត់ទៅទីណាផងនោះ មិនមែនមកពីវិចារណញ្ញាណរបស់គាត់ទេ ប៉ុន្តែគាត់គ្រាន់តែស្តាប់តាមបង្គាប់ព្រះជាម្ចាស់ដែលបានបញ្ជាគាត់ប៉ុណ្ណោះ (ហេព្រើរ ១១:៨)។ តាមទស្សនៈលោកីយ៍គេគិតថា លោក យ៉ូស្វេ គ្មានភាពឆ្លាតវៃសោះ ហើយលើសពីនោះទៅទៀតគេគិតថា គាត់ឆ្កួត ដោយសារគាត់បាន

ទៅច្បាំងនឹងទីក្រុងយេរីខូរដោយមិនមានអាវុធយុទ្ធភណ្ឌ ប៉ុន្តែគាត់បានវាយឈ្នះគេដោយជំនឿពិតប្រាកដមែន (យ៉ូស្វេ ៦:១-២០)។

តាមពិតទៅ ការមានជំនឿគឺជាការឆ្លាតវៃណាស់។ តើមានការណាដែលសមហេតុផលជាងការដែលមនុស្សម្នាក់ៗត្រូវតែជឿទុកចិត្តលើព្រះជាម្ចាស់ដែលបានបង្កើតពួកគេមកទៀតនោះ? តើវាឆ្កួតណាស់ទៅឬ ក្នុងការដែលយើងជឿលើព្រះដែលមិនចេះកុហក ឬធ្វើអ្វីដែលមិនខុសឆ្គងនោះ? ការទុកចិត្តលើព្រះជាម្ចាស់ គឺជាការមានសុភវិនិច្ឆ័យ មិនឆ្កួតវង្វេង និងជាការដែលសមហេតុផលបំផុតដែលមនុស្សយើងម្នាក់ៗអាចធ្វើបាន។ វាមិនមែនជាការជឿទាំងងងឹតងងុលនោះទេ្បីយ។ ជំនឿទាមទារឲ្យមានភស្តុតាងជាក់ស្តែងបំផុតដែលអាចរកឃើញបាននៅក្នុងព្រះបន្ទូលដ៏ពិតរបស់ព្រះជាម្ចាស់។ គ្មានអ្នកណាដែលជឿលើព្រះជាម្ចាស់ហើយ មិនទទួលបានប្រយោជន៍ពីទ្រង់នោះឡើយ។ ជំនឿលើព្រះអម្ចាស់មិនទាក់ទិនទៅនឹងការប្រថុយប្រថានអ្វីសោះឡើយ។

ដោយសារជំនឿជឿថា ព្រះជាម្ចាស់សោយរាជ្យលើអ្វីៗទាំងអស់ ហើយថាទ្រង់គឺជាព្រះដែលយើងអាចទុកចិត្តបាន១០០%។ ម្យ៉ាងទៀត ការគ្មានជំនឿមិនបានថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ឡើយ ដោយសារការគ្មានជំនឿចោទថាទ្រង់កុហក (១យ៉ូហាន ៥:១០)

ហើយថាព្រះជាម្ចាស់ដ៏ជាព្រះបរិសុទ្ធនៃសាសន៍អ៊ីស្រាអែលមិនអាចធ្វើអ្វីទាំងអស់បាន (ទំនុកដំកើង ៧៨:៤១)។

ជំនឿធ្វើឲ្យមនុស្សទទួលស្គាល់ថា ពួកគេត្រូវចេះបន្ទាបខ្លួននៅចំពោះព្រះលើអស់ទាំងព្រះ។

ជំនឿផ្ទុយពីការមើលឃើញផ្ទាល់នឹងភ្នែក។ សាវ័ក ប៉ុល បានក្រើនរំឭកយើងថា *«ដ្បិតយើងខ្ញុំដើរដោយសារជំនឿមិនមែនដោយសារមើលឃើញនោះទេ»* (២កូរិនថូស ៥:៧)។ ការដើរដោយការមើលឃើញមានន័យថា យើងរស់នៅដោយមានការផ្គត់ផ្គង់ដ៏ជាក់-លាក់ ហើយចេះបម្រុងទុកល្អមសម្រាប់ពេលអនាគត ព្រមទាំងការប្រើភាពវៃឆ្លាតរបស់មនុស្ស ដើម្បីធានាបាននូវការទប់ទល់នឹងគ្រោះថ្នាក់ដែលយើងអាចនឹងជួបនៅពេលខាងមុខ។ ឯការដើរដោយជំនឿមានភាពផ្ទុយគ្នាស្រឡះពីការដើរដោយមើលឃើញ។ វាគឺជាក្ដីរំពឹងថា ព្រះជាម្ចាស់នឹងផ្គត់ផ្គង់យើងជារៀងរាល់ថ្ងៃ ហើយក្ដីរំពឹងនេះគ្មានទីបញ្ចប់ឡើយ។ ខាងឯសាច់ឈាមរបស់មនុស្សយើងមិនចង់ពឹងផ្អែកលើព្រះដែលយើងមើលមិនឃើញនោះទេ។ សាច់ឈាមខិតខំរិះរកមធ្យោបាយ ដើម្បីការពារទ្រព្យសម្បត្តិរបស់លោកីយ៍មិនឲ្យបាត់បង់។ ប្រសិនបើសាច់ឈាមមិនអាចមើលឃើញផ្លូវដែលត្រូវដើរ នោះវាងាយនឹងទៅជាវិកលចរិត។ ប៉ុន្តែ ជំនឿបានបោះជំហាន

ទៅដោយការស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយមិនខ្វល់ពីគ្រប់កាលៈទេសៈ ព្រមទាំងជឿទុកចិត្តព្រះជាម្ចាស់ថាទ្រង់នឹងផ្គត់ផ្គង់គ្រប់ទាំងតម្រូវការ។

សិស្សទាំងឡាយណាដែលតាំងចិត្តដើរដោយជំនឿ ចូរចងចាំថាជំនឿរបស់ពួកគេនឹងជួបប្រទះនឹងការល្បងលជាមិនខាន។ ហើយមិនយូរមិនឆាប់ ពួកគេនឹងជួបប្រទះនឹងស្ថានភាពដែលលើសពីសមត្ថភាពរបស់ខ្លួនឯង ពេលនោះពួកគេនឹងជួបការល្បួងដែលចង់សុំជំនួយពីមនុស្សនៅជុំវិញខ្លួន។ ប៉ុន្តែប្រសិនបើពួកគេពិតជាជឿទុកចិត្តលើព្រះជាម្ចាស់ទាំងស្រុង នោះគាត់នឹងទូលសុំជំនួយពីទ្រង់តែមួយអង្គប៉ុណ្ណោះ។ លោក ស៊ី. អេឆ. ម៉ាឃីនថស (C. H. Mackintosh) បានមានប្រសាសន៍ថា៖

> ដើម្បីឲ្យសេចក្តីប្រាថ្នារបស់ខ្ញុំ បានឮសុសសាយទៅដល់មនុស្សទូទៅទាំងដោយផ្ទាល់ក្តី និងដោយប្រយោលក្តី គឺខ្ញុំត្រូវចាកចេញពីជីវិតដែលពោរពេញដោយជំនឿ ហើយបន្ទុះបង្អាប់ដល់ព្រះជាម្ចាស់ និយាយឲ្យខ្លីគឺក្បត់នឹងទ្រង់។ វាដូចទៅនឹងការដែលយើងពោលថា ព្រះជាម្ចាស់បានធ្វើឲ្យខ្ញុំបរាជ័យហើយ ដូច្នេះខ្ញុំត្រូវតែរកមនុស្សដូចគ្នាឲ្យជួយ។ វាគឺជាការបោះបង់ចោលនូវប្រភពទឹកផុសដ៏រស់ ហើយបែរទៅរកប្រភពទឹកក្រោមដីដែលខ្ទេចខ្ទាំទៅវិញ។ វាក៏ដូចជាការដែលខ្ញុំដាក់របស់ដែលព្រះជាម្ចាស់បាន

បង្កើតមកនៅចន្លោះរវាងព្រលឹងខ្ញុំនឹងព្រះជាម្ចាស់ ការធ្វើដូច្នេះឃាំងមិនឲ្យព្រះពររបស់ព្រះជាម្ចាស់ហូរមកដល់ខ្ញុំបាន ហើយក៏មិនបានថ្វាយសិរីរុងរឿងដល់ទ្រង់ដែរ។[២]

អាកប្បកិរិយាធម្មតារបស់សិស្សព្រះយេស៊ូវគឺត្រូវមានបំណងចិត្តបង្កើនជំនឿរបស់ខ្លួន (លូកា ១៧:៥)។ ពួកគេបានទុកចិត្តលើព្រះគ្រីស្ទដើម្បីឲ្យបានសង្គ្រោះរួចទៅហើយ។ បន្ទាប់មក ពួកគេខិតខំបង្កើនការចុះចូលក្រោមការគ្រប់គ្រងរបស់ព្រះជាម្ចាស់លើជីវិតរបស់ពួកគេបន្ថែមទៀត។ ពួកគេកាន់តែស្គាល់ព្រះជាម្ចាស់ និងកាន់តែមានភាពស្និទ្ធស្នាល ហើយជំនឿកាន់តែរឹងប៉ឹងឡើង នៅពេលដែលពួកគេប្រឈមមុខនឹងជំងឺ ការល្បួងល សោកនាដកម្ម និងការដកយកជីវិតអ្នកជាទីស្រឡាញ់។ ពួកគេបង្ហាញពីសេចក្តីពិតដែលមានចែងនៅក្នុងកណ្ឌគម្ពីរ ហូសេ ៦:៣ ថា «ចូរឲ្យយើងបានស្គាល់ព្រះយេហូវ៉ាចុះ ហើយមានព្យាយាមនឹងស្គាល់ទ្រង់តទៅ»។ នៅពេលដែលពួកគេកាន់តែឃើញថា ព្រះជាម្ចាស់គួរឲ្យទុកចិត្ត នោះពួកគេក៏កាន់តែចង់ទុកចិត្តទ្រង់លើការធំផ្សេងៗទៀតដែរ។

បំណងប្រាថ្នារបស់សិស្សព្រះយេស៊ូវគួរតែជាការបញ្ជ្រាបនូវព្រះបន្ទូលឲ្យបានសុសសាយពេញក្នុងខ្លួនរបស់ពួកគេ ដោយការ

អានព្រះគម្ពីរ ការសិក្សាស្វាធ្យាយ ការទន្ទេញខគម្ពីរឲ្យចាំរត់មាត់ ព្រមទាំងសញ្ជឹងគិតព្រះបន្ទូលទាំងយប់ទាំងថ្ងៃ ដោយដឹងថា ជំនឿកើតឡើងដោយការឮព្រះបន្ទូល ហើយការឮនោះកើតមកពីការប្រកាសព្រះបន្ទូលរបស់ទ្រង់។ ព្រះបន្ទូលគឺជាគំនូសតាង និងជាត្រីវិស័យរបស់ពួកគេ ហើយក៏ជាមគ្គុទ្ទេសក៏ ជាការកម្សាន្តចិត្ត ហើយក៏ជាចង្កៀង និងពន្លឺរបស់ពួកគេផងដែរ។

ការរស់នៅដោយជំនឿតែងតែមាននូវចន្លោះប្រហោងក្នុងការរីកចម្រើនទៅមុខជានិច្ច។ នៅពេលដែលយើងអាននូវអ្វីៗដែលសម្រេចបានតាមរយៈជំនឿក្នុងព្រះគម្ពីរ នោះយើងនឹងដឹងថា យើងប្រៀបបាននឹងកូនក្មេងមិនទាន់ដឹងក្ដីដែលលេងក្បែរឈូងសមុទ្រដ៏ធំគ្មានកោះត្រើយយ៉ាងដូច្នោះដែរ។ កណ្ឌគម្ពីរ ហេព្រើរជំពូក១១ មានចែងពីរឿងដ៏អស្ចារ្យទាក់ទងនឹងជំនឿ។ ជំពូកនៃខគម្ពីរទាំងនេះបានរំលេចឡើងនូវចំណុចដែលគួរចាប់អារម្មណ៍ចាប់ពីខ៣២-៤០ ដែលមានដូចខាងក្រោម៖

តើខ្ញុំអាចនិយាយអ្វីទៀតបាន? ខ្ញុំមិនមានពេលនឹងនិយាយអំពីរឿងលោក គេឌាន លោក បារ៉ាក់ លោក សាំសុន លោក យ៉ែបថា ព្រះបាទ ដាវីឌ លោក សាំយូអែល និងព្យាការីនានាទេ។ ដោយសារជំនឿ លោកទាំងនោះបានច្បាំងនឹងនគរផ្សេងៗ បានប្រព្រឹត្តអំពើសុចរិត បានទទួលអ្វីៗដែល

ព្រះជាម្ចាស់សន្យាប្រទានឲ្យបានបិទមាត់សឹង្ហ បានពន្លត់ភ្លើងដែលឆេះសន្ធោសន្ធៅ បានគេចផុតពីមុខដាវ មានកម្លាំងឡើងវិញនៅពេលធ្លាក់ខ្លួនឈឺ ខ្លាំងពូកែនៅពេលច្បាំង ធ្វើឲ្យខ្មាំងសត្រូវបាក់ទ័ព។ ស្ត្រីៗបានឃើញក្រុមគ្រួសាររបស់ខ្លួនដែលស្លាប់ទៅហើយនោះ មានជីវិតរស់ឡើងវិញ។ អ្នកខ្លះសុខចិត្តឲ្យគេធ្វើទារុណកម្ម មិនព្រមឲ្យនរណាដោះលែងឡើយ ដើម្បីឲ្យបានជីវិតរស់ឡើងវិញក៏ប្រសើរជាង។ អ្នកខ្លះទៀតសុខចិត្តឲ្យគេចំអកឡកឡឺយ ឲ្យគេវាយដំ ហើយថែមទាំងឲ្យគេដាក់ច្រវាក់ឃុំឃាំងថែមទៀតផង។ អ្នកខ្លះត្រូវគេយកដុំថ្មគប់សម្លាប់ ត្រូវគេសម្លាប់ដោយអារនឹងរណារ ត្រូវគេសម្លាប់ដោយមុខដាវ ត្រូវរសាត់អណ្តែតពីកន្លែងមួយទៅកន្លែងមួយ មានតែស្បែកចៀម និងស្បែកពពែបិទបាំងខ្លួន ខ្វះខាតសព្វគ្រប់ទាំងអស់ ហើយត្រូវគេជិះជាន់សង្កត់សង្កិនធ្វើបាបថែមទៀតផង។ លោកីយ៍ពុំស័ក្តិសមនឹងឲ្យអ្នកនោះរស់នៅជាមួយឡើយ ដូច្នេះ គេទៅរស់នៅតែលតោលតាមវាលរហោស្ថាន តាមភ្នំ តាមរូងភ្នំ និងតាមល្អាងភ្នំ។ ទោះបីអ្នកទាំងនោះទទួលសក្ខីភាពល្អ ព្រោះតែជំនឿរបស់ខ្លួនក្តី ក៏គេពុំបានទទួលអ្វីៗតាមព្រះបន្ទូលសន្យាដែរ។ ដោយព្រះជាម្ចាស់គ្រោងទុកថានឹងប្រទានអ្វីៗដ៏ល្អប្រសើរមកយើង ទ្រង់ពុំបានប្រោសអ្នកទាំងនោះឲ្យបានគ្រប់លក្ខណៈមុនយើងឡើយ (គខប)។

បណ្ដាំចុងក្រោយ៖ យើងបានលើកឡើងហើយថា លោកីយ៍នឹងចាត់ទុកសិស្សរបស់ព្រះយេស៊ូវដែលដើរដោយជំនឿថា ពួកគេជាមនុស្សមមើមមាយ និងជាមនុស្សងប់ងុលនឹងជំនឿ សូម្បីតែអ្នកដែលហៅខ្លួនថាគ្រីស្ទបរិស័ទក៏គិតដូច្នោះដែរ។ ជាការល្អ បើយើងចងចាំពីសម្ដីរបស់លោក ស៊ី. អេឆ. ម៉ាឃីនថស (C. H. Mackintosh) ដែលថា «*បុគ្គលម្នាក់អាចដើរជាមួយព្រះជាម្ចាស់ដោយសារជំនឿ ហើយជំនឿនោះនឹងធ្វើឲ្យអ្នកនោះមិនរវីរវល់នឹងការរិះគន់របស់លោកីយ៍*»។

### ជំពូកទី៧

# ការអធិស្ឋាន

សៀវភៅតែមួយគត់ដែលធ្លាប់ទទួលបានភាពពេញនិយមតាំងពីដើមរៀងមកទាក់ទិននឹងប្រធានបទនៃការអធិស្ឋាននោះគឺ ព្រះគម្ពីរ។ សៀវភៅទាំងអស់ដែលទាក់ទិននឹងការអធិស្ឋានស្ទើរតែធ្វើឲ្យអ្នកអានមានអារម្មណ៍ថាវាមិនទាន់គ្រប់គ្រាន់ទេ ព្រោះអ្នកនិពន្ធមិនទាន់និយាយឲ្យបានគ្រប់ជ្រុងជ្រោយ ហើយក៏មិនទាន់បានថ្លឹងថ្លែងឲ្យច្បាស់លាស់ពីការអធិស្ឋាននៅឡើយដែរ។ ក៏ដូចគ្នាដែរនៅក្នុងសៀវភៅដ៏ខ្លីនេះ យើងមិនមែនចង់បង្ហាញថា វាល្អជាងសៀវភៅរបស់អ្នកនិពន្ធផ្សេងៗទៀតនោះឡើយ។ ការដែលយើងអាចធ្វើទៅបាននោះគឺគ្រាន់តែសង្ខេបគោលការណ៍សំខាន់ខ្លះៗនៃការអធិស្ឋានជាពិសេសដូចជាការអធិស្ឋានដែលទាក់ទងទៅនឹងភាពជាសិស្សរបស់ព្រះយេស៊ូវ។

ការអធិស្ឋានដែលល្អបំផុតកើតឡើងនៅពេលដែលយើងមានទុក្ខព្រួយ។ យើងគ្រប់គ្នាបានទទួលស្គាល់ហើយថា នេះគឺជាការ

ពិតមែន ដោយសារតែយើងបានដកពិសោធន៍នឹងការនេះហើយ។ នៅពេលណាដែលជីវិតរបស់យើងស្ងប់ស្ងៀមមិនមានជាបញ្ហាអ្វី នោះការអធិស្ឋានរបស់យើងមិនសូវមានភាពមុតស្រួច ហើយមិនអស់ពីចិត្តសោះ។ តែនៅពេលណាដែលយើងជួបប្រទះវិបត្តិអ្វីមួយ ដូចជាពេលមានគ្រោះថ្នាក់ ពេលមានជំងឺធ្ងន់ធ្ងរ ឬការបាត់បង់អ្នកជាទីស្រឡាញ់ នោះសេចក្ដីអធិស្ឋានរបស់យើងនឹងពោរពេញដោយភាពឆេះឆួល និងពុះកញ្ជ្រោលបំផុត។ មានសុភាសិតមួយពោលថា «ដើម្បីឲ្យគ្រាប់ព្រួញចូលទៅកាន់នគរស្ថានសួគ៌បាន អ្នកត្រូវតែឃឹតធ្នូបាញ់ពេញមួយទំហឹង»។ សេចក្ដីអធិស្ឋានដែលល្អកើតមានឡើងនៅពេលណាដែលស្មារតីរបស់យើងស្ថិតក្នុងភាពបន្ទាន់ ភាពទន់ខ្សោយ និងនៅពេលមានតម្រូវការជាបន្ទាន់។

ជាអកុសល យើងចំណាយពេលជាច្រើនក្នុងជីវិតរបស់យើងដើម្បីកុំឲ្យមានការខ្វះខាត។ យើងបានបម្រុងទុកលុយជាមុន ដោយប្រើយុទ្ធសាស្ត្រជំនួញដ៏ឈ្លាសវៃ ដើម្បីទប់ស្កាត់រាល់អន្តរាយដែលអាចកើតមានឡើង។ យើងបានប្រើប្រាជ្ញាដ៏ស្ទួចស្ទើងរបស់យើងដើម្បីប្រមូលទ្រព្យសម្បត្តិ ឲ្យបានក្លាយជាអ្នកមាន។ បន្ទាប់មកយើងឆ្ងល់ថា *«ម៉េចបានជាការអធិស្ឋានរបស់ខ្ញុំមិនមានភាពស្និទ្ធស្នាល ហើយដូចជាគ្មានជីវិតសោះ?»* ហើយថា *«ម៉េចបានជាគ្មានភ្លើង*

*ធ្លាក់មកពីស្ថានសួគ៌យ៉ាងដូច្នេះ?»* (១ពង្សាវតាក្សត្រ ១៨:៣៦-៣៨)។ ប្រសិនបើយើងពិតជាដើរដោយជំនឿ មិនមែនដោយការមើលឃើញមែន នោះការអធិស្ឋានរបស់យើងពិតជានឹងមានការផ្លាស់ប្តូរជាខ្លាំងមិនខាន។

លក្ខខណ្ឌមួយនៃការអធិស្ឋានដ៏ជោគជ័យនោះគឺ យើងត្រូវ *«ចូលទៅជិតទាំងមានចិត្តស្មោះត្រង់»* (ហេព្រើរ ១០:២២)។ នេះមានន័យថា យើងត្រូវតែទៀងត្រង់ ហើយស្មោះចំពោះព្រះអម្ចាស់។ ដាច់ខាតមិនត្រូវមានការលាក់ពុតអ្វីឡើយ។ ដើម្បីបំពេញនូវលក្ខខណ្ឌនេះបាន យើងនឹងមិនទូលសូមព្រះជាម្ចាស់ឲ្យធ្វើអ្វីមួយដែលយើងអាចធ្វើបានដោយខ្លួនឯងនោះទេ។ ឧទាហរណ៍ថា យើងនឹងមិនទូលសូមទ្រង់ឲ្យធ្វើការក្នុងចិត្តមនុស្សផ្សេងៗដើម្បីផ្តល់មូលនិធិទុកសម្រាប់ព័ន្ធកិច្ចគ្រីស្ទបរិស័ទឡើយ បើយើងផ្ទាល់មានលុយល្មមដើម្បីផ្គត់ផ្គង់ដល់ព័ន្ធកិច្ចនោះទាំងអស់រួចហើយ។ យើងមិនអាចបោកបញ្ឆោតព្រះជាម្ចាស់បានទេ។ បើយើងសូមលុយ១000ដុល្លារពីព្រះអង្គយកទៅប្រើប្រាស់ក្នុងព័ន្ធកិច្ច ខណៈពេលទ្រង់បានប្រទានលុយនោះមកយើងរួចទៅហើយមុនដែលយើងសូម តែយើងគ្មានឆន្ទៈនឹងប្រើលុយនោះសម្រាប់ព័ន្ធកិច្ចសោះ នោះទ្រង់នឹងមិនប្រទានលុយម្តងទៀតឡើយ។

ទាក់ទងនឹងរឿងនេះដែរ យើងមិនគួរណាអធិស្ឋានសូមព្រះជាម្ចាស់ប្រទានអ្នកដទៃទៀតឲ្យមកបំពេញបេសកកម្មរបស់ទ្រង់ឡើយ បើយើងមិនហ៊ាននឹងទៅដោយខ្លួនឯងផងនោះ។ មានមនុស្សរាប់ពាន់នាក់បានអធិស្ឋានសូមព្រះជាម្ចាស់សង្គ្រោះ ពួកអ្នកកាន់សាសនាអ៊ីស្លាម ពួកអ្នកកាន់សាសនាហិណ្ឌូ និងអ្នកកាន់ពុទ្ធសាសនា។ ប៉ុន្តែប្រសិនបើអស់អ្នកដែលបានអធិស្ឋានទាំងអស់នោះ ហ៊ានទៅឈោងចាប់អស់អ្នកដែលខ្លួនបានអធិស្ឋានឲ្យវិញនោះ នោះប្រហែលប្រវត្តិសាស្ត្រនៃបេសកកម្មរបស់គ្រីស្ទបរិស័ទនឹងមានដំណើរការប្រសើរជាងសព្វថ្ងៃនេះទៅទៀត។

យើងគួរតែអធិស្ឋានបែបសាមញ្ញៗដោយជំនឿ ហើយមានចិត្តចុះចូលនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ យើងងាយនឹងជក់ចិត្តទៅនឹងបញ្ហាផ្នែកទេវវិទ្យាដែលទាក់ទងនឹងការអធិស្ឋាន។ ហើយការជក់ចិត្តទៅនឹងបញ្ហាផ្នែកទេវវិទ្យាធ្វើឲ្យមានតែសឹករិចរិលខាងវិញ្ញាណប៉ុណ្ណោះនោះទេ។ ការអធិស្ឋានប្រសើរជាងការដែលយើងព្យាយាមដោះស្រាយរាល់បញ្ហា ឬអាថ៌កំបាំងផ្សេងៗទាក់ទងនឹងការអធិស្ឋានទៅទៀត។ សូមអនុញ្ញាតឲ្យបណ្ឌិតផ្នែកទេវវិទ្យាជាអ្នកផ្ដល់ទ្រឹស្ដីទាក់ទងនឹងអាថ៌កំបាំងនៃការអធិស្ឋានចុះ។ ប៉ុន្តែសូមឲ្យអ្នកជឿអធិស្ឋានដល់ព្រះជាម្ចាស់ដោយជំនឿដូច

កូនក្មេងជឿទុកចិត្តលើឪពុកម្តាយពួកគេយ៉ាងដូច្នោះដែរ។ លោកអូគូស្ទីន (Augustine) បានលើកឡើងថា *«អក្ខរជនខំប្រឹងចាប់យកនគរស្ថានសួគ៌ ហើយពួកគេក៏យកបាន តែយើងដែលជាបណ្ឌិតភាគច្រើនរវល់តែគិតពីរឿងជីវិតនេះទៅវិញ»*។

*ទោះមានវិធីសាស្ត្រកម្រយ៉ាងណា*
*ខ្ញុំដឹងច្បាស់ថាព្រះទ្រង់នឹងឆ្លើយតប*
*ទោះមិនដឹងពេលព្រះបន្ទូលទ្រង់មក*
*ប្រាប់យើងកោកៗថាទ្រង់បានឮ។*
*ខ្ញុំដឹងថាគង់មកដល់យូរឬឆាប់*
*ខ្ញុំត្រូវត្រងត្រាប់អធិស្ឋានចាំយាម*
*បើខ្ញុំមិនដឹងព្រះពរនឹងមកភ្លាម*
*នឹងមកដល់តាមព្រះទ័យនៃព្រះអង្គ។*
*ពេលនេះខ្ញុំសូមថ្វាយពាក្យអធិស្ឋាន*
*ថ្វាយដល់ទ្រង់បានថ្វាយទ្រង់តែមួយគត់*
*ដ្បិតព្រះប្រាជ្ញាទ្រង់ជ្រៅពិតប្រាកដ*
*ជ្រៅផុតកំណត់ថ្លៃថ្លាជាងរូបខ្ញុំ។*

— លោកស្រី ឡូឡា ហេនសិន
(Lola Henson)

បើលោកអ្នកចង់ឲ្យការអធិស្ឋានមានអំណាចដ៏ពិត នោះចូរអធិស្ឋានឲ្យអស់ពីចិត្តចុះ។ ហើយសូមចុះចូលចំពោះព្រះគ្រីស្ទទាំងស្រុង។ ចូរធ្វើគ្រប់ទាំងអស់ថ្វាយទ្រង់។ ចូរលះអាល័យគ្រប់ទាំងអស់ ដើម្បីដើរតាមទ្រង់។ ព្រះជាម្ចាស់សព្វព្រះហឫទ័យដល់អស់អ្នកណាដែលមានភក្តីភាពចំពោះព្រះគ្រីស្ទណាស់ ដោយសារពួកគេទទួលយកទ្រង់មកធ្វើជាព្រះអម្ចាស់លើអ្វីៗទាំងអស់។

ពេលដែលយើងលះបង់អ្វីមួយ ដើម្បីនឹងអធិស្ឋាន ព្រះជាម្ចាស់ហាក់បីដូចជាឲ្យតម្លៃយ៉ាងពិសេសលើការអធិស្ឋានរបស់យើង។ អស់អ្នកដែលក្រោកពីព្រលឹមនឹងមានការប្រកបយ៉ាងស្និទ្ធស្នាលជាមួយព្រះយេស៊ូវដែលតើនពីព្រលឹមកាលដែលទ្រង់គង់នៅផែនដីនេះ ដើម្បីឲ្យដឹងថាព្រះវរបិតាសព្វព្រះហឫទ័យឲ្យទ្រង់ធ្វើអ្វីនៅថ្ងៃហ្នឹង (ម៉ាកុស ១:៣៥)។

ដូចគ្នានេះដែរ អស់អ្នកណាដែលស្រវាស្រទេញយ៉ាងស្មោះអស់ពីចិត្តនឹងអធិស្ឋានពេញមួយយប់ អ្នកនោះនឹងបានប្រកបដោយអំណាចដ៏ពិសេសជាមួយព្រះជាម្ចាស់ជាមិនខាន។ ការអធិស្ឋានដែលមិនមានការលះបង់អ្វីសោះនោះគ្មានតម្លៃអ្វីទេ ព្រោះការអធិស្ឋានបែបនោះចេញមកពីអ្នកជឿក្លែងក្លាយដែលគ្មានតម្លៃ។

ជារឿយៗយើងឃើញថា អ្នកនិពន្ធកណ្ឌគម្ពីរសញ្ញាថ្មីតែងតែ

ភ្ជាប់ការអធិស្ឋានទៅនឹងការតមអាហារ។ ការតមអាហារអាចជាជំនួយដ៏មានតម្លៃមួយក្នុងការហ្វឹកហ្វឺនជំនឿខាងវិញ្ញាណ។ ការតមអាហារអាចជួយយើងឲ្យមានគំនិតភ្លឺថ្លា ផ្តោតអារម្មណ៍កាន់តែច្បាស់ ហើយឲ្យយើងកាន់តែមានភាពរៀសរវ៉ៃ។ តែចំពោះទស្សនៈរបស់ព្រះជាម្ចាស់វិញ ហាក់បីដូចជាទ្រង់មានបំណងព្រះហឫទ័យពិសេសក្នុងការឆ្លើយតបនឹងការអធិស្ឋាន នៅពេលដែលយើងឲ្យតម្លៃលើការអធិស្ឋានសំខាន់ជាងអាហារ។

កុំអធិស្ឋានបែបអាត្មានិយម។ *«អ្នករាល់គ្នាក៏សូមដែរ តែមិនបានទេដ្បិតសេចក្តីសំណូមនោះបែបអាក្រក់ សំរាប់នឹងចាយបំពេញសេចក្តីសំរើបរបស់អ្នករាល់គ្នាវិញ»* (យ៉ាកុប ៤:៣)។ នៅពេលដែលយើងអធិស្ឋានយើងគួរតែអធិស្ឋានសូមឲ្យព្រះហឫទ័យរបស់ទ្រង់បានសម្រេច។ ជាដំបូងយើងគួរតែអធិស្ឋានថា *«...សូមឲ្យរាជ្យទ្រង់បានមកដល់ សូមឲ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដីដូចនៅស្ថានសួគ៌ដែរ»* បន្ទាប់មក យើងអាចបន្ថែមដូចជា *«សូមប្រទានអាហារដែលយើងខ្ញុំត្រូវការមកជារាល់ថ្ងៃ»* (លូកា ១១:២-៣)។

យើងគួរតែថ្វាយកិត្តិនាមដល់ព្រះជាម្ចាស់ដោយទូលសូមការអស្ចារ្យពីទ្រង់ ព្រោះទ្រង់គឺជាព្រះដ៏អស្ចារ្យក្រៃលែង។ ចូរយើងទាំងអស់គ្នាមានជំនឿក្នុងការរំពឹងចាំការអស្ចារ្យពីព្រះជាម្ចាស់។

*ចូលមកទៅគាល់ស្តេច*
*ទូលអង្វរគ្រប់កិច្ចដល់អង្គក្សត្រា*
*សេចក្តីស្រឡាញ់ និងឫទ្ធីចេស្តា*
*គ្មានអ្វីឡើយណាធំលើសទ្រង់ឡើយ។*

— លោក ចន ញ៉ូថិន
(John Newton)

តើការដែលយើងមិនហ៊ានពឹងសុំការអស្ចារ្យពីព្រះអម្ចាស់ នោះនឹងធ្វើឲ្យទ្រង់ព្រួយព្រះហឫទ័យខ្លាំងប៉ុណ្ណា? យើងស្កប់ចិត្តជាមួយនឹងជ័យជម្នះដ៏ស្តួចស្តើងជាមួយនឹងការទទួលផលដែលមិនសូវល្អ ជាមួយនឹងចំណាប់អារម្មណ៍ដ៏ខ្សត់ខ្សោយក្នុងការចង់បានអ្វីៗដ៏អស្ចារ្យ ដូច្នេះអស់អ្នកដែលនៅជុំវិញយើងមិនគិតថា ព្រះជាម្ចាស់នៃយើងជាព្រះដ៏អស្ចារ្យបំផុតនោះទេ។ យើងមិនបានថ្វាយសិរីល្អដល់ទ្រង់នៅមុខមនុស្សដទៃដែលមិនស្គាល់ទ្រង់សោះ ពីព្រោះជីវិតរស់នៅរបស់យើង មិនបានធ្វើឲ្យពួកគេចាប់អារម្មណ៍ ហើយក៏មិនបានធ្វើឲ្យពួកគេចង់សួរនាំពីអំណាចដែលទ្រទ្រង់ជីវិតយើងនោះដែរ។ ជារឿយៗ ការនេះមិនមានបញ្ជាក់អំពីយើងរាល់គ្នាដូចពួកសាវ័កដែលបាននិយាយថា *“គេក៏នាំគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះតែខ្ញុំ”* (កាឡាទី ១:២៤)។ — អ៊ី. ដាប់ប៊ិលយូ. ម័រ (E. W. Moore)

នៅពេលដែលយើងអធិស្ឋាន យើងគួរពិចារណាថា តើយើងកំពុងស្ថិតក្នុងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឬអត់? បន្ទាប់មកយើងគួរតែអធិស្ឋាន ហើយជឿថា ទ្រង់នឹងជ្រាបហើយនឹងឆ្លើយ-តប។ «ហេតុនេះហើយបានជាយើងមានចិត្តរឹងប៉ឹងនៅចំពោះព្រះភក្ត្រព្រះអង្គ គឺថា ប្រសិនបើយើងទូលសូមអ្វី ស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះទ្រង់នឹងព្រះសណ្ដាប់យើងជាមិនខាន។ បើយើងដឹងថា ព្រះអង្គទ្រង់ព្រះសណ្ដាប់យើង ទោះបីយើងទូលសូមអ្វីពីព្រះអង្គក៏ដោយ យើងដឹងថា យើងបានទទួលអ្វីៗដែលយើងទូលសូមនោះរួចហើយ» (១យ៉ូហាន ៥:១៤-១៥ គខប)។

ការអធិស្ឋានដោយនូវព្រះនាមព្រះយេស៊ូវមានន័យថា អធិស្ឋានស្របតាមព្រះហឫទ័យទ្រង់។ នៅពេលដែលយើងពិតជាអធិស្ឋានក្នុងព្រះនាមទ្រង់ នោះក៏ដូចជាទ្រង់កំពុងតែទូលសូមដល់ព្រះវរបិតារបស់ទ្រង់ដែរ។ «ហើយការអ្វីក៏ដោយ ដែលអ្នករាល់គ្នានឹងសូមដោយនូវឈ្មោះខ្ញុំ នោះខ្ញុំនឹងសំរេចឲ្យ ដើម្បីឲ្យព្រះវរបិតាបានដំកើងឡើងក្នុងព្រះរាជបុត្រា បើអ្នករាល់គ្នានឹងសូមអ្វីដោយនូវឈ្មោះខ្ញុំ នោះខ្ញុំនឹងសំរេចឲ្យ» (យ៉ូហាន ១៤:១៣-១៤)។ «នៅថ្ងៃនោះ អ្នករាល់គ្នានឹងមិនសូមអ្វីពីខ្ញុំទៀត ប្រាកដមែនខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្វីៗ ដែលអ្នករាល់គ្នានឹងសូមដល់ព្រះវរបិតា ដោយនូវ

ឈ្មោះខ្ញុំ នោះទ្រង់នឹងប្រទានឲ្យ (យ៉ូហាន ១៦:២៣)។ *“មួយទៀត ខ្ញុំប្រាប់ថា បើសិនជាមាន២នាក់ក្នុងពួកអ្នករាល់គ្នា ព្រមព្រៀងគ្នា នៅផែនដី ពីដំណើរអ្វីដែលគេចង់សូមក៏ដោយ នោះនឹងបានសំរេច ដល់គេ អំពីព្រះវរបិតាខ្ញុំ ដែលគង់នៅស្ថានសួគ៌ ដ្បិតកន្លែងណា ដែលមាន២ឬ៣នាក់ ប្រជុំជាមួយគ្នា ដោយនូវឈ្មោះខ្ញុំ នោះខ្ញុំក៏ នៅកណ្តាលចំណោមអ្នកទាំងនោះដែរ”* (ម៉ាថាយ ១៨:១៩-២០)។

ការទូលសូម *“ដោយនូវព្រះនាមទ្រង់”* មានន័យថា ទ្រង់កាន់ដៃយើង ហើយនាំយើងក្នុងការអធិស្ឋាន ហើយក៏ដូចជាទ្រង់កំពុងតែលុតព្រះជង្ឃជាមួយយើង ឯបំណងព្រះហឫទ័យរបស់ទ្រង់ក៏កំពុងតែហូរចេញចូលក្នុងចិត្តរបស់យើងផងដែរ។ នេះហើយគឺជាអត្ថន័យនៃឃ្លាថា *“ដោយនូវព្រះនាមទ្រង់”*។ ព្រះនាមទ្រង់គឺជាលក្ខណសម្បត្តិរបស់ទ្រង់ ហេតុដូច្នេះហើយ ការអធិស្ឋានក្នុងព្រះនាមព្រះគ្រីស្ទពិតជាមានន័យថា យើងកំពុងតែអធិស្ឋានផ្អែកតាមបំណងព្រះហឫទ័យដែលពេញដោយព្រះពររបស់ទ្រង់។ តើខ្ញុំអាចអធិស្ឋានសុំការអាក្រក់ក្នុងព្រះនាមព្រះរាជបុត្រាបានដែរឬទេ? ការដែលខ្ញុំអធិស្ឋានសុំគួរតែជាការបញ្ជាក់អំពីលក្ខណសម្បត្តិរបស់ទ្រង់។ តើខ្ញុំអាចអធិស្ឋានបែបនេះបានដែរឬទេ? ការអធិស្ឋានរបស់យើងគួរតែបញ្ចេញអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធ ព្រះប្រាជ្ញាញាណរបស់ព្រះគ្រីស្ទ និងបំណងព្រះហឫទ័យ

របស់ព្រះគ្រីស្ទសម្រាប់យើង។ ព្រះអម្ចាស់បង្រៀនយើងម្តងហើយម្តងទៀត ពីការអធិស្ឋានក្នុងព្រះនាមទ្រង់។ យើងគួរបញ្ចប់សេចក្តីអធិស្ឋានដោយពោលពាក្យថា *"ក្នុងព្រះនាមដែលពោរពេញដោយព្រះពរ"* ឯការទទូចសុំរបស់យើងគួរតែបានពោរពេញដោយព្រះនាមព្រះយេស៊ូវ ហើយទូលសូមអ្វីគ្រប់យ៉ាងដោយនូវព្រះនាមទ្រង់។

— លោក សាំយ៉ូអែល រីដៅថ៍
(Samuel Ridout)

ប្រសិនបើការអធិស្ឋានរបស់យើងពិតជាមានប្រសិទ្ធភាពមែននោះ  កុំឲ្យយើងលាក់បាំងអំពើបាបរបស់យើងនឹងព្រះជាម្ចាស់ឡើយ។ នេះមានន័យថា យើងត្រូវតែលន់តួបាប ហើយជំរុះវាចោលនៅពេលដែលយើងដឹងខ្លួនថា យើងបានធ្វើបាប។ *"បើសិនជាខ្ញុំឃើញមានសេចក្តីទុច្ចរិតនៅក្នុងចិត្ត នោះព្រះអម្ចាស់ទ្រង់ មិនព្រមស្តាប់ខ្ញុំទេ"* (ទំនុកដំកើង ៦៦:១៨)។ យើងត្រូវតែនៅជាប់នឹងព្រះគ្រីស្ទ *"បើអ្នករាល់គ្នានៅជាប់នឹងខ្ញុំ ហើយពាក្យខ្ញុំនៅជាប់ក្នុងអ្នករាល់គ្នានោះ ចូរសូមអ្វីតាមតែប្រាថ្នាចុះ សេចក្តីនោះនឹងបានសំរេចដល់អ្នករាល់គ្នាជាមិនខាន"* (យ៉ូហាន ១៥:៧)។ អ្នកដែលនៅជាប់នឹងព្រះគ្រីស្ទ នោះក៏នៅប្រកៀកនឹងទ្រង់ដែរ ហើយដោយសារគាត់នៅប្រកៀកដូចនេះ បានជាគាត់ស្គាល់ព្រះហឫទ័យទ្រង់យ៉ាងច្បាស់-

លាស់ដែរ។ គាត់អាចអធិស្ឋានដោយស្របតាមព្រះហឫទ័យរបស់ទ្រង់ ដោយដឹងប្រាកដថា គាត់នឹងទទួលបានចម្លើយពីព្រះជាម្ចាស់។ ជីវិតដែលនៅជាប់នឹងព្រះគ្រីស្ទ ទាមទារឲ្យយើងធ្វើតាមបញ្ញត្តិរបស់ទ្រង់។ *«ហើយទោះបើយើងសូមអ្វីពីទ្រង់ក៏ដោយ គង់តែនឹងបានសំរេច ពីព្រោះយើងកាន់តាមបញ្ញត្តិទ្រង់ហើយក៏ប្រព្រឹត្តការដែលគាប់ព្រះហឫទ័យដល់ទ្រង់ដែរ»* (១យ៉ូហាន ៣:២២)។ ប្រសិនបើយើងចង់ឲ្យព្រះជាម្ចាស់ព្រះសណ្ដាប់ ហើយឆ្លើយតបនឹងសំណូមពរអធិស្ឋានរបស់យើង នោះយើងត្រូវតែរក្សាទំនាក់ទំនងរបស់យើងជាមួយទ្រង់ឲ្យបានល្អ (១យ៉ូហាន ៣:២០)។

យើងមិនគួរអធិស្ឋានតែនៅពេលជាក់លាក់ដែលបានគ្រោងទុកប្រចាំថ្ងៃនោះទេ តែយើងគួរតែអភិវឌ្ឍអាកប្បកិរិយានៃការអធិស្ឋានដើម្បីឲ្យយើងអាចដើរជាមួយព្រះជាម្ចាស់ជាប់ជានិច្ចទាំងពេលដែលយើងកំពុងដើរតាមផ្លូវពេលកំពុងបើកបរ ពេលកំពុងធ្វើការ ក៏ដូចជាពេលដែលយើងជួយធ្វើការងារផ្ទះ។ លោក នេហេមា គឺជាគំរូដ៏ល្អនៃការអធិស្ឋានបែបនេះ ដោយសារគាត់មានទម្លាប់ក្នុងការសម្រេចចិត្តអធិស្ឋានយ៉ាងឆាប់រហ័សច្រើនដង (នេហេមា ២:៤)។ ការ *«...នៅជាប់ក្នុងទីកំបាំងនៃព្រះដ៏ខ្ពស់បំផុត...»* គឺជាការល្អ (ទំនុកដំកើង ៩១:១) ជាជាងការដែលយើងចូលទៅចំពោះព្រះជាម្ចាស់ម្ដងម្កាល។

ជាទីបញ្ចប់ ការអធិស្ឋានរបស់យើងគួរតែមានភាពច្បាស់លាស់។ យើងអាចឃើញការឆ្លើយតបរបស់ព្រះជាម្ចាស់យ៉ាងជាក់លាក់ មានតែនៅពេលដែលយើងអធិស្ឋានឲ្យចំៗតែប៉ុណ្ណោះ។

ការអធិស្ឋាន គឺជាអភ័យឯកសិទ្ធិដ៏អស្ចារ្យមួយ។ លោក ហ៊ដ-សិន ថេល័រ (Hudson Taylor) បានមានប្រសាសន៍ថា យោងតាមអភ័យឯកសិទ្ធិនេះ យើងអាចបំផ្លាស់បំប្រែមនុស្សតាមរយៈព្រះជាម្ចាស់បាន។

> អូ៎! យើងពិតជាមានឱកាសធ្វើការអស្ចារ្យដ៏ធំក្រៃលែង តាមរយៈការអធិស្ឋានមែន។ តាមរយៈការអធិស្ឋាន យើងអាចបង្វែរពន្លឺព្រះអាទិត្យដែលរះចិញ្ចែងចិញ្ចាចឲ្យទៅកន្លែងត្រជាក់ល្ហឹមបាន។ យើងអាចអុជបំភ្លឺចង្កៀងនៃសេចក្តីសង្ឃឹមនៅក្នុងគុកនៃភាពអស់សង្ឃឹម។ យើងអាចដោះច្រវាក់ពីកជើងរបស់អ្នកទោសដែលជាប់នៅក្នុងគុក។ យើងអាចនាំយកអនុស្សាវរីយនិងគំនិតពីផ្ទះរបស់យើងទៅកាន់ប្រទេសឆ្ងាយៗឯទៀត។ យើងអាចនាំយកភាពរួសរាយរាក់ទាក់ពីស្ថានសួគ៌ទៅកាន់អ្នកដែលមានជំនឿខ្សត់ខ្សោយ ទោះបីជាពួកគេកំពុងខិតខំប្រឹងប្រែងយ៉ាងត្រដាបត្រដួសនៅឯនាយសមុទ្រដ៏សែនឆ្ងាយក៏ដោយ។ ទាំងអស់នេះគឺជាការឆ្លើយតបទៅនឹងការអធិស្ឋានដ៏អស្ចារ្យក្រៃលែង!
>
> — លោក ចេ. អេឆ. ចូវិត
> (J. H. Jowett)

ទាក់ទងនឹងចំណុចនេះដែរ អ្នកនិពន្ធដែលមានឈ្មោះថា វេន ហែម (Wenham) បានបន្ថែមទីបន្ទាល់របស់គាត់ដូចតទៅ ៖ «*ការអធិប្បាយគឺជាអំណោយទានដ៏កម្រមួយ ឯការអធិស្ឋានគឺរឹតតែកម្រជាងនោះទៅទៀត។ ការអធិប្បាយប្រៀបបាននឹងដាវដែលជាអាវុធប្រើសម្រាប់ច្បាំងនៅជិតគ្នា ប៉ុន្តែមិនអាចវាយជាមួយអ្នកដែលនៅឆ្ងាយបានទេ។ ឯការអធិស្ឋានវិញប្រៀបបានទៅនឹងកាំភ្លើងធំដែលយើងអាចបាញ់បានឆ្ងាយ ហើយក៏មានប្រសិទ្ធភាពជាជាងការអធិប្បាយនៅក្នុងកាលៈទេសៈមួយចំនួនទៅទៀត*»។

*ឱព្រះជាម្ចាស់អើយ*
*តើទូលបង្គំនឹងមានការផ្លាស់ប្តូរអស្ចារ្យយ៉ាងណាក្នុងពេលដ៏ខ្លី*
*ស្ថិតក្នុងព្រះវត្តមាននៃព្រះដ៏ឧត្តុង្គឧត្តមក្រៃលែង។*
*បន្ទុកទាំងឡាយនោះឯងនឹងរលាយបង់បោះ*
*ដូចជាដីដែលក្រៀមក្រោះបានផ្សើមដោយទឹកភ្លៀង។*
*ពេលទូលបង្គំលុតជង្គង់ចុះគ្រប់យ៉ាងដូចហាក់នៅទាប*
*ទូលបង្គំនឹងក្រោកទោះនៅឆ្ងាយឬក៏នៅជិត*
*ប្រៀបបាននឹងពន្លឺចាំងចិញ្ចែងនៃព្រះអាទិត្យ។*
*យើងលុតជង្គង់ពេលយើងខ្សោយ*
*ពេលក្រោកឡើងវិញពេញដោយចេស្តា*
*ហេតុអ្វីត្រូវឲ្យខ្លួនយើងប្រែជាខុសលែងអធិស្ឋាន*
*ជួយគេក៏មិនបាន ព្រោះយើងខ្សោយពេក។*
*ចុះហេតុអ្វីបានជាយើងខ្ញុំតែងតែដាក់បន្ទុកនៃការខ្វល់ខ្វាយលើខ្លួនឯង?*
*ហើយម៉េចបានក្រែងប្រែជាទន់ខ្សោយចិត្តក៏មិនបាន*
*ភ័យព្រួយ ធុញថប់ អាចផុតរលត់ដោយពាក្យអធិស្ឋាន*
*នាំមកអំណរ និងភាពក្លាហាន កម្លាំងក៏មាននៅក្នុងព្រះអង្គ។*

— លោក រីឆាត ស៊ី. ទ្រិនឆ៍
(Richard C. Trench)

## ជំពូកទី៨

# សឹកសង្គ្រាម

ទោះបើបុគ្គលម្នាក់គ្រាន់តែអានព្រះគម្ពីរសញ្ញាថ្មីតែបន្តិចបន្តួច គង់តែគាត់ឃើញថា ព្រះគម្ពីរតែងប្រើរូបភាពដែលទាក់ទងទៅនឹងសឹកសង្គ្រាមមកពណ៌នាពីការគ្រងរាជ្យរបស់ព្រះគ្រីស្ទនៅលើផែនដីនេះដែរ។ បុព្វហេតុនៃជំនឿគ្រីស្ទបរិស័ទក្លែងក្លាយគឺគ្រាន់តែសម្តែងឲ្យមនុស្សលោកទស្សនាដើម្បីកំដរអារម្មណ៍តែប៉ុណ្ណោះ ប៉ុន្តែជំនឿគ្រីស្ទបរិស័ទដ៏ពិតផ្ទុយស្រលះពីនេះទាំងស្រុង។ ជំនឿគ្រីស្ទបរិស័ទដ៏ពិតមិនមែននាំឲ្យមនុស្សមានជីវិតដ៏ហ៊ឺហា ឬជាជីវិតដែលចង់បានតែភាពសម្បូរសប្បាយ ដូចដែលមនុស្សលោកនៅលោកីយ៍នេះភាគច្រើនកំពុងតែធ្វើនោះឡើយ។ ផ្ទុយទៅវិញ វាគឺជាការតស៊ូរហូតដល់ទីមរណា និងជាជម្លោះដែលគ្មានទីបញ្ចប់ជាមួយនឹងពួកអារក្សសាតាំង។ បុគ្គលដែលរាប់ខ្លួនថាជាសិស្សរបស់ព្រះយេស៊ូវ តែមិនដឹងថា ខ្លួនកំពុងស្ថិតក្នុងសមរភូមិសង្គ្រាមខាងឯវិញ្ញាណ បុគ្គលនោះ

មិនស័ក្តិសមនឹងទទួលនាមថាជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទទេ។

យើងត្រូវតែពួតដៃគ្នាក្នុងសង្គ្រាម មិនមែនទៅបង្កជម្លោះ ច្រណែនគ្នា ប្រកាន់បក្សពួក ឬក៏លាក់ពុតគ្នានោះឡើយ។ ក្រុមគ្រួសារណាដែលទាស់ទែងគ្នាមិនអាចនៅជាមួយគ្នាបានស្ថិតស្ថេរនោះទេ (ម៉ាថាយ ១២:២៥)។ ហេតុដូច្នេះហើយ ទាហានរបស់ព្រះគ្រីស្ទត្រូវចេះសាមគ្គីគ្នា។ ការបន្ទាបខ្លួន គឺជាគន្លឹះនៃការសាមគ្គីគ្នា។ កណ្ឌគម្ពីរភីលីពជំពូក២ បានបង្រៀនការនេះយ៉ាងច្បាស់លាស់។ វាមិនអាចទៅរួចទេ បើយើងទៅទាស់ជាមួយនឹងអ្នកដែលពិតជាបន្ទាបខ្លួននោះ។ ការទាស់ទែងគ្នាត្រូវការគូបដិបក្ខពីរនាក់។ *"ផលនៃសេចក្តីឆ្មើងឆ្មៃ នោះមានតែការទាស់ទែងគ្នាប៉ុណ្ណោះ..."* (សុភាសិត ១៣:១០)។ ទីណាដែលគ្មានសេចក្តីឆ្មើងឆ្មៃ ទីនោះនឹងគ្មានការឈ្លោះប្រកែកគ្នានោះឡើយ។

សង្គ្រាមទាមទារឲ្យយើងរស់នៅយ៉ាងសាមញ្ញតាមបែបក្បិតក្បៀត។ ទោះបើតាមរូបភាពណាក៏ដោយ ការធ្វើសង្គ្រាមដ៏ធំមិនអាចគេចផុតពីការលៃលកធនធានសឹកសង្គ្រាមបាននោះឡើយ។ គ្រីស្ទបរិស័ទត្រូវដឹងថា យើងកំពុងស្ថិតក្នុងសមរភូមិ ហេតុដូច្នេះហើយ យើងគួរតែកាត់បន្ថយរាល់ការចំណាយផ្សេងៗឲ្យដល់ចំណុចអប្បបរមា ដើម្បីឲ្យមានធនធានគ្រប់គ្រាន់ក្នុងការប្រយុទ្ធ។

មានមនុស្សតិចណាស់ដែលមើលឃើញការនេះច្បាស់ដូចទៅនឹងសិស្សវ័យក្មេងម្នាក់ឈ្មោះ អរ. អិម (R. M)។ នៅឆ្នាំ ១៩៦០ គាត់គឺជាប្រធាននិស្សិតឆ្នាំទី១ នៅសាលាគ្រីស្ទបរិស័ទមួយ។ នៅក្នុងអំឡុងនៃអាណត្តិរបស់គាត់ សិស្សផ្សេងៗបានលើកសំណើនៃការចំណាយទៅលើពិធីជប់លៀងការទិញអាវធំ និងការទិញកាដូប្រ-ចាំថ្នាក់សម្រាប់ពួកគេ។ ប៉ុន្តែលោក អរ. អិម បានសុំលាឈប់ពីតំណែងជាប្រធាន ដោយសារគាត់មិនឯកភាពនឹងការឲ្យសិស្សចំណាយលុយទៅលើអ្វីដែលមិនបានជួយរួមចំណែកក្នុងការបន្តពង្រឹង ហើយនិងបង្កើនការផ្សាយដំណឹងល្អ។ ខាងក្រោមនេះគឺជាសំបុត្រដែលបានចែកជូនដល់និស្សិតឆ្នាំទី១ទាំងអស់នៅថ្ងៃដែលគេប្រកាសពីការលាឈប់ពីតំណែងរបស់គាត់៖

**មកដល់មិត្តរួមថ្នាក់ទាំងអស់ជាទីនឹករឭក**

យោងតាមសំណើនៃការចំណាយទៅលើពិធីជប់លៀង ការទិញអាវធំ និងការទិញកាដូប្រចាំថ្នាក់ដែលបានលើកជូនដល់គណៈកម្មការ តាំងនាមខ្ញុំជាប្រធាននិស្សិតឆ្នាំទី១ ខ្ញុំបានពិចារណាលើអាកប្បកិរិយាដ៏ត្រឹមត្រូវរបស់គ្រីស្ទបរិស័ទចំពោះការស្នើសុំនោះដូចតទៅនេះ៖

ខ្ញុំគិតថា យើងអាចទទួលអំណរដ៏អស្ចារ្យបាន តាមរយៈការថ្វាយជីវិត

ថវិកា និងពេលវេលារបស់យើងទាំងអស់ដាច់ដល់ព្រះគ្រីស្ទ ដើម្បីបម្រើអ្នកដទៃទៀត។ នៅពេលដែលយើងធ្វើដូច្នេះ នោះយើងនឹងយល់ពីសេចក្ដីពិតនៃព្រះបន្ទូលរបស់ទ្រង់ ដូចដែលបានចែងថា៖ “*...អ្នកណាដែលបាត់ជីវិតដោយយល់ដល់ខ្ញុំ អ្នកនោះនឹងបានជីវិតវិញ*” (ម៉ាថាយ ១០:៣៩)។

ការដែលគ្រីស្ទបរិស័ទចំណាយថវិកា និងពេលវេលារបស់ពួកគេទៅលើការដែលមិនបានផ្ដល់ជាលទ្ធផលដែលជាទីបន្ទាល់ល្អដ៏ជាក់លាក់ដល់អ្នកមិនជឿ ឬមិនបានស្អាងបុត្រាបុត្រីរបស់ទ្រង់ដែលនៅក្នុងព្រះវត្តមានទ្រង់នោះហាក់បីដូចជាមិនសមសោះ ដ្បិតមានមនុស្សប្រមាណជា ៧០០០នាក់ដែលស្លាប់ជារៀងរាល់ថ្ងៃ ហើយមនុស្សជាងពាក់កណ្ដាលលើពិភពលោកនេះនៅមិនទាន់បានឮអំពីសង្ឃឹមដែលមកពីព្រះយេស៊ូវតែមួយគត់នៅឡើយនោះទេ។

យើងគិតទៅមើលថា តើព្រះជាម្ចាស់នឹងទទួលបានសិរីល្អច្រើនប៉ុណ្ណាទៅ បើយើងជួយផ្សាយដំណឹងល្អទៅកាន់មនុស្ស៦០%ដែលមិនទាន់បានឮដំណឹងល្អអំពីព្រះគ្រីស្ទ ឬអ្នកជិតខាងរបស់យើងជាជាងការដែលយើងជួបជុំគ្នាជប់លៀងសម្រាប់តែខ្លួនឯង។ បើយើងចេះតែជួបជុំជប់លៀងតែគ្នាឯង ហើយខ្ជះខ្ជាយថវិកា និងពេលវេលា ដើម្បីតែការសប្បាយសម្រាប់ខ្លួន នោះយើងមិនបានថ្វាយសិរីល្អដល់ព្រះជាម្ចាស់បានពេញទំហឹងនោះទេ។

ខ្ញុំបានឃើញពីតម្រូវការដ៏ជាក់លាក់ និងឱកាសក្នុងការដែលយើងអាច

ចំណាយថវិកា ដើម្បីថ្វាយសិរីល្អដល់ព្រះយេស៊ូវគ្រីស្ទ និងដើម្បីជួយដល់អ្នកជិតខាងទាំងនៅក្នុងស្រុក និងនៅក្រៅស្រុក។ អាស្រ័យហេតុនេះហើយបានជាខ្ញុំមិនអាចនឹងអនុញ្ញាតឲ្យលើកគម្រោងចំណាយសម្រាប់ខ្លួនយើងដែលវាមិនចាំបាច់នោះឡើយ។ ប្រសិនបើខ្ញុំស្ថិតក្នុងចំណោមអ្នកដែលខ្វះ-ខាត ដូចមនុស្សជាច្រើននៅពិភពលោកនេះ នោះខ្ញុំប្រាថ្នាចង់ឲ្យអ្នកដែលមានលទ្ធភាពជួយប្រាប់ដំណឹងល្អដល់ខ្ញុំ ព្រមទាំងជួយផ្គត់ផ្គង់តម្រូវការដែលខ្ញុំមាន តាមដែលពួកគេអាចធ្វើទៅបាន។

*"បើអ្នករាល់គ្នាចង់ឲ្យមនុស្សប្រព្រឹត្តចំពោះអ្នករាល់គ្នាយ៉ាងណា ចូរប្រព្រឹត្តចំពោះគេយ៉ាងនោះដែរ"* (លូកា ៦:៣១ គគខ)។

*"បើអ្នកណាមានភោគសម្បត្តិរបស់លោកីយ៍នេះ ហើយឃើញបងប្អូនណាដែលខ្វះខាត តែមិនចេះអាណិតមេត្តាសោះ នោះធ្វើដូចម្ដេច ឲ្យសេចក្ដីស្រឡាញ់នៃព្រះ បានស្ថិតនៅក្នុងអ្នកនោះបាន"* (១យ៉ូហាន ៣:១៧)។

ខ្ញុំអធិស្ឋានសូមឲ្យអ្នកទាំងអស់គ្នាឃើញពីការលះបង់អ្វីៗទាំងអស់របស់ព្រះអម្ចាស់យេស៊ូវ (២កូរិនថូស ៨:៩)។ ដោយសេចក្ដីស្រឡាញ់ ខ្ញុំសូមលាឈប់ពីតំណែងជាប្រធានថ្នាក់ឆ្នាំ ១៩៦៣ នេះចាប់ពីពេលនេះតទៅ។

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទដែលគង់នៅជាមួយ អ្នករាល់គ្នា៕

— ប្រធាននិស្សិត អរ. អិម (R. M)

សង្គ្រាមទាមទារឲ្យមានការរងទុក្ខ។ ប្រសិនបើយុវជនសម័យនេះមានចិត្តមោះមុតហ៊ានពលីជីវិតរបស់ពួកគេដើម្បីប្រទេសជាតិ នោះតើយើងដែលជាគ្រីស្ទបរិស័ទគួរមានចិត្តមោះមុតហ៊ានពលីជីវិត ដើម្បីព្រះគ្រីស្ទ និងដំណឹងល្អជាងអម្បាលម៉ានទៅ។ ជំនឿដែលគ្មានការលះបង់អ្វីសោះ នោះគ្មានតម្លៃទេ។ ប្រសិនបើយើងជឿថា ព្រះអម្ចាស់យេស៊ូវមានតម្លៃ នោះយើងត្រូវជឿថា ទ្រង់មានតម្លៃលើសអ្វីៗទាំងអស់។ យើងមិនគួរអនុញ្ញាតឲ្យការខ្វល់ខ្វាយពីសុវត្ថិភាពផ្ទាល់ខ្លួន និងការភ័យក្លាចនឹងជួបគ្រោះថ្នាក់មករារាំងយើងក្នុងការបម្រើព្រះជាម្ចាស់ទេ។

នៅពេលដែលសាវ័ក ប៉ុល ព្យាយាមការពារភាពជាសាវ័ករបស់គាត់ពីការវាយប្រហារពីសំណាក់ក្រុមអ្នករិះគន់ គាត់មិនបានយកប្រវត្តិក្រុមគ្រួសាររបស់គាត់ ចំណេះដឹងរបស់គាត់ ឬក៏សេចក្ដីសម្រេចតាមបែបលោកីយ៍មកប្រើនោះឡើយ។ ផ្ទុយទៅវិញ គាត់បានយកការរងទុក្ខរបស់គាត់សម្រាប់ព្រះអម្ចាស់យេស៊ូវគ្រីស្ទមកប្រើ៖

> គេជាអ្នកបំរើព្រះគ្រីស្ទឬអី (ខ្ញុំនិយាយបែបដូចជាវង្វេងស្មារតីហើយ) ខ្ញុំក៏លើសជាងគេទៅទៀត ក្នុងការនឿយហត់លើសជាងគេ ដោយត្រូវរំ-ពាត់ហួសល្បត់ ទាំងត្រូវជាប់គុកច្រើនជាងគេ ក៏ដល់នូវភាពជិតស្លាប់ជាញឹកញយ ប្រាំដងហើយ សាសន៍យូដាវាយខ្ញុំ៤០រំពាត់ខ្វះ១ គេវាយខ្ញុំនឹង

ដំបង៣ដង គេចោលខ្ញុំនឹងថ្ម១ដង ខ្ញុំត្រូវសំពៅលិច៣ដង ខ្ញុំនៅនាសមុទ្រជ្រៅអស់១ថ្ងៃ១យប់ ខ្ញុំដើរដំណើរជាច្រើន ក៏មានសេចក្តីអន្តរាយនៅទន្លេ អន្តរាយដោយពួកចោរប្លន់ អន្តរាយដោយសាសន៍របស់ខ្ញុំ អន្តរាយដោយសាសន៍ដទៃ  ក៏អន្តរាយក្នុងទីក្រុង ក្នុងទីរហោស្ថាន ក្នុងសមុទ្រ ក្នុងពួកបងប្អូនក្លែងក្លាយដែរ ត្រូវនឿយហត់ ហើយលំបាក ត្រូវចាំយាមជាញយ ត្រូវស្រេកឃ្លាន ត្រូវអត់ជាញឹកញយ ត្រូវរងា ហើយត្រូវអាក្រាតផង ក្រៅពីការខាងសាច់ឈាមទាំងនោះ ក៏មានសេចក្តីកង្វល់ខាងឯពួកជំនុំទាំងប៉ុន្មាន ដែលប្រជ្រៀតមកលើខ្ញុំ  រាល់តែថ្ងៃជានិច្ចថែមទៀត  (២កូរិនថូស ១១:២៣-២៨)។

សាវ័ក ប៉ុល បានដាស់តឿនលោក ធីម៉ូថេ ដែលជាកូនក្នុងជំនឿរបស់គាត់យ៉ាងមុតមាំថា *“ដូច្នេះ ចូរឲ្យអ្នកទ្រាំទ្រទុក្ខលំបាក ដូចជាទាហានយ៉ាងល្អរបស់ព្រះយេស៊ូវគ្រីស្ទចុះ”* (២ធីម៉ូថេ ២:៣)។

សង្គ្រាមទាមទារឲ្យមានការស្តាប់បង្គាប់ដែលមិនអាចតវ៉ាបាន។ ទាហានល្អនឹងស្តាប់តាមមេបញ្ជាការរបស់ខ្លួនដោយគ្មានការសួរតវ៉ា ឬឃឹតយ៉ាវនោះឡើយ។ បើយើងគិតថា ព្រះយេស៊ូវសព្វព្រះហឫទ័យឲ្យយើងស្តាប់បង្គាប់ទ្រង់មិនដូចកូនទាហានស្តាប់បង្គាប់មេបញ្ជាការយ៉ាងអស់ពីចិត្ត នោះយើងយល់ច្រឡំហើយ។ ក្នុងនាមទ្រង់ជាព្រះ

អាទិករ និងជាព្រះប្រោសលោះ ទ្រង់មានសិទ្ធលើអស់អ្នកដែលដើរតាមទ្រង់ទៅកាន់ទីលានប្រយុទ្ធគ្រប់បែបយ៉ាង ក្នុងការបង្គាប់បញ្ជាឲ្យពួកគេស្តាប់តាមព្រះរាជបញ្ជារបស់ទ្រង់ដោយមិនអាចប្រកែកបាន ហើយដោយគ្មានការបង្អែបង្អង់។

សង្គ្រាមទាមទារឲ្យមានជំនាញក្នុងការប្រើប្រាស់អាវុធ។ ការអធិស្ឋាន និងព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺជាអាវុធរបស់គ្រីស្ទបរិស័ទ។ អ្នកនោះត្រូវតែអធិស្ឋានដោយចិត្តក្លៀវក្លា ពេញដោយជំនឿ ហើយឥតឈប់ឈរ។ មានតែការនេះទេ ទើបអាចកំទេចបន្ទាយខ្មាំងសត្រូវរបស់យើងបាន។ ជាមួយគ្នានេះដែរ អ្នកនោះត្រូវតែមានភាពប៉ិនប្រសប់ក្នុងការប្រើប្រាស់ដាវរបស់ព្រះវិញ្ញាណដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ខ្មាំងសត្រូវនឹងប្រើវិធីសាស្ត្រគ្រប់បែបយ៉ាងដែលវាអាចធ្វើបាន ដើម្បីបោកបញ្ឆោតគាត់ឲ្យទម្លាក់ដាវនោះចោល។ វានឹងធ្វើឲ្យយើងសង្ស័យថា ព្រះជាម្ចាស់មិនបានតែងព្រះបន្ទូលរបស់ទ្រង់ទេ។ វានឹងធ្វើឲ្យយើងគិតថា ព្រះគម្ពីរហាក់បីដូចជាមានភាពច្របូកច្របល់ ហើយមិនមានភាពស៊ីគ្នា។ វានឹងយកការទាស់ប្រឆាំងទាក់ទងផ្នែកវិទ្យាសាស្ត្រ ទស្សនវិជ្ជា និងប្រពៃណីទំនៀមទម្លាប់មកបំភាន់ព្រះបន្ទូល។ ប៉ុន្តែទាហានរបស់ព្រះគ្រីស្ទត្រូវតែឈរឲ្យរឹងមាំ ហើយបង្ហាញពីប្រសិទ្ធភាពនៃដាវរបស់គាត់ ដោយប្រើប្រាស់វាគ្រប់

កាលៈទេសៈ។

អាវុធសម្រាប់ធ្វើសង្គ្រាមរបស់គ្រីស្ទបរិស័ទ មើលទៅគឺជារឿងដ៏គួរឲ្យអស់សំណើចសម្រាប់លោកីយ៍នេះ។ អ្នកដឹកនាំពលទាហាននាសម័យបច្ចុប្បន្ននេះនឹងសើចចំអកលើគម្រោងការដ៏មានប្រសិទ្ធ-ភាពដែលសាសន៍អ៊ីស្រាអែលបានប្រើ ដើម្បីវាយយកក្រុងយេរីខូរ។ ហើយពួកគេក៏នឹងសើចចំអកចំពោះទាហានដ៏តិចតួចស្តួចស្តើងរបស់លោក គេឌានដែរ (ពួកចៅហ្វាយ ៦-៨)។ ចុះតើយើងអាចនិយាយយ៉ាងម៉េចដែរទាក់ទងនឹងខ្សែដង្ហក់របស់ដាវីឌ ជន្លួញចាក់គោរបស់លោក សាំកើរ និងទាហានមិនសូវមានភាពឆ្លាតវៃរបស់ព្រះជាម្ចាស់ជាច្រើនសតវត្សរ៍កន្លងមកនេះ (១សាំយូអែល ១៧; ពួកចៅហ្វាយ ៣:៣១)? គំនិតដែលពេញដោយព្រះវិញ្ញាណដឹងថា ព្រះជាម្ចាស់មិនមែននៅខាងទាហានមួយកងធំនោះឡើយ តែផ្ទុយទៅវិញទ្រង់សព្វព្រះទ័យនឹងប្រើអ្នកទន់ខ្សោយ អ្នកក្រីក្រ និងអ្វីៗដែលលោកីយ៍នេះស្អប់ខ្ពើម ដើម្បីបង្កើនសិរីល្អរបស់ទ្រង់តាមរយៈពួកគេ។

សង្គ្រាមទាមទារឲ្យមានសេចក្តីក្លាហានក្នុងការប្រឈមនឹងគ្រោះថ្នាក់។ «*ហេតុនោះបានជាត្រូវឲ្យយកគ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទប់ទល់ក្នុងថ្ងៃអាក្រក់បាន រួចកាលណាបានតតាំងសព្វគ្រប់ហើយ នោះឲ្យបាននៅតែឈរមាំមួនដដែល ដូច្នេះ ចូរ*

*ឲ្យឈរមាំមួនចុះ...»* (អេភេសូរ ៦:១៣-១៤)។ ជាទូទៅ គ្រូបង្រៀនព្រះបន្ទូលតែងតែលើកឡើងថា គ្រឿងសឹកទាហានរបស់ព្រះគ្រីស្ទនៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៦:១៣-១៨ មិនមានប្រដាប់ការពារខ្នងនោះទេ នេះសឲ្យឃើញថា ទាហានគ្មានជម្រើសនឹងដកថយនោះឡើយ។ ហេតុអ្វីចាំបាច់ដកថយ ប្រសិនបើ *«...យើងមានជ័យជំនះលើសពីអ្នកមានជ័យជំនះទៅទៀត...»* (រ៉ូម ៨:៣៧)។

ប្រសិនបើគ្មានអ្នកណាម្នាក់អាចយកជ័យជម្នះលើយើងបានដោយសារតែព្រះជាម្ចាស់ជួយយើង ហើយប្រសិនបើយើងមានជ័យជម្នះតាំងពីមុនយើងចាប់ផ្តើមប្រយុទ្ធ នោះតើយើងអាចគិតពីការដកថយយ៉ាងម៉េចបាន?

*បើទោះជាខ្ញុំឈរជាប់អ្នកឈ្នះ*
*ឬក្លាយជាផេះដូចជាអ្នកចាញ់?*
*មនុស្សបាបកំសាកសែនទោម្នេញ*
*គឺមានតែការតតាំងគ្នាប៉ុណ្ណោះ។*
*សត្រូវដ៏ខ្លាំងបានវាយសម្រុក*
*ផ្លែដាវខ្ញុំបាក់មុខហើយព្រះអើយ*
*សូមទតមើលចុះទង់ជ័យខ្មាំងលើកហើយ*
*ទោះដាវតូចមួយក៏ដោយសូមប្រទានផង។*

— លើកឡើងដោយលោកស្រី អេមី ខរម៉ាយខល
(Amy Carmichael)

## ជំពូកទី៩

# អំណាចគ្រប់គ្រងផែនដី

ព្រះជាម្ចាស់បានត្រាស់ហៅយើងមកឲ្យមានអំណាចគ្រប់គ្រងផែនដី ហើយទ្រង់មិនដែលមានបំណងព្រះហឫទ័យឲ្យយើងទៅធ្វើការតូចទាបនោះទេ។ ទ្រង់ក៏មិនដែលមានបំណងព្រះហឫទ័យឲ្យយើងចំណាយជីវិតរបស់យើងជាអ្នកធ្វើការតូចតាចដែលមិនស្ថិតស្ថេរនោះដែរ។

នៅពេលដែលព្រះជាម្ចាស់បានបង្កើតមនុស្សនៅដើមដំបូង ទ្រង់បានប្រទានអំណាចឲ្យគាត់គ្រប់គ្រងលើផែនដី។ ទ្រង់ក៏បានបំពាក់មកុដសិរីរុងរឿង និងកិត្តិយសដល់គាត់ ព្រមទាំងបានបង្ក្រាបគ្រប់អ្វីៗទាំងអស់ឲ្យនៅក្រោមជើងរបស់គាត់។ នៅពេលនោះព្រះជាម្ចាស់បានប្រដាប់កាយមនុស្សដោយកិត្តិយស និងអធិបតេយ្យទាបជាងទេវតាតែបន្តិចទេ។

ពេលដែលអ័ដាមបានធ្វើបាប គាត់បានធ្វើឲ្យបាត់បង់អំណាចរបស់គាត់ ដែលព្រះជាម្ចាស់បានប្រទានឲ្យ។ គាត់មិនបានប្រើអំ-

ណាចដែលព្រះជាម្ចាស់បានប្រគល់ឲ្យទេ តែគាត់បែរជាទៅគ្រប់គ្រងលើអាណាចក្រដែលមិនស្ថិតស្ថេរទៅវិញ។

យើងអាចទទួលបានអំណាចគ្រប់គ្រងមកវិញខ្លះតាមរយៈដំណឹងល្អ។ វាមិនមែនដូចជាការដែលយើងគ្រាន់តែគ្រប់គ្រងលើឆ្កែដែលកាចសាហាវ ឬពស់អាសិរពិសនោះទេ តែវាគឺជាការប្រមូលអ្នកមិនជឿ និងអ្វីៗទាំងអស់នៅលើផែនដីនេះមកធ្វើជាមរតករបស់យើង។ លោក ចេ. អេឆ. ហ៊្វូវ៉េតថ៍ (J. H. Jowett) បានលើកឡើងថា៖ *«នៅពេលដែលបុគ្គលម្នាក់មានអធិបតេយ្យខាងឯសីលធម៌ និងខាងឯវិញ្ញាណ នោះគាត់មានចក្រពត្តិនិយមដ៏ពិត។ គាត់គ្រប់គ្រងបាន ដោយសារគាត់មានជីវិតដែលពោរពេញទៅដោយភាពស្អាតស្អំ ហើយជីវិតនោះបានទាក់ទាញចំណាប់អារម្មណ៍របស់មនុស្ស»*។

តាមពិតទៅ កិត្តិយសនៃការត្រាស់ហៅដែលគ្រីស្ទបរិស័ទបានទទួលពីព្រះជាម្ចាស់ គឺជាការដែលលោក អ័ដាម មិនដឹងសោះ។ យើងគឺជាដៃគូជាមួយនឹងព្រះជាម្ចាស់ក្នុងការរំដោះលោកីយ៍នេះ។ លោក ឌីនស្ដែល ធី. យ៉ាំង (Dinsdale T. Young) បានសរសេរថា៖ *«ព័ន្ធកិច្ចរបស់យើងគឺ ការចាក់ប្រេងតាំងឲ្យមនុស្សក្នុងព្រះនាមព្រះអម្ចាស់ ដើម្បីឲ្យពួកគេបានជាប់ជាពូជស្ដេច ដើម្បីឲ្យចេះគ្រប់គ្រងចិត្តខ្លួនឯង និងដើម្បីមកបម្រើអាណាចក្រព្រះជាម្ចាស់»*។

ការបដិសេធនឹងការត្រាស់ហៅដ៏ខ្ពង់ខ្ពស់របស់យើងបានផ្ដល់សោកនាដកម្មជាច្រើនក្នុងជីវិតនាពេលបច្ចុប្បន្ននេះ។ យើងស្កប់ចិត្តនឹងការឱបក្រសោបយកអ្វីដែលគ្មានប្រយោជន៍ ឬក៏ជ្រើសយកអ្វីដែលតូចតាចមកធ្វើជាចម្បងវិញ។ ហើយយើងធ្វើតែអ្វីដែលធម្មតា ជាជាងធ្វើអ្វីដែលអស្ចារ្យ។ យើងស្កប់ចិត្តនឹងឋានៈជាទាសករជាជាងការសោយរាជ្យជាមួយព្រះគ្រីស្ទ។ មានមនុស្សតិចណាស់ដែលចង់ឃើញជាតិសាសន៍ផ្សេងៗក្លាយជារាស្ត្ររបស់ព្រះគ្រីស្ទដូចជាលោក ស៊ី. អេឆ. ស្ពើចិន (C. H. Spurgeon)។ គាត់បានសរសេរពាក្យសម្ដីដ៏អង់អាចទៅកាន់កូនប្រុសរបស់គាត់ថា៖

> ឪពុកមិនសប្បាយចិត្តទេ បើកូនទៅធ្វើជាមហាសេដ្ឋី ស្របពេលដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យកូនទៅធ្វើជាបេសកជននោះ។ ហើយឪពុកក៏មិនសប្បាយចិត្តនឹងឃើញកូនទៅធ្វើជាស្ដេច ស្របពេលដែលកូនសមធ្វើជាបេសកជនដែរ។ ការធ្វើជាស្ដេច ធ្វើជាឯកឧត្ដម និងការមានគ្រប់ទាំងគ្រឿងអលង្ការរបស់លោកីយ៍នេះ មិនអាចប្រៀបផ្ទឹមនឹងការងារផ្សាយដំណឹងល្អពីព្រះគ្រីស្ទបាននោះឡើយ។ គ្មានការអ្វីដែលមានកិត្តិយសជាងការសាងសង់រាជ្យរបស់ព្រះគ្រីស្ទនៅកន្លែងដែលគ្មានអ្នកណាសង់ពីមុននោះទេ គឺការផ្សាយដំណឹងល្អរបស់ព្រះគ្រីស្ទនៅតាមតំបន់ឆ្ងាយៗ។[១]

លោក ចន ម៉ត់ (Jonh Mott) ដែលជាអ្នកតំណាង បេសកជនដ៏ល្បីម្នាក់ក៏ស្ថិតនៅក្នុងចំណោមអ្នកដែលចង់ឃើញជាតិសាសន៍ផ្សេងៗក្លាយជារាស្ត្ររបស់ព្រះគ្រីស្ទ។ នៅពេលដែលលោកប្រធានាធិបតីអាមេរិកឈ្មោះ ខាលវីន ខូលលិជ (Calvin Coolidge) ស្នើសុំឲ្យគាត់ទៅបម្រើការជាឯកអគ្គរាជទូតប្រចាំនៅប្រទេសជប៉ុន លោក ម៉ត់ (Mott) បានតបថា៖ *«លោកប្រធានាធិបតី ចាប់តាំងពីពេលដែលព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យមកធ្វើជាឯកអគ្គរាជទូតរបស់ទ្រង់មក ត្រចៀករបស់ខ្ញុំបានប្រែជាថ្លង់លែងឮការត្រាស់ហៅផ្សេងទៀតហើយ»*។ លោក ប៊ីលី ហ្គ្រាម (Billy Graham) ក៏បានលើកឡើងផងដែរថា៖ មានក្រុមហ៊ុនប្រេងអន្តរជាតិមួយកំពុងតែស្វែងរកបុរសម្នាក់ដែលរស់នៅភាគខាងកើត ពេលនោះក្រុមហ៊ុនក៏ជ្រើសរើសយកបេសកជនម្នាក់ឲ្យមកធ្វើជាតំណាងក្រុមហ៊ុន។ គេបានសន្យាថានឹងឲ្យគាត់មួយម៉ឺនដុល្លារ ប៉ុន្តែគាត់បានបដិសេធ។ រួចគេក៏ថានឹងឲ្យគាត់ពីរម៉ឺនប្រាំពាន់ដុល្លារ តែគាត់បានបដិសេធទៀត។ ក្រោយមកទៀតគេក៏ថានឹងឲ្យគាត់ប្រាំម៉ឺនដុល្លារ ប៉ុន្តែគាត់នៅតែបដិសេធដដែល។ ដូច្នេះគេក៏សួរគាត់ថា *«ម៉េចក៏លោកមិនព្រមទទួល?»* គាត់បានតបថា *«តម្លៃដែលលោកឲ្យនោះវាល្អហើយ តែការងារនោះវាតូចពេក ព្រោះព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំឲ្យមក*

*ធ្វើជាបេសកជនរួចទៅហើយ»។*

ការត្រាស់ហៅដែលមកពីព្រះជាម្ចាស់ គឺជាការប្រសើរលើសជាងអ្វីៗទាំងអស់ ហើយប្រសិនបើយើងបានដឹងអំពីការនេះ នោះជីវិតរបស់យើងនឹងទទួលបាននូវភាពឧដុង្គឧត្ដមយ៉ាងល្អក្រៃលែង។ យើងនឹងលែងហៅខ្លួនឯងថាជា «*អ្នកដែលទទួលការត្រាស់ហៅឲ្យមកធ្វើជាអ្នកបូមលូ*» ឬ «*អ្នកដែលទទួលការត្រាស់ហៅឲ្យមកធ្វើជាសាស្ត្រាចារ្យរូបវិទ្យា*» ឬក៏ជា «*អ្នកដែលទទួលការត្រាស់ហៅឲ្យមកធ្វើជាពេទ្យធ្មេញ*» ទៀតហើយ។ ផ្ទុយទៅវិញ យើងនឹងរាប់ខ្លួនឯងថាជា «*អ្នកដែលទទួលការត្រាស់ហៅឲ្យមកធ្វើជាអគ្គរាជទូតរបស់ព្រះជាម្ចាស់*» ហើយការងារផ្សេងៗ គឺគ្រាន់តែជាមធ្យោបាយសម្រាប់ជីវភាពរស់នៅតែប៉ុណ្ណោះ។ យើងនឹងឃើញថា យើងគឺជាអ្នកដែលព្រះជាម្ចាស់បានត្រាស់ហៅឲ្យចេញទៅផ្សាយដំណឹងល្អដល់គ្រប់ទាំងមនុស្ស ហើយទៅបង្កើតសិស្សអស់គ្រប់ទាំងសាសន៍។

អ្នកប្រហែលនឹងពោលថា ការងារនោះធំមហិមាយ៉ាងហ្នឹងផង! បាទ! ធំមហិមាមែន! ប៉ុន្តែយើងអាចធ្វើបាន។ តែការនេះទាមទារឲ្យមានការប្រតិបត្តិភ្លាមៗដែលយើងត្រូវធ្វើឲ្យអស់ពីចិត្ត។

ជាដំបូង សូមគិតអំពីចំនួនប្រជាជនសរុបនៅលើពិភពលោកទាំងមូលសិន។ សព្វថ្ងៃនេះមានប្រជាជនជាងប្រាំពីរកោដិនាក់ដែល

កំពុងរស់នៅលើពិភពលោកនេះ ហើយអត្រានៃការកើតក៏កំពុងតែកើនឡើងយ៉ាងសន្ធឹកសន្ធាប់ដែរ។ ចាប់តាំងពីសម័យកាលព្រះយេស៊ូវរហូតដល់មុនសតវត្សរ៍ទី១៨ ឃើញថា ចំនួនប្រជាជនសរុបមិនមានដល់មួយកោដិនាក់ទេ តែមួយសតវត្សរ៍ក្រោយមកយើងឃើញថា ចំនួនប្រជាជនសរុបមានដល់ពីរកោដិនាក់។ នៅសតវត្សរ៍ទី២០ ចំនួនប្រជាជនសរុបបានកើនឡើងរហូតដល់ ៤.៤ កោដិនាក់។ សព្វថ្ងៃយើងឃើញថា ចំនួនមនុស្សកើនឡើងប្រមាណជា ១៥០.០០០នាក់ជារៀងរាល់ថ្ងៃ។[២]

បើយើងធ្វើស្ថិតិមនុស្សរាប់ពីកំណើតពិភពលោករហូតមកដល់សតវត្សរ៍ទី១៨ យើងឃើញថា មានមនុស្សប្រមាណជា៧០កោដិធ្លាប់រស់រានមានជីវិតលើផែនដីនេះ ហើយសព្វថ្ងៃនេះអ្នកដែលកំពុងរស់នៅមានប្រមាណជា១០ភាគនៃចំនួនមនុស្ស៧០កោដិនាក់នោះ ដោយសារចំនួនមនុស្សកើនឡើងយ៉ាងលឿន។

ទោះបើអាយុកាលជាមធ្យមនៃមនុស្សដែលកំពុងរស់នៅក្នុងប្រទេសអភិវឌ្ឍន៍គឺប្រមាណជា ៧០ឆ្នាំក៏ដោយ យើងគួរផ្សាយដំណឹងល្អទៅកាន់ពិភពលោកទាំងមូលជាបន្ទាន់ ព្រោះមនុស្សដែលកំពុងរស់នៅប្រទេសកំពុងអភិវឌ្ឍមានអាយុកាលជាមធ្យមក្រោម ៤០ឆ្នាំតែប៉ុណ្ណោះ។ មនុស្សជាច្រើនកំពុងតែរកកល់នឹងចូលទៅក្នុង

ស្ថាននរកអស់កល្បជានិច្ច។ ដូច្នេះ បងប្អូនអើយ កុំពន្យារពេលក្នុងការផ្សាយដំណឹងល្អដល់មនុស្សលោកឲ្យសោះ។

ព្រះគម្ពីរបានសង្កត់ធ្ងន់លើការផ្សាយដំណឹងល្អដល់លោកីយ៍ទាំងមូល។ *«សេចក្តីជំនឿ កើតឡើងដោយឮ ហើយដែលឮនោះ គឺដោយសារព្រះបន្ទូលនៃព្រះ»* (រ៉ូម ១០:១៧)។ ក្នុងចំណោមភាសាជាង៦៥០០ដែលមនុស្សប្រើប្រាស់នៅក្នុងពិភពលោកទាំងមូលនេះ មានប្រមាណជា២៥០០ភាសាប៉ុណ្ណោះដែលមានព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបកប្រែជាភាសារបស់ពួកគេ។ ឯពាក្យពេចន៍ដែលមានប្រើនៅក្នុងព្រះគម្ពីរខ្លះហាក់បីដូចជាប្រើពាក្យបុរាណពេកហើយពិបាកយល់។ ជាងនេះទៅទៀត រឿងដែលគួរឲ្យខ្លោចផ្សាបំផុតនោះគឺ មានប្រជាជនប្រហែលជា១៦ភាគរយនៅលើពិភពលោកជាអនក្ខរជន។ ទោះបើពួកគេមានព្រះគម្ពីរនៅក្នុងដៃ ក៏ពួកគេមិនអាចអានបានដែរ។

សម្រាប់ជាតិសាសន៍នៅលោកខាងលិចវិញ ពួកគេមានសិទ្ធិសេរីភាពមិនត្រឹមតែផ្នែកសាសនា និងជាពន្លឺនៃដំណឹងល្អប៉ុណ្ណោះនោះទេ លើសពីនោះទៅទៀត ពួកគេក៏មានធនធានជាច្រើនផ្សេងៗទៀតផងដែរ។ គ្រីស្ទបរិស័ទដែលមានធនធានច្រើនគួរតែប្រើវាក្នុងការជួយផ្សព្វផ្សាយដំណឹងល្អដល់លោកីយ៍នេះ ក៏ដូចជាជួយផ្គត់ផ្គង់

តម្រូវការរបស់អ្នកក្រីក្រ។

មានមនុស្សមួយភាគបីនៅលើលោកីយ៍នេះបានរាប់ខ្លួនថាជាគ្រីស្ទបរិស័ទ ប៉ុន្តែក្នុងចំណោមនោះ ក៏មានគ្រីស្ទបរិស័ទក្លែងក្លាយដែរ។ គ្មានអ្នកណាម្នាក់ដឹងច្បាស់ពីចំនួនអ្នកជឿដ៏ពិតនោះឡើយ។ ប្រសិនបើគ្រីស្ទបរិស័ទដ៏ពិតទាំងអស់ចេញទៅផ្សាយដំណឹងល្អទៅកាន់អ្នកដែលមិនទាន់បានឮឲ្យបានតែសែសិបនាក់ នោះពិភពលោកទាំងមូលនឹងបានឮដំណឹងល្អពីព្រះយេស៊ូវសុសសាយជាមិនខាន។

សព្វថ្ងៃនេះ  មានពួក  រ៉ូម៉ាំងកាតូលិក (Roman Catholics) ប្រមាណជាមួយកោដិនាក់  ហើយពួក អូថាដខស៍ (Orthodox) ប្រមាណជា២១៧លាននាក់ និងពួក ប្រូតេស្តង់ (Protestants) ប្រ-មាណជា៣៥១លាននាក់។

អ៊ីស្លាមសាសនាគឺជាសាសនាដែលមានការលូតលាស់លឿនជាងគេ។ ក្នុងចំណោម១.៣កោដិនាក់នៃអ្នកកាន់សាសនាអ៊ីស្លាមភាគច្រើនមានអាយុក្រោម២៥ឆ្នាំ។ មានប្រទេសចំនួន១៥ដែលស្ទើរនឹងក្លាយទៅជាពួកអ្នកកាន់សាសនាអ៊ីស្លាមទាំងអស់ទៅហើយ។ ក្នុងចំណោមសាសនាខុសៗគ្នាទាំង១០.២០០ នៃទ្វីបលោកទាំងមូល សាសនាធំៗមានដូចជា ព្រហ្មញ្ញសាសនា ពុទ្ធសាសនា សា-

សនាដែលជឿថាគ្មានព្រះ (Atheism) សាសនាស៊ីក (Sikhism) និង សាសនាយូដា (Judaism)។ ហើយបើយើងបូកសាសនាទាំងអស់ នេះចូលគ្នា វានឹងមានចំនួន១.៤កោដិនាក់ដែលមិនបានទទួលការ សង្គ្រោះ។

លទ្ធិកុម្មុយនីស្តនៅតែជាសត្រូវនឹងជំនឿគ្រីស្ទបរិស័ទ។ លទ្ធិ នេះបានព្យាយាមរារាំងមនុស្សមួយភាគប្រាំនៃចំនួនប្រជាជនក្នុង ពិភពលោកទាំងមូល មិនឲ្យឮសេចក្ដីពិតដូចជានៅ ប្រទេសចិន ប្រទេសគុយបា ប្រទេសវៀតណាម ប្រទេសកូរ៉េខាងជើង និងប្រ-ទេសផ្សេងៗទៀត។

រាល់សមាជិកនៃសាសនា និងលទ្ធិទាំងអស់មានតម្លៃពេកក្រៃ ចំពោះព្រះអម្ចាស់យេស៊ូវ។ ទ្រង់បានសុគតសម្រាប់ពួកគេគ្រប់ៗគ្នា។ ពួកគេទាំងអស់នោះគួរតែបានឮដំណឹងល្អ។ មនុស្សដែលត្រូវការឮ ដំណឹងល្អមានច្រើនក្រៃលែង។

ហេតុដូច្នេះ តើពិភពលោកទាំងមូលបានឮដំណឹងល្អអំពីព្រះ គ្រីស្ទក្នុងជំនាន់យើងនេះតាមរយៈអ្វី? មានចម្លើយតែមួយគត់ដែលឲ្យ ពិភពលោកទាំងមូលបានឮដំណឹងល្អនោះគឺ តាមរយៈបុរសនិងស្ត្រី ដែលស្រឡាញ់ព្រះជាម្ចាស់អស់ពីដួងចិត្ត និងស្រឡាញ់អ្នកជិតខាង ខ្លួនឲ្យដូចខ្លួនឯងតែប៉ុណ្ណោះ។ កិច្ចការនេះអាចសម្រេចបានតាមរយៈ

ភក្ដីភាពចំពោះព្រះជាម្ចាស់ដែលចេញពីសេចក្ដីស្រឡាញ់ដ៏អមតៈ។

អស់អ្នកដែលនៅជាប់នឹងសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទនឹងមិនខ្លាចលះបង់អ្វីឡើយក្នុងការបម្រើទ្រង់។ ដោយសារពួកគេស្រ-ឡាញ់ទ្រង់ នោះពួកគេហ៊ានលះបង់ដើម្បីទ្រង់ លើសពីអ្វីដែលពួកគេហ៊ានលះបង់ដើម្បីប្រមូលទ្រព្យសម្បត្តិនៅលោកីយ៍នេះ។ ពួកគេនឹងលែងរាប់ជីវិតរបស់ពួកគេថា សំខាន់សម្រាប់ខ្លួនទៀតឡើយ។ បំណងចិត្តដ៏ចម្បងរបស់ពួកគេគឺចង់ឃើញមនុស្សទទួលសេចក្ដីសង្គ្រោះរួចផុតពីបឹងភ្លើង ទោះបើត្រូវលះបង់ជីវិតរបស់ខ្លួនក៏ដោយ។

*ឱ! ព្រះជាម្ចាស់ដែលត្រូវគេឆ្កាងអើយ*
*សូមប្រទានឲ្យទូលបង្គំមានចិត្តដូចទ្រង់*
*បង្រៀនទូលបង្គំឲ្យចេះស្រឡាញ់*
*អស់ទាំងព្រលឹងដែលកំពុងតែសាបសូន្យ។*
*សូមរក្សាចិត្តទូលបង្គំនៃបនិត្យនឹងទ្រង់*
*មានទាំងក្ដីស្រឡាញ់ផងដូចនៅកាល់វ៉ារី*
*នាំទាំងព្រលឹងអ្នកវង្វេងដល់ទីដែលព្រះអង្គគង់។*

— លោក ចេមស៍ អេ. ស្ទីវវើត (James A. Stewart)

ប្រសិនបើសេចក្តីស្រឡាញ់មិនមែនជាកត្តាជំរុញចិត្តយើងទេ នោះកុំសង្ឃឹមថា យើងអាចបំពេញបេសកកម្មរបស់ព្រះគ្រីស្ទបានឡើយ។ ហើយព័ន្ធកិច្ចរបស់យើងក៏គ្មានប្រយោជន៍ដែរ ប្រៀបដូចជាសំឡេងឆ្វេងឆាង ដូចគង ឃ្មោះយ៉ាងដូច្នេះដែរ។ ប៉ុន្តែនៅពេលដែលសេចក្តីស្រឡាញ់បានចូលមកធ្វើជា តារានាំផ្លូវ និងនៅពេលដែលមនុស្សចេញទៅដោយមានភក្តីភាពដ៏ឆេះឆួលចំពោះព្រះគ្រីស្ទ នោះគ្មានអំណាចណាមួយលើផែនដីនេះអាចមកបញ្ឈប់ការសាបព្រោះដំណឹងល្អបានឡើយ។

សូមនឹកស្រមៃពីអ្នកដើរតាមព្រះយេស៊ូវមួយក្រុមដែលប្តូរផ្តាច់ជីវិតចំពោះទ្រង់ ស្រឡាញ់ទ្រង់ ហើយក៏បានឆ្លងភ្នំ កាត់សមុទ្រ ដើម្បីផ្សាយដំណឹងល្អដ៏អស្ចារ្យនេះ។ ពួកគេនៅតែរុករកកន្លែងថ្មីៗដោយមិនចេះនឿយហត់ ដើម្បីផ្សាយដំណឹងល្អ ហើយរាប់មនុស្សដែលពួកគេបានជួបថា ជាមនុស្សដែលព្រះយេស៊ូវបានសុគតជំនួស ព្រមទាំងរំពឹងចង់ឲ្យពួកគេក្លាយជាអ្នកដែលគោរពថ្វាយបង្គំព្រះអង្គសង្គ្រោះរហូតតរៀងទៅ។

តើសិស្សទាំងនេះប្រើវិធីសាស្ត្របែបណា ដើម្បីឲ្យមនុស្សបានស្គាល់ព្រះគ្រីស្ទ?

ព្រះគម្ពីរសញ្ញាថ្មីហាក់ដូចជាចង់បង្ហាញពីគោលការណ៍ធំពីរ

យ៉ាង ដើម្បីឈោងចាប់លោកីយ៍ដោយដំណឹងល្អ។ ទីមួយ គឺតាម-រយៈការប្រកាសជាសាធារណៈ ចំណែកឯទីពីរនោះ គឺតាមរយៈការបង្កើតសិស្សដោយផ្ទាល់តែម្តង (សូមមើលឧទាហរណ៍នៅក្នុងកិច្ចការ ២០:២០)។

ព្រះអម្ចាស់យេស៊ូវ និងសិស្សរបស់ទ្រង់បានប្រើវិធីសាស្ត្រទីមួយនេះជាច្រើនលើកច្រើនសាររួចមកហើយ។ ទីណាដែលមានមនុស្សប្រមូលផ្តុំគ្នា ទីនោះគឺជាឱកាស  ដើម្បីផ្សាយដំណឹងល្អហើយ។ ហេតុដូច្នេះហើយ យើងឃើញថា ការផ្សាយដំណឹងល្អកើតឡើងនៅតាម ផ្សារ ពន្ធនាគារ សាលាប្រជុំ នៅតាមឆ្នេរសមុទ្រ ក៏ដូចជាច្រាំងទន្លេផងដែរ។ ដោយសារដំណឹងល្អមានភាពបន្ទាន់ និងជាសារដ៏សំខាន់បំផុត ហេតុដូច្នេះបានជាព្រះយេស៊ូវ និងសិស្សទ្រង់ចេះតែផ្សាយនៅគ្រប់ទីកន្លែង។

វិធីសាស្ត្រទីពីរក្នុងការបណ្តុះបណ្តាលជំនឿរបស់គ្រីស្ទបរិស័ទ គឺតាមរយៈការបង្កើតសិស្សម្នាក់ទល់ម្នាក់ ឬតាមក្រុមតូច។ នេះគឺជាវិធីសាស្ត្រដែលព្រះអម្ចាស់យេស៊ូវបានប្រើពេលទ្រង់ហ្វឹកហ្វឺនសាវ័កទាំង១២នាក់។ ទ្រង់បានត្រាស់ហៅសាវ័កទាំងនោះឲ្យមកនៅជាប់ជាមួយនឹងទ្រង់ ដើម្បីបញ្ជូនពួកគេឲ្យចេញទៅផ្សាយដំណឹងល្អនៅកន្លែងផ្សេងៗ។ ពីមួយថ្ងៃទៅមួយថ្ងៃ ទ្រង់បានបង្រៀនពួកគេពី

សេចក្ដីពិតនៃព្រះជាម្ចាស់។ ទ្រង់បានរៀបចំព័ន្ធកិច្ច ដើម្បីឲ្យពួកគេយកទៅបំពេញតាមមុខងាររៀងៗខ្លួន។ ទ្រង់បានប្រាប់ពួកគេយ៉ាងលម្អិតពីគ្រោះថ្នាក់ដែលនឹងកើតឡើង ក៏ដូចជាការលំបាកផ្សេងៗទៀតដែលពួកគេនឹងជួបប្រទះ។ ទ្រង់ក៏បានបង្រៀនពួកគេពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលពីមុនជារឿងអាថ៌កំបាំង។ ទ្រង់ក៏បានឲ្យពួកគេធ្វើជាដៃគូនឹងទ្រង់ក្នុងព័ន្ធកិច្ចដ៏អស្ចារ្យ។ បន្ទាប់មកទ្រង់ក៏បានចាត់ពួកគេឲ្យចេញទៅ ដូចជាចៀមនៅកណ្ដាលហ្វូងស្វានយ៉ាងដូច្នោះដែរ (ម៉ាថាយ ១០:១៦)។ ដោយសារព្រះវិញ្ញាណបរិសុទ្ធបានប្រទានអំណាចដល់ពួកគេ នោះពួកគេក៏បានចេញទៅប្រកាសប្រាប់លោកីយ៍ពីព្រះយេស៊ូវគ្រីស្ទដ៏ជាព្រះដែលមានព្រះជន្មរស់ឡើងវិញ បានយាងទៅស្ថានសួគ៌ និងពីការដែលព្រះជាម្ចាស់បានតម្កើងទ្រង់ឡើង។ យើងឃើញថា វិធីសាស្ត្រនេះមានប្រសិទ្ធភាពណាស់ ព្រោះតាមរយៈពួកសាវ័កតែ១១នាក់ (ដោយសារម្នាក់បានក្បត់ទ្រង់) ពួកគេបានក្រឡាប់ចាក់ពិភពលោកនេះថ្វាយដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ (កិច្ចការ ១៧:៦)។

សាវ័ក ប៉ុល ក៏បានអនុវត្តវិធីសាស្ត្រនេះដោយផ្ទាល់ដែរ ហើយមិនត្រឹមតែប៉ុណ្ណោះ គាត់បានលើកទឹកចិត្តឲ្យលោក ធីម៉ូថេ ប្រើប្រាស់វិធីសាស្ត្រនេះទៀតផង។ “*ឯអស់ទាំងសេចក្ដីដែលអ្នក បានឮអំពីខ្ញុំ*

*នៅមុខស្មរបន្ទាល់ជាច្រើននោះក៏ត្រូវផ្ញើទុកនឹង មនុស្សស្មោះត្រង់ដែលអាចនឹងបង្ហឹកបង្រៀនតទៅអ្នកឯទៀតដែរ»* (២ធីម៉ូថេ ២:២)។ ជំហានទីមួយ គឺជ្រើសរើសអ្នកដែលស្មោះត្រង់នឹងព្រះជាម្ចាស់ដោយប្រុងប្រយ័ត្ន និងដោយការអធិស្ឋាន។ ជំហានទីពីរ គឺចែកចាយនិមិត្តដ៏ល្អនេះដល់ពួកគេ។ ជំហានទីបី គឺបញ្ជូនពួកគេឲ្យចេញទៅបង្កើតសិស្សដោយផ្ទាល់ (ម៉ាថាយ ២៨:១៩)។

ចំពោះអស់អ្នកដែលត្រេកត្រអាលតែនឹងតួលេខនៃចំនួនមនុស្ស ឬមនុស្សដ៏សន្ធឹកសន្ធាប់ នោះការប្រើវិធីសាស្ត្របែបនេះមើលទៅដូចជាគ្មានអ្វីអស្ចារ្យសោះ ហើយត្រូវចំណាយកម្លាំងច្រើនពេក។ ប៉ុន្តែព្រះជាម្ចាស់ទ្រង់ជ្រាបនូវការដែលទ្រង់កំពុងតែធ្វើ ហើយវិធីសាស្ត្ររបស់ទ្រង់គឺជាវិធីសាស្ត្រដែលល្អបំផុត។

សិស្សដ៏ស្មោះត្រង់តែមួយក្រុមតូចអាចមានឥទ្ធិពលក្នុងការបំផ្លាស់បំប្រែពិភពលោកជាងក្រុមធំ បើពួកគេប្រើវិធីសាស្ត្ររបស់ព្រះជាម្ចាស់។

នៅពេលដែលសិស្សទាំងអស់នេះចេញដំណើរទៅដោយនូវព្រះនាមព្រះគ្រីស្ទ ពួកគេបានត្រាប់តាមគោលការណ៍គ្រឹះយ៉ាងច្បាស់-លាស់ដែលមានចែងនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ជាដំបូងយើងឃើញថា ពួកគេមានភាពវៃឆ្លាតដូចពស់ ហើយសុភាពដូចព្រាប

ដែលមិនដែលចេះបង្ករឿងទាស់អ្នកដទៃ។ ពួកគេទីពឹងលើប្រាជ្ញារបស់ព្រះជាម្ចាស់ ដើម្បីដោះស្រាយរាល់បញ្ហាលំបាកដែលពួកគេជួបប្រទះ។ ស្របពេលជាមួយគ្នានេះដែរ ពួកគេក៏មានឥរិយាបថទន់ភ្លន់ និងចេះបន្ទាបខ្លួនក្នុងទំនាក់ទំនងជាមួយនឹងអ្នកផ្សេងៗដែរ។ ដូច្នេះមិនគួរឲ្យមានអ្នកណាម្នាក់ភ័យខ្លាចថា ពួកគេនឹងវាយធ្វើបាបខ្លួនឡើយ តែគួរភ័យខ្លាចនឹងការអធិស្ឋាន និងការដែលពួកគេចែកចាយដំណឹងល្អមិនចេះឈប់មិនចេះឈរដែលនាំឲ្យមនុស្សជឿលើព្រះគ្រីស្ទវិញ។

ពួកសិស្សទាំងនេះមិនបានប្រឡូកខ្លួននឹងនយោបាយក្នុងលោកីយ៍នេះទេ។ ហើយក៏មិនបានគិតថា ព្រះជាម្ចាស់ត្រាស់ហៅពួកគេឲ្យទៅធ្វើសង្គ្រាមតតាំងនឹងរដ្ឋាភិបាល ឬក៏មនោគមន៍នយោបាយអ្វីនោះឡើយ។ ពួកគេអាចសម្របខ្លួននៅក្រោមរបៀបរបបរដ្ឋាភិបាលមួយណាក៏បាន ហើយស្មោះត្រង់ទៅនឹងប្រព័ន្ធគ្រប់គ្រងនោះរហូត លើកលែងតែចំណុចដែលរដ្ឋាភិបាលតម្រូវឲ្យពួកគេបង្ខូចទីបន្ទាល់ ឬក៏បដិសេធព្រះជាម្ចាស់របស់ពួកគេទេ ទើបពួកគេនឹងមិនស្តាប់បង្គាប់ ហើយសុខចិត្តទទួលទោសវិញ។ ពួកគេមិនចូលរួមគំនិតប្រព្រឹត្តអំពើទុច្ចរិតប្រឆាំងនឹងអំណាចរដ្ឋាភិបាលនោះទេ ក៏មិនដែលធ្វើបដិវត្តន៍អ្វីឡើយ។ តើព្រះអម្ចាស់មិនបានមានបន្ទូល

នៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ១៨:៣៦ ទេឬអីថា៖ *“...នគរខ្ញុំមិនមែនត្រូវខាងលោកីយ៍នេះទេ បើសិនជានគរខ្ញុំត្រូវខាងលោកីយ៍នេះ នោះពួកអ្នកបំរើខ្ញុំ គេនឹងបានតយុទ្ធហើយ...”?* ពួកគេគឺជាអគ្គរាជទូតនៃនគរស្ថានសួគ៌ ហើយរស់នៅបែបជាអ្នកធម្មយាត្រា និងជាជនចម្លែកក្នុងលោកីយ៍នេះផងដែរ។

ពួកគេពិតជាស្មោះត្រង់ចំពោះគ្រប់ទាំងកិច្ចការ ហើយមិនចេះស៊ីសំណូកសូកប៉ាន់អ្វីឡើយ។ ចម្លើយថា *“បាទ”* របស់ពួកគេនៅតែបាទ ហើយចម្លើយថា *“ទេ”* របស់ពួកគេនៅតែទេ។ ពួកគេមិនគ្រាប់តាមរបៀបលោកីយ៍ដែលគិតថា យើងអាចធ្វើអ្វីក៏បានឲ្យតែយើងទទួលបានផលល្អនៅទីបញ្ចប់។ ទោះក្នុងស្ថានភាពណាក៏ដោយ ក៏ពួកគេនឹងមិនប្រើវិធីអាក្រក់ ដើម្បីឲ្យមានការល្អណាមួយកើតឡើងនោះឡើយ។ ពួកគេម្នាក់ៗគឺជារូបកាយដែលបានប្រដាប់ដោយបញ្ញាចិត្តដែលសុខចិត្តស្លាប់ ជាជាងធ្វើបាបទៅទៀត។

គោលការណ៍មួយផ្សេងទៀតដែលសិស្សទាំងនេះគ្រាប់តាមគឺថា ពួកគេចុះចូលហើយសហការធ្វើព័ន្ធកិច្ចជាមួយក្រុមជំនុំតាមតំបន់។ ពួកគេចេញទៅវាលចម្រូតក្នុងលោកីយ៍ទាំងមូល ដើម្បីច្រូតយកអ្នកជឿថ្មីៗថ្វាយព្រះអម្ចាស់យេស៊ូវ រួចហើយនាំអស់អ្នកដែលបានជឿទាំងនោះឲ្យប្រកបជាមួយនឹងក្រុមជំនុំតាមតំបន់ ដើម្បីពង្រឹងជំនឿ

ដ៏បរិសុទ្ធរបស់អ្នកជឿទាំងនោះ។ សិស្សដ៏ពិតរបស់ព្រះយេស៊ូវដឹងថា ក្រុមជំនុំតាមតំបន់នៅលើផែនដីនេះគឺជាឧបករណ៍របស់ទ្រង់ក្នុងការផ្សព្វផ្សាយជំនឿ។ ហើយព័ន្ធកិច្ចដែលធ្វើតាមរយៈក្រុមជំនុំជាព័ន្ធកិច្ចដ៏ស្ថិតស្ថេរ ព្រមទាំងមានផលប្រយោជន៍ល្អជាងគេ។

ដោយសារសិស្សរបស់ព្រះយេស៊ូវឆ្លាតវៃ ដូច្នេះពួកគេអាចគេចចេញពីភាពជំពាក់ជំពិននៃសម្ពន្ធគ្រប់បែបយ៉ាងដែលមិនត្រាប់តាមព្រះបន្ទូល។ ពួកគេជំទាស់ជាដាច់ខាតក្នុងការអនុញ្ញាតឲ្យអង្គការណាមួយមកបញ្ជាលើព័ន្ធកិច្ចរបស់ពួកគេនោះឡើយ។ តែពួកគេទទួលព្រះរាជឱង្ការឲ្យចេញទៅដោយផ្ទាល់ពីទីបញ្ជាការដ្ឋានកំពូលនៅនគរស្ថានសួគ៌។ នេះមិនមែនមានន័យថា ពួកគេចាប់ផ្តើមចេញទៅដោយមិនមានទំនុកចិត្ត ឬគ្មានប្រឹក្សាពីសំណាក់គ្រីស្ទបរិស័ទក្នុងក្រុមជំនុំតាមតំបន់របស់ពួកគេនោះឡើយ។ ផ្ទុយទៅវិញ ការប្រឹក្សានេះពួកគេរាប់ជាការអះអាងថា ព្រះជាម្ចាស់ពិតជាបានត្រាស់ហៅពួកគេឲ្យធ្វើព័ន្ធកិច្ចមែន។ លើសពីនេះទៅទៀត ពួកគេគិតថា ការបម្រើព្រះគ្រីស្ទស្របតាមព្រះបន្ទូលរបស់ទ្រង់ និងការណែនាំរបស់ទ្រង់គឺជាការចាំបាច់ណាស់។

ជាទីបញ្ចប់ ពួកសិស្សទាំងនេះព្យាយាមចៀសចេញពីការបង្ហាញមុខមាត់ជាសាធារណៈ។ ហើយបើមានជម្រើសពីរ នោះពួកគេនឹង

ជ្រើសយកការបម្រើដែលមិនទាមទារមុខមាត់។ គោលបំណងរបស់ពួកគេគឺ ធ្វើយ៉ាងណានាំសិរីល្អថ្វាយព្រះគ្រីស្ទ និងឲ្យមនុស្សគ្រប់គ្នាបានស្គាល់ទ្រង់។ ពួកគេមិនមែនស្វែងរកកេរ្តិ៍ឈ្មោះសម្រាប់ខ្លួនឯងនោះឡើយ ហើយក៏មិនចង់បង្ហាញពីយុទ្ធសាស្ត្ររបស់ខ្លួនដល់សា-តាំងដែរ។ ហេតុដូច្នេះហើយបានជាពួកគេបម្រើព្រះជាម្ចាស់យ៉ាងស្ងៀមស្ងាត់មិនទាមទារយកមុខមាត់ ហើយក៏មិនអើពើនឹងការលើកសរសើរ ឬក៏ការចោទប្រកាន់ពីមនុស្សក្នុងលោកីយ៍នេះឡើយ។ ពួកគេដឹងហើយថា *«នគរស្ថានសួគ៌គឺជាកន្លែងដ៏ល្អ ហើយមានសុវត្ថិភាពបំផុតសម្រាប់ពួកគេ ក្នុងការយល់ពីលទ្ធផលនៃការបម្រើព្រះជាម្ចាស់យ៉ាងនឿយហត់របស់ពួកគេ»*។

## ជំពូកទី១០

# គ្រីស្ទបរិស័ទ និង អាពាហ៍ពិពាហ៍

*«ដ្បិតមនុស្សខ្លះជាមនុស្សកម្រៀវតាំងពីកំណើតមក និងអ្នកផ្សេងទៀត ជាមនុស្សកម្រៀវដោយសារគេក្រៀវ ហើយក៏មានមនុស្សកម្រៀវដែលក្រៀវខ្លួនឯងដោយព្រោះតែនគរស្ថានសួគ៌។ ដូច្នេះ អ្នកដែលអាចទទួលយកបាន ចូរទទួលយកចុះ»*
(ម៉ាថាយ ១៩:១២ គគខ)។

សំណួរដ៏សំខាន់មួយដែលសិស្សរបស់ព្រះយេស៊ូវគួរសួរខ្លួនឯងនោះគឺ *«តើព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យខ្ញុំរៀបការ ឬក៏នៅលីវ?»* មានតែការដឹកនាំពីព្រះជាម្ចាស់ប៉ុណ្ណោះដែលអាចនឹងផ្តល់ចម្លើយចំពោះសំណួរនោះបាន។ គ្មានអ្នកណាម្នាក់អាចឆ្លើយសំ-ណួរនោះសម្រាប់បុគ្គលណាមួយបានឡើយ ហើយការព្យាយាម

ឆ្លើយសំណួរនោះសម្រាប់បុគ្គលណាមួយក៏អាចបង្កឲ្យមានគ្រោះថ្នាក់យ៉ាងធំបានដែរ។

ជាទូទៅ ព្រះបន្ទូលបានបង្រៀនយើងថា ព្រះជាម្ចាស់បានបង្កើតអាពាហ៍ពិពាហ៍សម្រាប់មនុស្សយើងដោយមានទាំងបំណង ព្រះហឫទ័យមួយចំនួនដូចខាងក្រោម៖

ទី១ ព្រះជាម្ចាស់បានគ្រោងទុកការផ្សំផ្គុំជាដៃគូ និងឲ្យមានភាពអរសប្បាយជាមួយគ្នាក្នុងអាពាហ៍ពិពាហ៍។ ព្រះជាម្ចាស់បានឃើញថា *«បើមនុស្សប្រុសនៅតែឯងដូច្នេះ មិនល្អទេ»* (លោកុប្បត្តិ ២:១៨ គខប)។

ទី២ ព្រះជាម្ចាស់បានរៀបចំអាពាហ៍ពិពាហ៍ឡើង ដើម្បីឲ្យមនុស្សបង្កើតកូនចៅតទៅមុខទៀត។ យើងអាចឃើញគោលបំណងនេះតាមរយៈព្រះរាជបញ្ជារបស់ព្រះជាម្ចាស់ដែលបញ្ជាក់ថា *«ចូរបង្កើតកូនឲ្យចំរើនជាច្រើនឡើង»* (លោកុប្បត្តិ ១:២៨)។

ទី៣ ព្រះជាម្ចាស់បានរៀបចំអាពាហ៍ពិពាហ៍ឡើង ដើម្បីរក្សាភាពបរិសុទ្ធនៅក្នុងគ្រួសារ និងសង្គម។ *«ដោយព្រោះមានការសហាយស្មន់កើតឡើង បានជាគួរឲ្យគ្រប់គ្នាមានប្រពន្ធជារបស់ផងខ្លួនវិញ...»* (១កូរិនថូស ៧:២)។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនបានលើកឡើងថា មនុស្សមិនអាចរៀបការបានទេ បើពួកគេចង់មាន

ជីវិតបរិសុទ្ធ ហើយមានការប្ដេជ្ញាចិត្តក្នុងការបម្រើព្រះគ្រីស្ទ។ ប៉ុន្តែ ព្រះបន្ទូលបានលើកឡើងថា *«ចូរឲ្យមនុស្សគ្រប់គ្នាគោរពការរៀបការ ហើយការរួមដំណេកក៏ត្រូវបរិសុទ្ធដែរ»* (ហេព្រើរ ១៣:៤)។ ចំណុច នេះចង់បញ្ជាក់ថា *«អ្នកណាដែលរកបានប្រពន្ធ នោះឈ្មោះថាបាន របស់ល្អ...»* (សុភាសិត ១៨:២២)។ គ្រូប្រដៅនៅក្នុងកណ្ឌគម្ពីរ សាស្ដាបានលើកឡើងទាក់ទងនឹងអាពាហ៍ពិពាហ៍ថា *«មានគ្នា ២នាក់ នោះវិសេសជាងនៅតែឯង»* (សាស្ដា ៤:៩) ជាពិសេស ប្រសិនបើអ្នកទាំងពីរនេះចាប់ដៃគ្នាបម្រើព្រះអម្ចាស់ជាមួយគ្នា។ កណ្ឌគម្ពីរ ចោទិយកថា ៣២:៣០ បានចែងពីប្រសិទ្ធភាពនៃការ រីកចម្រើនក្នុងការសហការគ្នា ហើយក៏បានបង្ហាញឲ្យឃើញថា មនុស្សតែម្នាក់អាចដេញសត្រូវដល់មួយពាន់ ហើយពីរនាក់ក៏អាច ធ្វើឲ្យមួយម៉ឺននាក់រត់ជាសក្រញាំដែរ។

ទោះបីជាអាពាហ៍ពិពាហ៍គឺជាបំណងព្រះហឫទ័យរបស់ព្រះ ជាម្ចាស់សម្រាប់ មនុស្សយើងជាទូទៅក្ដី ក៏មិនមែនមានន័យថា ជាបំណងព្រះហឫទ័យសម្រាប់មនុស្សគ្រប់រូបនោះទេ។ ទោះបើវា មើលទៅដូចជាសិទ្ធិដែលមិនមានអ្នកណាម្នាក់អាចដកហូតចេញ បានក្ដី ក៏សិស្សរបស់ព្រះអម្ចាស់យេស៊ូវអាចសម្រេចលើកសិទ្ធិនេះ ចេញ ដើម្បីឲ្យខ្លួនគាត់អាចបម្រើព្រះគ្រីស្ទយ៉ាងអស់ពីចិត្ត។

ព្រះអម្ចាស់យេស៊ូវបានកត់សម្គាល់ថា នៅក្នុងនគររបស់ទ្រង់នឹងមានអ្នកដែលប្រៀបបាននឹងអ្នកដែលក្រៀវខ្លួនឯងដើម្បីបម្រើទ្រង់ *«ដ្បិតមនុស្សខ្លះជាមនុស្សកម្រៀវតាំងពីកំណើតមក និងអ្នកផ្សេងទៀត ជាមនុស្សកម្រៀវដោយសារគេក្រៀវ ហើយក៏មានមនុស្សកម្រៀវដែលក្រៀវខ្លួនឯងដោយព្រោះតែនគរស្ថានសួគ៌។ ដូច្នេះ អ្នកដែលអាចទទួលយកបាន ចូរទទួលយកចុះ»* (ម៉ាថាយ ១៩:១២)។

ជម្រើសធ្វើជាអ្នកកម្រៀវកើតឡើងតាមរយៈការស្ម័គ្រចិត្តតែប៉ុណ្ណោះ ហើយគាត់សម្រេចចិត្តដោយសារៈ

១. គាត់ដឹងច្បាស់ក្នុងចិត្តថា ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យគាត់នៅលីវ។

២. គាត់មានបំណងប្រាថ្នាថ្វាយខ្លួនគាត់ទាំងស្រុង ដើម្បីបម្រើព័ន្ធកិច្ចរបស់ព្រះអម្ចាស់ដោយមិនមានការជំពាក់ជំពិននឹងការទទួលខុសត្រូវក្នុងជីវិតអាពាហ៍ពិពាហ៍។

ដូច្នេះបុគ្គលដែលចង់ធ្វើជាមនុស្សនៅលីវ គាត់ត្រូវតែដឹងឲ្យច្បាស់ថា នោះហើយជាព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់គាត់ (១កូរិនថូស ៧:៧)។ មានតែតាមរយៈការនេះប៉ុណ្ណោះ ទើបសិស្សរបស់ព្រះយេស៊ូវដឹងយ៉ាងច្បាស់ថា ព្រះអម្ចាស់នឹងប្រទានព្រះគុណ

ដែលពួកគេត្រូវការក្នុងជីវិតជាអ្នកនៅលីវ។

ហើយវាត្រូវតែធ្វើដោយស្ម័គ្រពីចិត្ត។ ទីណាដែលមានការបង្ខំឲ្យនៅលីវដើម្បីបម្រើព័ន្ធកិច្ចព្រះជាម្ចាស់ ទីនោះអាចប្រឈមមុខនឹងគ្រោះថ្នាក់នៃសេចក្តីស្មោកគ្រោក និងសេចក្តីកំផិតជាច្រើន។

សាវ័ក ប៉ុល បានបញ្ជាក់យ៉ាងច្បាស់ថា អ្នកដែលមិនរៀបការអាចបម្រើព័ន្ធកិច្ចរបស់ស្តេចលើអស់ទាំងស្តេចបានយ៉ាងច្រើន៖ *"អ្នកដែលគ្មានប្រពន្ធ នោះតែងរវល់តែនឹងការរបស់ព្រះអម្ចាស់ដែលនឹងធ្វើដូចម្តេចឲ្យទ្រង់សព្វព្រះហឫទ័យប៉ុណ្ណោះ តែអ្នកណាដែលមានប្រពន្ធ នោះតែងរវល់នឹងការនៅលោកីយ៍នេះវិញ ដែលនឹងធ្វើដូចម្តេចឲ្យប្រពន្ធបានពេញចិត្ត"* (១កូរិនថូស ៧:៣២-៣៣)។

នោះហើយជាហេតុផលដែលបណ្តាលឲ្យសាវ័ក ប៉ុល ប្រាថ្នាថាអ្នកមិនទាន់រៀបការ និងមេម៉ាយ ឬពោះម៉ាយក្តី គួររស់នៅដូចគាត់ដោយមិនចាំបាច់រៀបការ (១កូរិនថូស ៧:៧-៨)។

សូម្បីតែអស់អ្នកដែលបានរៀបការរួចហើយក្តី ក៏សាវ័ក ប៉ុល បានប្រាប់ពួកគេថា ពេលវេលាចង្អៀតណាស់ ដូច្នេះពួកគេត្រូវប្រើអ្វីៗគ្រប់យ៉ាង ដើម្បីនាំមនុស្សឲ្យស្គាល់ព្រះគ្រីស្ទ៖

*បងប្អូនអើយ ខ្ញុំប្រាប់សេចក្តីនេះថា ពេលវេលាចង្អៀតណាស់ហើយ ពីនេះទៅមុខ គួរតែឲ្យពួកអ្នកដែលមានប្រពន្ធ បាននៅដូចជាគ្មានវិញ*

*ពួកដែលយំ ដូចជាមិនយំ ពួកដែលអរសប្បាយ ដូចជាមិនអរសប្បាយ ពួកដែលទិញ ដូចជាគ្មានអ្វីសោះ ហើយពួកអ្នកដែលប្រើប្រាស់លោកីយ៍នេះ ដូចជាមិនប្រើហួសខ្នាតទេ ដ្បិតគំរូនៃលោកីយ៍នេះតែងតែផ្លាស់ទៅ* (១កូរិនថូស ៧:២៩-៣១)។

នេះមិនមែនចង់មានន័យថា មនុស្សប្រុសគួរតែលះអាល័យចោលទំនួលខុសត្រូវនៅផ្ទះរបស់ខ្លួន ឬបោះបង់ចោលប្រពន្ធនិងកូនរបស់ខ្លួន ហើយទៅធ្វើជាបេសកជននោះទេ។ ប៉ុន្តែ គាត់មិនគួរព្យាយាមរកការអរសប្បាយ និងការស្កប់ចិត្តចេញតែពីគ្រួសាររបស់គាត់នោះឡើយ។ គាត់មិនគួរយកលេសថា មកពីប្រពន្ធកូនរបស់គាត់ បានជាគាត់ដាក់ព្រះយេស៊ូវជាទីពីរទៅវិញ។

លោក ស៊ី. ធី. ស្ទឹដ (C. T. Studd) បារម្ភថា គូដណ្តឹងរបស់គាត់គិតពីគាត់ច្រើនពេក ហើយការនោះនឹងធ្វើឲ្យនាងបែរជាយកព្រះអម្ចាស់យេស៊ូវជាទីពីរសម្រាប់ជីវិតរបស់នាងទៅវិញ។ ដើម្បីចៀសវាងកុំឲ្យមានរឿងនេះកើតឡើង គាត់ក៏បានតែងជាកំណាព្យខ្លីមួយទុកឲ្យនាងទន្ទេញជាប្រចាំថ្ងៃគឺ៖

*ព្រះយេស៊ូវអើយ ទូលបង្គំស្រឡាញ់ទ្រង់ណាស់*
*ព្រះអង្គជាក់ច្បាស់សំខាន់ដល់ទូលបង្គំ*
*ភរិយាសំណព្វមិនស្មើដូចទ្រង់ ដួងចិត្តទូលបង្គំស្រឡាញ់ទ្រង់ពន់ពេក។*

ពួកអ្នកកាន់លទ្ធិកុម្មុយនីស្តប្រកាន់យកគោលការណ៍ឈ្នះពិភពលោក សំខាន់ជាងទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេទៅទៀត។ លោក ហ្គោដឹន អនណាល ឡុន់ស្តេល (Gordon Arnold Lonsdale) បានធ្វើគំរូស្រាប់ហើយ។ បន្ទាប់ពីប៉ូលិសបានចាប់ខ្លួនគាត់នៅក្នុងប្រទេសអង់គ្លេស ថាគាត់ជាគិញមកពីរុស្ស៊ីក្នុងឆ្នាំ ១៩៦០ ពួកប៉ូលិសបានរកឃើញសំបុត្រមួយច្បាប់ពីប្រពន្ធរបស់គាត់រួមជាមួយនឹងចម្លើយតបប្រមាណជាជិត៦ទំព័រ។ ប្រពន្ធគាត់បានសរសេរថា៖

ជីវិតនេះអីក៏អយុត្តិធម៌ម្ល៉េះ! អូនយល់ច្បាស់ហើយថាបងធ្វើការ ហើយវាគឺជាកិច្ចការរបស់បង បងស្រឡាញ់ការងារបង ហើយព្យាយាមធ្វើគ្រប់បែបយ៉ាងដោយយកចិត្តទុកដាក់។ ទោះបីជាយ៉ាងនេះក្តី ហេតុផលរបស់អូនស្តាប់ទៅដូចជាមានលក្ខណៈចង្អៀតចង្អល់ក្នុងបែបបទនៃការនិយមរបស់ស្ត្រី ហើយអូនមានការឈឺចាប់ខ្លាំងណាស់។ សូមឆ្លើយតបមកអូនផងថាបងស្រឡាញ់អូនប៉ុណ្ណា ហើយប្រហែលជាអូននឹងបានធូរចិត្ត។

លោក ឡុន់ស្តេល (Lonsdale) បានឆ្លើយតបដូចតទៅ៖

ការដែលបងចង់លើកឡើងនោះគឺថា សូម្បីតែរូបបងផ្ទាល់ក៏មានជីវិតតែមួយ ហើយក៏មិនមានភាពសុខស្រួលយ៉ាងដូច្នោះដែរ។ អ្វីដែលបងចង់ធ្វើនោះគឺ រស់នៅដើម្បីកុំឲ្យបងមានភាពអាម៉ាស់ នៅពេលដែលបងក្រឡេក

> មើលក្រោយ...ពេលនេះបងមានអាយុ៣៩ឆ្នាំទៅហើយ តើវាមាននៅសល់ពេលច្រើនទៀតទេ?[១]

សាវ័ក ប៉ុលបានលើកឡើងថា *“...ពេលវេលាចង្អៀតណាស់ហើយ ពីនេះទៅមុខគួរតែឲ្យពួកអ្នកដែលមានប្រពន្ធ បាននៅដូចជាគ្មានវិញ”* (១កូរិនថូស ៧:២៩)។

អារក្សសាតាំងតែងតែប្រើអាពាហ៍ពិពាហ៍ដែលមានលក្ខណៈឆាប់រហ័ស ឬការយល់ពីអត្ថន័យនៃអាពាហ៍ពិពាហ៍មិនបានត្រឹមត្រូវមករារាំងសិស្សដ៏ក្មេងខ្ចីរបស់ព្រះយេស៊ូវមិនឲ្យបម្រើព័ន្ធកិច្ចរបស់ទ្រង់យ៉ាងពេញទី។ មានអ្នកត្រួសត្រាយដ៏ឆេះឆួលរបស់ព្រះជាម្ចាស់ជាច្រើនបានលះបង់ព័ន្ធកិច្ចដែលទ្រង់បានដាក់ឲ្យគាត់ធ្វើចោលចេញដើម្បីទៅរៀបការវិញ។

ពេលខ្លះអាពាហ៍ពិពាហ៍អាចជាសត្រូវដ៏ធំមួយដែលរារាំងយើងមិនឲ្យបំពេញបំណងព្រះហឫទ័យរបស់ព្រះគ្រីស្ទដែលថា មនុស្សគ្រប់រូបគួរតែឮដំណឹងល្អពីទ្រង់។

> អាពាហ៍ពិពាហ៍គឺជាការប្រទានមកពីព្រះជាម្ចាស់ ប៉ុន្តែនៅពេលដែលវាក្លាយជារនាំងទាស់នឹងព្រះហឫទ័យរបស់ទ្រង់  នោះមានន័យថាយើងកំពុងតែប្រើប្រាស់វាមិនបានត្រឹមត្រូវ។ យើងទាំងអស់គ្នាសុទ្ធតែអាចនឹង

រៀបរាប់ឈ្មោះអ្នកដែលយើងស្គាល់ជាច្រើន គឺជាអ្នកដែលព្រះជាម្ចាស់បានត្រាស់ហៅឲ្យទៅធ្វើជាបេសកជន តែមិនដែលចេញទៅសោះ ព្រោះពួកគេរវល់តែជាប់ដៃជាប់ជើងជាមួយអ្នកជាទីស្រឡាញ់របស់ខ្លួនប៉ុណ្ណោះ។ មិនគួរឲ្យមានការណាមួយមកបង្អាក់បំណងព្រះហឫទ័យ ដែលព្រះជាម្ចាស់មានសម្រាប់អ្នកណាម្នាក់នោះឡើយ  សូម្បីតែការដែលព្រះជាម្ចាស់ប្រទានគូជីវិតក៏ដោយ...សព្វថ្ងៃនេះមានមនុស្សជាច្រើនបានស្លាប់ទៅដោយគ្មានព្រះគ្រីស្ទ ព្រោះតែអ្នកដែលព្រះជាម្ចាស់បានត្រាស់ហៅឲ្យទៅផ្សាយដំណឹងល្អ បែរទៅជាលើកតម្កើងគ្រួសារជាទីមួយជាជាងការបំពេញតាមបំណងព្រះហឫទ័យរបស់ទ្រង់ទៅវិញ។[២]

## អាពាហ៍ពិពាហ៍អាចក្លាយជាសត្រូវនឹងការបំពេញបេសកកម្មរបស់ព្រះគ្រីស្ទ ជាពិសេស ចំពោះអ្នកត្រួសត្រាយដែលផ្សាយដំណឹងល្អនៅកន្លែងពិបាក ហើយមិនទាន់បានឮដំណឹងល្អ។

មានបុរសស្ត្រីជាច្រើនដែលជាអ្នកនាំមុខប្រហែលជាត្រូវលះបង់ សូម្បីតែតម្រូវការចាំបាច់ឬការល្អមួយចំនួនក្នុងជីវិតក៏ដោយ។ អ្នកនាំមុខត្រូវមានភាពរឹងប៉ឹង  ត្រូវធ្វើជាទាហានដ៏ល្អដែលមិនជាប់ទាក់ទិននឹងរឿងផ្សេងៗក្នុងជីវិតនេះ និងធ្វើជាកីឡាករដែលចោលអស់ទាំងបន្ទុក ព្រះជាម្ចាស់បានត្រាស់ហៅពួកគេឲ្យមានមុខងារពិសេសសម្រាប់ទ្រង់។[៣]

សម្រាប់អស់អ្នកដែលបានឮការត្រាស់ហៅនេះ ហើយបានឆ្លើយតបវិញ អ្នកនោះនឹងមានរង្វាន់ជាទីគាប់ចិត្ត។ “*ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលថា ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា...អស់អ្នកណាដែលលះចោលផ្ទះសំបែង ឬបងប្អូនប្រុសស្រី ឪពុកម្តាយ ប្រ-ពន្ធកូន ឬស្រែចំការ ដោយយល់ដល់ឈ្មោះខ្ញុំ នោះនឹងបានជា១រយភាគឡើងវិញ ហើយនឹងបានគ្រងជីវិតអស់កល្បជានិច្ចទុកជាមរដកដែរ*” (ម៉ាថាយ ១៩:២៨-២៩)។

## ជំពូកទី១១

# ការលៃលកមើលជាមុន

ព្រះអម្ចាស់យេស៊ូវមិនដែលបញ្ជោរអ្នកណាម្នាក់ឲ្យនិយាយថា ខ្លួនជឿលើទ្រង់នោះឡើយ។ ហើយទ្រង់ក៏មិនដែលប្រើការអធិប្បាយដែលពេញនិយម ដើម្បីទាក់ទាញឲ្យមានអ្នកដើរតាមទ្រង់ជាច្រើននោះឡើយ។ តាមពិត រាល់ពេលដែលហ្វូងមនុស្សចាប់ផ្តើមនាំគ្នាដើរតាមទ្រង់ ទ្រង់ក៏លើកលក្ខខណ្ឌនៃភាពជាសិស្សដែលពិបាកអនុវត្តឡើង ដើម្បីញែកអ្នកជឿពីអ្នកមិនជឿ។

មានពេលមួយមានហ្វូងមនុស្សបានដើរតាមព្រះយេស៊ូវ ហើយទ្រង់បានព្រមានដល់អស់អ្នកនោះថា ពួកគេត្រូវលៃលកមើលជាមុន។ ទ្រង់មានបន្ទូលថា៖

*ដ្បិតក្នុងពួកអ្នករាល់គ្នា បើមានអ្នកណាចង់សង់ផ្ទះពីថ្ម តើមិនអង្គុយលៃលកមើលជាមុនទេឬអី ដើម្បីឲ្យដឹងជាមានល្មមនឹងធ្វើបង្ហើយបានឬមិនបាន ក្រែងកាលណាដាក់ជើងជញ្ជាំង រួចបង្ហើយមិនបាន នោះអស់អ្នក*

*ណាដែលឃើញក៏នឹងសើចចំអកឲ្យ ដោយពាក្យថា អ្នកនេះបានចាប់ផ្តើមសង់ផ្ទះ តែបង្ហើយមិនបាន ឬតើមានស្តេចឯណា ដែលរៀបចេញទៅច្បាំងនឹងស្តេច១ទៀត ឥតអង្គុយពិគ្រោះមើលជាមុនសិន ដើម្បីឲ្យដឹងជាខ្លួននាំពល១ម៉ឺន ទៅតទល់នឹងស្តេច ដែលនាំពល២ម៉ឺន មកច្បាំងបានឬមិនបាន បើឃើញថាមិនបានទេ នោះទ្រង់នឹងចាត់រាជទូត ឲ្យទៅស៊ើបសួរពីកិច្ច ដែលចងស្ពានមេត្រីនឹងគ្នាជាយ៉ាងណាក្នុងកាលដែលស្តេចនោះនៅឆ្ងាយនៅឡើយ* (លូកា ១៤:២៨-៣២)។

យោងតាមបទគម្ពីរខាងលើនេះយើងឃើញថា ព្រះយេស៊ូវបានប្រៀបប្រដូចជីវិតជាគ្រីស្ទបរិស័ទទៅនឹងដំណើរនៃការសាងសង់ និងការធ្វើសង្គ្រាម។

ទ្រង់បានមានបន្ទូលថា ការចាប់ផ្តើមសាងសង់អគារដែលមិនដឹងថាមានថវិកាគ្រប់គ្រាន់ ដើម្បីបង្ហើយការសាងសង់នោះ វាគឺជារឿងដ៏ល្ងង់ខ្លៅមួយ។ ជាងនេះទៅទៀត អគារដែលពុំទាន់បានបញ្ចប់នោះនឹងក្លាយជាសំណង់ដែលឈរទ្រើងមួយដែលវានឹងបង្ហាញពីភាពខ្វះចន្លោះនៃគំនិតរបស់ម្ចាស់។

ពិតណាស់! បើបុគ្គលម្នាក់សម្រេចចិត្តដើរតាមព្រះគ្រីស្ទនៅកន្លែងប្រារព្ធពិធីធំៗរបស់គ្រីស្ទបរិស័ទ និងកន្លែងដែលមានភាព

កក់ក្ដៅ នោះងាយនឹងឲ្យគាត់សម្រេចចិត្តដើរតាមមែន។ ប៉ុន្តែ ការពិបាកគឺការលះអាល័យខ្លួនឯង និងការលើឈើឆ្កាងជាប្រចាំថ្ងៃ ដើម្បីដើរតាមព្រះយេស៊ូវ។ ទោះបើការក្លាយជាគ្រីស្ទបរិស័ទមិនមានការបង់ថ្លៃអ្វីសោះក៏ដោយ តែការក្លាយជាអ្នកជឿដ៏នឹងធឹងម្នាក់ទាមទារឲ្យមានការលះបង់ជាច្រើនដូចជា ការពលីជីវិត ការញែកខ្លួនចេញពីលោកីយ៍ និងការរងទុក្ខ ដើម្បីបម្រើព្រះគ្រីស្ទ។ ការចាប់ផ្ដើមរស់នៅជាគ្រីស្ទបរិស័ទគឺជាការងាយស្រួលមែន។ ប៉ុន្តែការតស៊ូរស់នៅជាគ្រីស្ទបរិស័ទដែលប្រឈមមុខនឹងការល្អឬការអាក្រក់ មានឬក្រសប្បាយឬកើតទុក្ខពីមួយថ្ងៃទៅមួយថ្ងៃ នោះជាការពិបាកណាស់។

លោកីយ៍កំពុងតែសង្កេតមើលជីវិតយើង។ ពួកគេដឹងក្នុងវិញ្ញាណថា ជីវិតជាគ្រីស្ទបរិស័ទតម្រូវឲ្យមានភាពងប់ងុលក្នុងជំនឿ បើមិនដូច្នោះវាគ្មានតម្លៃអ្វីសោះ។ នៅពេលដែលលោកីយ៍ជួបគ្រីស្ទបរិស័ទដ៏ឧស្សាហ៍ម្នាក់ ប្រហែលជាពួកគេនឹងមើលងាយមើលថោកជេរប្រមាថ ចំអកឲ្យ ប៉ុន្តែពួកគេគោរពឲ្យតម្លៃអ្នកឧស្សាហ៍ក្នុងការដើរតាមព្រះគ្រីស្ទនៅក្នុងចិត្តពួកគេវិញ។ ប៉ុន្តែនៅពេលដែលលោកីយ៍ជួបគ្រីស្ទបរិស័ទមុខពីរដែលមិនបានបម្រើព្រះជាម្ចាស់អស់ពីចិត្តវិញនោះពួកគេមានតែការស្អប់ខ្ពើម។ លោកីយ៍ចាប់ផ្ដើមចំអកឡកឡឺយឲ្យគ្រីស្ទបរិស័ទមុខពីរនោះដោយការខឹងងថា *"អាមួយនេះវាចាប់ផ្ដើម*

*សាងសង់ហើយ តែវាមិនមានលទ្ធភាពបញ្ចប់បានសោះ។ វារំភើបចិត្តនឹងប្រាប់គេពីជីវិតផ្លាស់ប្រែវាណាស់ ប៉ុន្តែឥឡូវវានៅតែដូចពីមុនដដែលដូចតែគេតែឯងដែរហ្នឹង។ វាចាប់ផ្តើមឡើងលឿនដូចព្យុះ ប៉ុន្តែឥឡូវវាជាប់ភក់ហើយ»*។

ហេតុដូច្នេះហើយទើបព្រះសង្គ្រោះបានមានបន្ទូលថា *«ឯងត្រូវតែលៃលកមើលជាមុន»*។

ការប្រៀបប្រដូចទីពីរបស់ព្រះយេស៊ូវទាក់ទងនឹងស្តេចមួយអង្គដែលប្រុងនឹងប្រកាសសង្គ្រាមជាមួយប្រទេសផ្សេងទៀត។ តើវាមិនមែនជាការសម្រេចចិត្តដែលប្រកបដោយសុភវិនិច្ឆ័យក្នុងការដែលស្តេចនោះគន់គូរថា ពលទាហានទាំងមួយម៉ឺននាក់របស់ទ្រង់អាចមានលទ្ធភាពវាយកំទេចខ្មាំងសត្រូវដែលមានចំនួនទ្វេដងនៃចំនួនទាហានរបស់ទ្រង់ទេឬអី? តើវាគួរឲ្យអស់សំណើចយ៉ាងណាទៅ បើស្តេចនោះប្រកាសសង្គ្រាមហើយ តែបែរជាគិតវិញថា យើងមិនគួរច្បាំងឡើយ ស្របពេលពលទាហានទាំងសងខាងកំពុងតែសម្រុកចូលប្រយុទ្ធគ្នា? បើដូច្នោះគាត់មានតែគ្រវីទង់សសុំចុះចាញ់ហើយឱនក្រាបនៅលើដីសុំក្តីមេត្តាពីពួកគេ។

ជីវិតគ្រីស្ទបរិស័ទ មានលក្ខណៈស្រដៀងគ្នានឹងអ្នកធ្វើសឹកសង្គ្រាមមែនទែន។ ជីវិតជាគ្រីស្ទបរិស័ទមានសត្រូវដ៏សាហាវឃោរ-

ឃៅគឺ លោកីយ៍ សាច់ឈាម និងអារក្សសាតាំង ហើយក៏មានទាំងការបង្អាក់ទឹកចិត្ត ការកាប់ចាក់ និងការឈឺចាប់ខ្លោចផ្សា មានផ្ទុកដោយជំងឺរសាប់រសល់ដេកមិនលក់ ហើយប្រាថ្នាចង់ឲ្យតែភ្លឺឆាប់ៗ មានតែទឹកភ្នែក អំម្រែកយ៉ាងលំបាកលំបិន និងការល្បួងលជាច្រើន។ ហើយនៅជុំវិញខ្លួនឃើញមានតែអ្នកស្លាប់រាល់តែថ្ងៃ។

អស់អ្នកដែលចាប់ផ្តើមដើរតាមព្រះគ្រីស្ទគួរតែចងចាំពីព្រឹត្តិការណ៍នៅ ច្បារគែតសេម៉ានី ទីក្រាលថ្ម កាបាថា (យ៉ូហាន ១៩:១៣) និងភ្នំលលាដ៍ក្បាល។ បន្ទាប់មកគាត់គួរតែលៃលកពីការលះបង់ក្នុងការដើរតាមទ្រង់ជាមុនសិន។ ក្រោយនោះមកគាត់មានជម្រើសពីរយ៉ាងដែលគាត់អាចជ្រើសយក ការប្តេជ្ញាចិត្តយ៉ាងមុតមាំដើរតាមព្រះគ្រីស្ទ ឬក៏បោះបង់ទ្រង់ចោល ព្រោះគាត់គិតថាការលះបង់ក្នុងការដើរតាមទ្រង់ហួសហេតុពេក។

យោងតាមការប្រៀបប្រដូចទាំងពីរខាងលើនេះ  ព្រះអម្ចាស់យេស៊ូវបានក្រើនរំឭកដល់អស់អ្នកដែលស្តាប់ទ្រង់ថា ពួកគេមិនគួរសម្រេចចិត្តមកធ្វើជាសិស្សរបស់ទ្រង់លឿនពេកនោះទេ។ ទ្រង់បានមានបន្ទូលទៀតថា ពួកគេនឹងជួបការបៀតបៀន ភាពខ្លោចផ្សា និងការរងទុក្ខវេទនាផ្សេងៗ។ ដូច្នេះ មុននឹងសម្រេចចិត្តធ្វើជាសិស្សរបស់ទ្រង់ ពួកគេគួរតែលៃលកជាមុនសិន។

តើអ្វីទៅជាតម្លៃនៃការដើរតាមព្រះយេស៊ូវ? ខខាងក្រោមនេះនឹងប្រាប់ពីចម្លើយយ៉ាងដូច្នេះថា៖ *«ដូច្នេះ អស់អ្នកណាក្នុងពួកអ្នករាល់គ្នា ដែលមិនលះអាល័យពីរបស់ទ្រព្យខ្លួនទាំងអស់ នោះធ្វើជាសិស្សខ្ញុំមិនបានទេ»* (លូកា ១៤:៣៣)។

តម្លៃនោះគឺ **គ្រប់អ្វីៗទាំងអស់** មិនថាជីវិតឬទ្រព្យសម្បត្តិនោះឡើយ។ យើងឃើញថា ព្រះសង្គ្រោះបានលះបង់គ្រប់ទាំងអស់ ហេតុដូច្នេះហើយ  អស់អ្នកដែលនឹងដើរតាមទ្រង់ត្រូវតែលះបង់គ្រប់អ្វីៗទាំងអស់ដូចទ្រង់ដែរ។ ប្រសិនបើទ្រង់ ដែលជាអ្នកមានស្តុកស្តម្ភបំផុត ហើយទ្រង់បានស្ម័គ្រព្រះទ័យយាងមកធ្វើជាអ្នកក្រ-ខ្សត់ទៅហើយនោះ តើសិស្សរបស់ទ្រង់សមនឹងទទួលបានមកុដដោយគ្រាន់តែលះបង់បន្តិចបន្តួចឬ?

ព្រះអម្ចាស់យេស៊ូវក៏បានបញ្ចប់សេចក្តីបង្រៀនដោយសង្ខេបយ៉ាងខ្លីថា៖ *«អំបិលជារបស់ល្អ តែបើបាត់ជាតិប្រៃហើយ តើនឹងយកអ្វីធ្វើឲ្យប្រៃឡើងវិញបាន»* (លូកា ១៤:៣៤)។

គ្រាសម័យដើមនៃព្រះគម្ពីរ  មនុស្សនៅជំនាន់នោះមើលទៅហាក់ដូចជាមិនមានអំបិលស្អាត ដូចជាអំបិលដែលយើងមានរាល់ថ្ងៃនេះសោះ។ អំបិលរបស់គេហាក់ដូចជាមានភាពប្រឡូកប្រឡាក់ខ្លះដូចជាមានលាយខ្សាច់ៗល។ ហើយមិនដឹងមកពីហេតុអ្វីបានជានាំ

ឲ្យអំបិលបាត់បង់ជាតិប្រៃ ដែលបណ្ដាលឲ្យអំបិលបាត់បង់តម្លៃអស់រលីង។ វាមិនអាចយកមកប្រើការបានទៀតឡើយ សូម្បីតែធ្វើជាដី ឬជាជីដាំដំណាំផ្សេងៗក៏មិនបានដែរ។ ពេលខ្លះគេយកវាមកចាក់បំពេញថ្លុកតាមផ្លូវដើរប៉ុណ្ណោះ។ ដូច្នេះវា «...គ្មានប្រយោជន៍ទៀតសោះ មានតែបោះបង់ចោលទៅក្រៅ ឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ» (ម៉ាថាយ ៥:១៣)។

ការប្រៀបប្រដូចខាងលើនេះបានបង្ហាញយ៉ាងច្បាស់ថា គោល-បំណងចម្បងរបស់គ្រីស្ទបរិស័ទគឺ ថ្វាយសិរីល្អដល់ព្រះជាម្ចាស់តាមរយៈការថ្វាយជីវិតបម្រើទ្រង់ឲ្យអស់ពីដួងចិត្ត។ គ្រីស្ទបរិស័ទអាចបាត់បង់ភាពឆេះឆួលនៃការបម្រើព្រះជាម្ចាស់ បើគាត់នៅតែប្រមូលទ្រព្យសម្បត្តិទុកនៅផែនដីនេះ ហើយស្វែងរកតែភាពសុខស្រួលសម្រាប់តែខ្លួនឯង ក៏ដូចជាព្យាយាមធ្វើឲ្យកិត្តិយសកេរ្តិ៍ឈ្មោះខ្លួនបានល្បីរន្ទឺ ព្រមទាំងយកជីវិត និងទេពកោសល្យរបស់ខ្លួនទៅបម្រើលោកីយ៍ដ៏មិនស្ថិតស្ថេរនេះ។

ប្រសិនបើអ្នកជឿយល់ច្រឡំពីគោលបំណងចម្បងរបស់ខ្លួន នោះគាត់ក៏នឹងយល់ច្រឡំពីអ្វីៗផ្សេងទៀតដែរ។ គាត់គ្មានប្រយោជន៍ទាល់តែសោះ លើកលែងតែប្រើដូចជាអំបិលដែលបាត់បង់រសជាតិទុកសម្រាប់ឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ។ ប្រយោជន៍របស់គាត់មាន

តែឲ្យលោកីយ៍សើចចំអក ជាន់ឈ្លី ហើយមើលងាយតែប៉ុណ្ណោះ។

ព្រះបន្ទូលចុងក្រោយនៃរឿងនេះគឺយ៉ាងដូច្នេះ៖ *«...អ្នកណាដែលមានត្រចៀកសំរាប់ស្តាប់ ឲ្យស្តាប់ចុះ»* (លូកា ១៤:៣៥)។

ជារឿយៗ នៅពេលដែលព្រះអម្ចាស់បន្លឺព្រះបន្ទូលយ៉ាងធ្ងន់ដូចនេះ ទ្រង់តែងតែបន្ថែមពាក្យពេចន៍ដូចខាងលើនេះ។ មើលទៅហាក់បីដូចជាទ្រង់ជ្រាបថា មនុស្សភាគច្រើននឹងបដិសេធព្រះបន្ទូលរបស់ទ្រង់។ ទ្រង់ជ្រាបថា នឹងមានអ្នកខ្លះព្យាយាមកាត់ស្រាយព្រះបន្ទូលរបស់ទ្រង់ខុស ដើម្បីព្យាយាមដកយកលក្ខខណ្ឌដ៏ពិបាកនៃភាពជាសិស្សដែលទ្រង់តម្រូវឲ្យមានចេញ។

ប៉ុន្តែទ្រង់ក៏ជ្រាបដែរថា នឹងមានមនុស្សក្មេងចាស់បើកចិត្ត ហើយចុះចូលនឹងលក្ខខណ្ឌដ៏ឧត្តុង្គឧត្តមរបស់ទ្រង់។ ហេតុដូច្នេះហើយបានជាទ្រង់ទុកទ្វារចំហ ដើម្បីទុកជម្រើសឲ្យពួកគេចូល។ *«...អ្នកណាដែលមានត្រចៀកសំរាប់ស្តាប់ ឲ្យស្តាប់ចុះ»* អស់អ្នកដែលបានឮ គឺជាអ្នកដែលបានលៃលកជាមុន ហើយនៅពោលថា៖

*ខ្ញុំបានសម្រេចចិត្ត ដើរតាមព្រះយេស៊ូវ*
*បើសិនគ្មានគេតាម ខ្ញុំនៅតែតាមទ្រង់*
*ឈើឆ្កាងនៅខាងមុខ លោកីយ៍នៅខាងក្រោយ*
*ខ្ញុំមិនបែរក្រោយ ខ្ញុំមិនបែរក្រោយ។*

## ជំពូកទី១២

# ស្រមោលនៃការស្លាប់ ដោយសារជំនឿ

នៅពេលដែលមនុស្សម្នាក់ពិតជាបានប្តេជ្ញាចិត្តដើរតាមព្រះយេស៊ូវគ្រីស្ទ ពេលនោះការស្លាប់ ឬរស់មិនសំខាន់ចំពោះគាត់ឡើយ។ អ្វីដែលសំខាន់នោះគឺឲ្យតែគាត់បានថ្វាយសិរីល្អដល់ព្រះអម្ចាស់ នោះគ្រប់គ្រាន់ហើយ។

ពេលដែលលោកអ្នកអានសៀវភៅ *The Triumph of John and Betty Stam*[១] នោះលោកអ្នកនឹងឃើញឃ្លាមួយដែលសៀវភៅនោះបានលើកឡើងម្តងហើយម្តងទៀតថា “...គឺឲ្យតែខ្ញុំបានដំកើងព្រះគ្រីស្ទក្នុងរូបកាយខ្ញុំវិញ...ទោះរស់ឬស្លាប់ក្តី” (ភីលីព ១:២០)។

នៅក្នុងសៀវភៅកំណត់ហេតុរបស់លោក ជីម អេលាត (Jim Elliot) ក៏មានសម្រង់សម្តីដូចទៅនឹងខនេះដែរ។ នៅពេលដែលលោកនៅជានិស្សិតនៅសាកលវិទ្យាល័យ វីតថឹន (Wheaton

College) លោកបានសរសេររៀបរាប់ថា «ខ្ញុំបានត្រៀមខ្លួនស្លាប់សម្រាប់ជនជាតិ អ័ងខឹស (Aucas) រួចទៅហើយ»។ មានពេលមួយគាត់បានសរសេរទៀតថា៖

> ឱ! ព្រះវរបិតា សូមដកយកជីវិតទូលបង្គំ និងឈាមរបស់ទូលបង្គំ ប្រសិនបើទ្រង់សព្វព្រះហឫទ័យ ហើយសូមឲ្យភ្លើងរបស់ទ្រង់ទទួលយកឈាមនោះទៅដុតផង។ ទូលបង្គំនឹងមិនទុកឈាមនោះទេ ព្រោះវាមិនមែនជារបស់ទូលបង្គំដែលត្រូវឲ្យទូលបង្គំរក្សាទុកនោះឡើយ។ សូមទ្រង់ដកចុះ ឱព្រះដ៏ជាម្ចាស់អើយ សូមទ្រង់យកទាំងអស់ចុះ! សូមទ្រង់បង្ហូរជីវិតទូលបង្គំឲ្យទៅជាតង្វាយដ៏វិសុទ្ធសម្រាប់លោកីយ៍ទាំងមូល ព្រោះឈាមដែលមានតម្លៃជាឈាមដែលហូរនៅមុខអាសនារបស់ទ្រង់តែប៉ុណ្ណោះ។[២]

វាហាក់ដូចជាបង្ហាញឲ្យឃើញថា វីរបុរសនិងវីរនារីរបស់ព្រះជាម្ចាស់ភាគច្រើនបានរាប់ជីវិតរបស់ខ្លួនថាគ្មានតម្លៃទៀត ពេលដែលពួកគេកាន់តែស្គាល់ទ្រង់ ដូចគ្នានឹងគំរូខាងលើផងដែរ។ ពួកគេទទួលស្គាល់ថា *«បើគ្រាប់ស្រូវដែលធ្លាក់ចុះទៅដីមិនងាប់ទេ នោះក៏នៅតែ១ដដែល តែបើងាប់វិញ នោះក៏បង្កើតផលជាច្រើនឡើង»* (យ៉ូហាន ១២:២៤)។ ពួកគេបានដាក់ចិត្តដាក់កាយធ្វើជាគ្រាប់ស្រូវដែលងាប់ ហើយបង្កើតផលជាច្រើន។

នេះហើយជាអាកប្បកិរិយាដែលព្រះសង្គ្រោះបានបង្រៀនសិស្សរបស់ទ្រង់ *«ដ្បិតអ្នកណាដែលចង់ឲ្យរួចជីវិត នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិត ដោយព្រោះខ្ញុំ នោះនឹងបានជីវិតវិញ»* (លូកា ៩:២៤)។

នៅពេលដែលយើងកាន់តែគិត យើងកាន់តែយល់ឃើញថា បទគម្ពីរនេះពិតជាត្រឹមត្រូវមែន។

ដំបូង យើងត្រូវដឹងថា ជីវិតរបស់យើងនេះមិនមែនជាកម្មសិទ្ធិរបស់យើងឡើយ។ វាជាកម្មសិទ្ធិរបស់ព្រះយេស៊ូវដែលបានទិញយើងដោយព្រះលោហិតដ៏ថ្លៃវិសេសរបស់ទ្រង់។ តើយើងរាល់គ្នាស័ក្តិសមនឹងរក្សាជីវិតដែលជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ឬ? លោក ស៊ី. ធី. ស្ទឹដ (C. T. Studd) បានឆ្លើយសំណួរនេះសម្រាប់ខ្លួនគាត់ នៅពេលដែលគាត់សរសេររៀបរាប់ពី ការនេះនៅសាកលវិទ្យាល័យខេមប្រ៊ីឆ (Cambridge University) ក្នុងប្រទេសអង់គ្លេសនៅឆ្នាំ ១៨៨៣៖

> ខ្ញុំបានដឹងហើយថា ព្រះយេស៊ូវសុគតសម្រាប់ខ្ញុំ ប៉ុន្តែខ្ញុំមិនដែលយល់យ៉ាងច្បាស់ថា បើទ្រង់ពិតជាសុគតសម្រាប់ខ្ញុំមែន នោះមានន័យថាខ្ញុំមិនមែនជាកម្មសិទ្ធិរបស់ខ្លួនទៀតទេ។ ការប្រោសលោះមានន័យថា ការទិញយកមកវិញ។ ហេតុដូច្នេះហើយ បើខ្ញុំជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ នោះមាន

ន័យថា ខ្ញុំត្រូវថ្វាយគ្រប់អ្វីៗទាំងអស់ទៅទ្រង់ តែបើខ្ញុំព្យាយាមទុកអ្វីដែលមិនមែនជាកម្មសិទ្ធិរបស់ខ្ញុំ នោះមានន័យថា ខ្ញុំគឺជាចោរ។ នៅពេលដែលខ្ញុំបានយល់យ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រីស្ទពិតជាបានសុគតជំនួសខ្ញុំ នោះគ្មានអ្វីដែលខ្ញុំពិបាកនឹងលះបង់សម្រាប់ទ្រង់ទៀតសោះឡើយ។

បន្ទាប់មក យើងរាល់គ្នានឹងត្រូវស្លាប់ លុះត្រាតែព្រះអម្ចាស់យាងមកវិញ ទាល់ពេលយើងនៅមានជីវិតនៅឡើយ។ តើការដែលយើងស៊ូស្លាប់ ដើម្បីបម្រើព្រះជាម្ចាស់ មិនមែនជាការល្អជាងការដែលយើងគ្រាន់តែស្លាប់ហើយមានឈ្មោះក្នុងបញ្ជីមរណភាពទេឬអី? តើសម្រង់សម្ដីរបស់លោក ជីម អេលាត (Jim Elliot) ដែលគាត់លើកឡើងថា «*បុគ្គលម្នាក់ដែលឲ្យនូវអ្វីដែលគាត់មិនអាចរក្សាទុកបាន ដើម្បីឈោងចាប់យកនូវអ្វីដែលគាត់នឹងមិនអាចបាត់បង់បាន បុគ្គលនោះមិនមែនជាមនុស្សល្ងីល្ងើ*» មិនត្រឹមត្រូវទេឬអី?

ចំណុចទីបី បើព្រះយេស៊ូវពិតជាបានសុគតជំនួសយើងមែនដូច្នេះការដែលយើងស៊ូស្លាប់ថ្វាយទ្រង់វិញ នោះជាការស័ក្តិសមណាស់។ បើអ្នកបម្រើមិនមានសិទ្ធិលើសចៅហ្វាយរបស់ខ្លួន ចុះតើយើងមានសិទ្ធិអ្វីឲ្យយើងចូលទៅស្ថានសួគ៌ដោយគ្មានទុក្ខលំបាកដូចដែលព្រះអម្ចាស់យេស៊ូវបានប្រឈមមុខនោះ? បន្ទាប់ពីលោក

ស៊ី. ធី. ស្ទឹដ (C. T. Studd) បានពិចារណាលើទស្សនៈខាងលើនេះ រួចមកគាត់ក៏បានមានប្រសាសន៍ថា «*ប្រសិនបើព្រះយេស៊ូវដ៏ជាព្រះពិតបានសុគតជំនួសខ្ញុំមែន នោះគ្មានការលះបង់ណាមួយដែលធំហួសពេកសម្រាប់ខ្ញុំ ដើម្បីធ្វើថ្វាយទ្រង់វិញនោះឡើយ*»។

ចំណុចបញ្ចប់ ការដែលយើងឱបក្រសោបជីវិតខ្លួនឯង ស្របពេលដែលយើងអាចប្រើជីវិតនោះ ដើម្បីនាំព្រះពរដ៏អស់កល្បជានិច្ចទៅកាន់មនុស្សក្នុងលោកីយ៍នេះ នោះគឺជាបទឧក្រិដ្ឋមួយ។ មនុស្សភាគច្រើនបានចំណាយពេលពេញមួយជីវិតរបស់ខ្លួន ដើម្បីស្រាវជ្រាវរកឱសថដែលគ្រាន់តែជាចំណង់របស់ពួកគេ។ អ្នកផ្សេងទៀតហ៊ានស្លាប់ ដើម្បីជួយសង្គ្រោះអ្នកដែលខ្លួនស្រឡាញ់ចេញពីអគារដែលកំពុងឆាបឆេះ។ ហើយមានអ្នកខ្លះទៀតបានពលីជីវិតក្នុងសឹកសង្គ្រាម ដើម្បីជួយសង្គ្រោះមាតុភូមិរបស់ខ្លួនឲ្យរួចពីកណ្ដាប់ដៃខ្មាំងសត្រូវ។ ចុះចំពោះព្រលឹងរបស់មនុស្សវិញ តើវាមានតម្លៃប៉ុណ្ណាសម្រាប់យើង? តើយើងហាននិយាយដូចលោក អេហ្វ. ដាប់ប៊ិលយូ. អេឆ. មៃយ៉ុរស៍ (F. W. H. Myers) ថា៖

*ខ្ញុំដូចជាមើលឃើញព្រលឹងរបស់មនុស្ស*
*ដែលសមនឹងយកឈ្នះតែជាប់ឃុំ*

*ទោះជាទាសករ ក៏អាចសមធ្វើជាស្តេចធំ*
*ចែកចាយនូវក្តីសង្ឃឹមតែមួយគត់ដែលគ្មានខ្លឹមសារ។*
*គួរឲ្យអាណិតណាស់ដោយសារគេស្តាប់ជាក់ច្បាស់នឹងការសម្តែង*
*ភ្លាមនោះមានសេចក្តីប្រាថ្នាដ៏ខ្លាំងក្លាជ្រៀតចូលប្រជែង*
*មកអង្រួនដួងចិត្តខ្ញុំដូចជាសំឡេងត្រែលាន់រំពង។*
*ឱ! ខ្ញុំចង់សង្គ្រោះអ្នកទាំងនេះ និងស្ម័គ្របូជាជីវិតដើម្បីសង្គ្រោះគេ*
*ស៊ូស្លាប់ដើម្បីជីវិតរបស់គេ*
*និងស្ម័គ្រវិនាសខ្លួនឯងដើម្បីគេទាំងអស់គ្នា។*

ស៊ូស្លាប់ដើម្បីជីវិតរបស់គេ និងស្ម័គ្រវិនាសខ្លួនឯងដើម្បីគេទាំងអស់គ្នា។ នោះមិនមែនមានន័យថា មនុស្សគ្រប់គ្នាសុទ្ធតែត្រូវស្លាប់ដើម្បីជំនឿនោះទេ។ ព្រះជាម្ចាស់បានបម្រុងទុកមនុស្សមួយចំនួនតូច ដើម្បីស្លាប់ដោយ ត្រូវគេដុតនឹងភ្លើង ចាក់ដោយលំពែង និងកាត់ក្បាលចោល។ ប៉ុន្តែសម្រាប់យើងរាល់គ្នាវិញ យើងអាចមានអាកប្បកិរិយាស៊ូស្លាប់ ចិត្តឆេះឆួល ហើយប្តេជ្ញាចិត្តដើម្បីជំនឿដូចពួកមរណសាក្សី។ យើងរាល់គ្នាអាចរស់នៅក្នុងនាមជាអ្នកដែលបានថ្វាយជីវិតខ្លួនដល់ព្រះគ្រីស្ទរួចទៅហើយ។

*ទោះឈឺឬជាមានឈើឆ្កាងមានម្ជុល*

*ឥន្ទធនូពៃនពត់ រួមទាំងផ្គរលាន់*

*បង្ក្រាបរូបកាយព្រលឹងខ្ញុំឲ្យទាន់*

*ឲ្យទ្រង់រួសរាន់ក្នុងរាស់ជីវិតខ្ញុំទៅ។*

— មិនស្គាល់អ្នកនិពន្ធ

## ជំពូកទី១៣

# រង្វាន់របស់គ្រីស្ទបរិស័ទ

ជីវិតដែលបានលះបង់ដើម្បីព្រះអម្ចាស់យេស៊ូវនឹងទទួលបានរង្វាន់ជាទីគាប់ចិត្ត។ អំណរអរ និងភាពរីករាយគឺជាធាតុពិតនៃជីវិតក្នុងការដើរតាមព្រះគ្រីស្ទ។

ព្រះសង្គ្រោះតែងមានបន្ទូលដដែលថា *«អ្នកណាដែលរកបានជីវិតខ្លួន នោះនឹងត្រូវបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិត ដោយយល់ដល់ខ្ញុំ នោះនឹងបានជីវិតវិញ»*។ តាមពិត ព្រះបន្ទូលត្រង់នេះទ្រង់បានលើកឡើងដដែលៗស្ទើរតែច្រើនជាងអ្វីៗផ្សេងទៅទៀតនៅក្នុងដំណឹងល្អទាំងបួន (សូមអាន ម៉ាថាយ ១០:៣៩, ១៦:២៥; ម៉ាកុស ៨:៣៥; លូកា ៩:២៤, ១៧:៣៣; យ៉ូហាន ១២:២៥)។ ចុះហេតុដូចម្ដេចបានជាទ្រង់លើកឃ្លាដដែលៗយ៉ាងដូច្នេះ? តើមិនមែនដោយសារតែ វាជាគោលការណ៍ចម្បងមួយរបស់គ្រីស្ទបរិស័ទដែលគេឲ្យឈ្មោះថា ជីវិតឱបក្រសោបជាជីវិតដែលបាត់បង់ តែជីវិតដែលលះបង់ដើម្បីបម្រើទ្រង់គឺជាជីវិតដ៏ពិត ជីវិតដែលទទួលបាន

ការសង្គ្រោះ មានអំណរ និងជាជីវិតរស់នៅអស់កល្បជានិច្ចទេឬអី?

ការធ្វើជាគ្រីស្ទបរិស័ទដែលមិនបានបម្រើព្រះជាម្ចាស់អស់ពីចិត្ត នឹងនាំឲ្យជីវិតរបស់អ្នកនោះមានពេញដោយការឈឺចាប់។ ការបម្រើទ្រង់ឥតឈប់ឈរគឺជាផ្លូវដែលធ្វើឲ្យយើងទទួលបានអំណរដ៏គាប់ប្រសើរពីទ្រង់។

ការធ្វើជាសិស្សដ៏ពិតគឺជាការធ្វើជាខ្ញុំបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ ហើយយើងនឹងឃើញថាការបម្រើទ្រង់គឺមានសេរីភាពពេញលេញ។ អស់អ្នកដែលពោលថា *«...ខ្ញុំស្រឡាញ់ ចៅហ្វាយខ្ញុំ...ខ្ញុំមិនចេញទៅទេ»* (និក្ខមនំ ២១:៥) អ្នកនោះមានសេរីភាពពិតប្រាកដ។

សិស្សរបស់ព្រះយេស៊ូវមិនជាប់ជំពាក់ជំពិននឹងរឿងកំប៉ិកកំប៉ុក ឬរឿងដែលមិននៅស្ថិតស្ថេរនោះទេ។ គាត់ខ្វល់ខ្វាយតែនឹងការដែលនៅអស់កល្បជានិច្ចប៉ុណ្ណោះ។ ជាក់ស្តែងដូចជាលោក ហ៉ដសិន ថេល័រ (Hudson Taylor) ជាដើម គាត់អសប្បាយនឹងស្កប់ចិត្តជាមួយនឹងរបស់ដ៏បន្តិចបន្តួចដែលគាត់មាន។

គ្រីស្ទបរិស័ទមើលទៅដូចជាមិនសូវមានឈ្មោះបោះសម្លេង តែគាត់ល្បីល្បាញដែរ។ ទោះបើគាត់ជាអ្នកដែលគ្មាននរណាស្គាល់ តែមនុស្សទាំងអស់ស្គាល់គាត់យ៉ាងច្បាស់។ ទោះបើគេចាត់ទុកគាត់ដូចជាមនុស្សហៀបនឹងស្លាប់ តែគាត់ពិតជានៅមានជីវិត។ ទោះបើគេ

ធ្វើទារុណកម្មគាត់ តែគាត់គ្មានទោសដល់ស្លាប់ទេ។ ទោះបើគេធ្វើឲ្យគាត់មានទុក្ខព្រួយ តែគាត់សប្បាយចិត្តជានិច្ច។ ទោះបើគាត់ជាអ្នកក្រ តែគាត់បានធ្វើឲ្យមនុស្សជាច្រើនក្លាយទៅជាអ្នកមាន ទោះបើគាត់គ្មានអ្វីសោះ តែគាត់មានសព្វគ្រប់ទាំងអស់វិញ (២កូរិនថូស ៦:៩-១០)។

បើជីវិតនៃគ្រីស្ទបរិស័ទដ៏ពិតជាជីវិតមួយដែលស្កប់ចិត្តខាងឯវិញ្ញាណជាងគេនៅផែនដីនេះ នោះយើងអាចដឹងប្រាកដថា គ្រីស្ទបរិស័ទនឹងទទួលរង្វាល់ច្រើនជាងគេនៅឯស្ថានសួគ៌។ «លុះដល់បុត្រមនុស្សប្រកបដោយសិរីរុងរឿងព្រះបិតារបស់ព្រះអង្គយាងមកជាមួយពួកទេវតារបស់ព្រះអង្គ ព្រះអង្គនឹងប្រទានរង្វាន់ ឬដាក់ទោសម្នាក់ៗ តាមអំពើដែលខ្លួនបានប្រព្រឹត្ត» (ម៉ាថាយ ១៦:២៧ គខប)។

ហេតុដូច្នេះហើយ មនុស្សដែលទទួលព្រះពរពិតប្រាកដទាំងនៅពេលនេះ និងអស់កល្បជានិច្ច នោះគឺជាអ្នកដែលអាចនិយាយដូចលោក បៀល ប័រដិន (Bill Borden) ជានិស្សិតនៅសាកលវិទ្យាល័យយ៉េល (Yale) ថា៖ «ព្រះអម្ចាស់យេស៊ូវអើយ ទូលបង្គំបានដកខ្លួនលែងធ្វើជាម្ចាស់លើជីវិតខ្លួនឯងទៀតហើយ។ ទូលបង្គំសូមយាងទ្រង់មកសោយរាជ្យក្នុងចិត្តទូលបង្គំ។ សូមទ្រង់បំផ្លាស់បំប្រែ លាងសម្អាត ហើយប្រើប្រាស់ទូលបង្គំតាមព្រះហឫទ័យទ្រង់ចុះ»។

ព្រះអង្គមិនសព្វព្រះទ័យឃើញមនុស្សវិនាសបង់
ព្រះយេស៊ូវគ្រងលើបល្ល័ង្កពេញដោយសិរីល្អដោត
ទ្រង់ទតឃើញលោកានៃមនុស្សគួរឲ្យអាណិតពេញដោយទុក្ខសោក
ទ្រង់យាងមកលោកលះព្រះជន្មដោយក្ដីស្រឡាញ់។
វិនាសហើយ វិនាសហើយ! មនុស្សវិនាសនៅនឹងមុខយើង
ដួងចិត្តក៏ចំបែងរងទុក្ខខ្លោចផ្សារ
ព្រះគ្រីស្ទសង្គ្រោះតែគ្មានអ្នកប្រាប់ពួកគេឡើយណា
ឲ្យរួចសង្ខារផុតពីបាបកម្ម។

ព្រះអង្គមិនសព្វព្រះទ័យឃើញមនុស្សវិនាសបង់
ទ្រង់យាងមកគង់ក្នុងលោកាដ៏សែនវេទនា
ទ្រង់រកអ្នកវង្វេងទ្រង់លួងលោមអ្នកកើតទុក្ខា
ទ្រង់ប្រោសឲ្យជាដល់ចិត្តដែលខ្ទេចខ្ទាំនិងបាក់បែក។
វិនាសហើយ វិនាសហើយ! រដូវចម្រូតកំពុងតែទៅហួស
អ្នកច្រូតក៏តិច យប់យន់ទន់ទោរមកដល់
ព្រះគ្រីស្ទត្រាស់ហៅអ្នក មកច្រូតចូរកុំរុញរា
ព្រោះព្រលឹងនៃមនុស្សម្នាមានតម្លៃណាស់ណាសម្រាប់ទ្រង់។

មនុស្សខ្លះសម្បូរចាយវាយខ្លាំងណាស់ តែសម្រាប់ព្រះមានតិចតួចទេ
ពេលសម្រាប់ខ្លួនសម្បូរណាស់ដែរ តែព្រះគ្មានទេរវល់ខ្លាំងណាស់
គ្មានពេលបំពេញកិច្ចការព្រះគ្រីស្ទ ទៅជួយដល់មនុស្សកំពុងស្រេកឃ្លាន
ជួយព្រលឹងមនុស្សកំពុងវង្វេង ជួយគេឲ្យស្វែងរកអំណារអស់កល្ប។
វិនាសហើយ វិនាសហើយ! មើលគេហៅយើងចុះ
“នាំព្រះអ្នកមក ហើយប្រាប់យើងពីទ្រង់ផង
យើងអស់កម្លាំងមានបន្ទុកច្រើនកន្លង
ទឹកភ្នែកហូរសៅហ្មងនាំឲ្យភ្នែកស្រវាំង”។

ព្រះអង្គមិនសព្វព្រះទ័យឃើញមនុស្សវិនាសបង់
ខ្ញុំជាអ្នកដើរតាមទ្រង់ តើខ្ញុំអាចរស់នៅបានសុខសាន្តយ៉ាងដូចម្ដេចទៅ
ពេលព្រលឹងមនុស្សកំពុងតែធ្លាក់នរកយ៉ាងជ្រៅ
បាត់រសាត់ទៅដោយខ្ញុំមិនបានជួយ។
វិនាសហើយ វិនាសហើយ! យើងមិនស្ម័គ្រចិត្ត
ម្ចាស់ខ្ញុំអើយអាណិត ប្រណីសន្ដោសផង
សូមបំបរបង់ចំណង់លោកីយ៍តែម្ដង
ឲ្យទូលបង្គំរស់ផងតាមទស្សនៈរបស់ព្រះអង្គ។

— លោកស្រី លូស៊ី អរ. ម៉ៃយើរ
(Lucy R. Meyer)

# កំណត់យោង

## ជំពូកទី១

១. មកពី H. A. Evan Hopkins, *Henceforth*, Chicago: IVF, ឆ្នាំ១៩៥៤, ទំព័រ២០។

## ជំពូកទី២

១. មកពី *Men of His Right Hand* ដោយ ទស្សនាវដ្ដី Witness ខែមករា ឆ្នាំ១៩៦១។

២. មកពី A. N. Groves, *Christian Devotedness*, Kansas City: Walterick Publicshers, ឆ្នាំ១៩៧៥។

៣. មកពី Norman Grubb, *C. T. Studd*, London: Lutterworth Press, ឆ្នាំ១៩៥៧, ទំព័រ៦៤។

៤. លោក ស៊ី.ធី. ស្ទឹដ បានទុកប្រាក់ចំនួន £៣៤០០ ដែលស្មើនឹងចំនួនប្រាក់ប្រមាណជា $៤០០,០០០ដុល្លារនាឆ្នាំ២០១៤នេះ។

៥. មកពី Elisabeth Elliot, *Shadow of the Almighty*, New York: Harper & Brothers, ឆ្នាំ១៩៥៨, ទំព័រ២៤៦។

៦. មកពី *Christian Devotedness*, ទំព័រ២៦-២៧។

៧. មកពី G. H. Lang, *Anthony Norris Groves*, London: The Paternoster Press, ឆ្នាំ១៩៤៩, ទំព័រ៥៤។

## ជំពូកទី៥

១. មកពី Norman Grubb, *C. T. Studd*, London: Lutterworth Press, ឆ្នាំ១៩៥៧, ទំព័រ៣៦។

២. មកពី Elisabeth Elliot, *Shadow of the Almighty*, New York: Harper & Brothers, ឆ្នាំ១៩៥៨, ទំព័រ៥៨-៥៩។

៣. មកពី Billy Graham ក្នុង *Mission Commitment*, វគ្គទី១, អធិប្បាយនៅ InterVarsity Christian Fellowship Conference, Urbana IL, ឆ្នាំ១៩៥៧, ប្រធានបទសន្និបាត៖ One Lord, One Church, One World។

៤. មកពី J. C. Ryle, *Practical Religion*, London: James Clarke & Co. Ltd., ឆ្នាំ១៩៥៩, ទំព័រ១៣០។

**ជំពូកទី៦**

១. មកពី C. H. Mackintosh, *Genesis to Deuteronomy*, Neptune, NJ: Loizeaux Brothers, ឆ្នាំ១៩៧២, ទំព័រ៤៩៨។

២. មកពី C. H. Mackintosh, *The Mackintosh Treasury*, Neptune, NJ: Loizeaux Brothers, ឆ្នាំ១៩៧៦។

**ជំពូកទី៩**

១. មកពី C. H. Spurgeon, លើកឡើងនៅក្នុងសៀវភៅ *The Prairie Overcomer*, Three Hills, Alberta: Prairie Bible Institute, ខែមិនា ឆ្នាំ១៩៥៧, ទំព័រ៨១។

២. មកពី http://www.worldometers.info/world-population/ នៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៤។

**ជំពូកទី១០**

១. មកពី Gordon Arnold Lonsdale, ទស្សនាវដ្ដី *TIME*, ១៧ កុម្ភៈ ១៩៦១។

២. មកពី Wesley L. Gustafson, *Called But Not Going*, Chicago: IVCF Press, ទំព័រ១០។

៣. មកពី លោក Cable និងលោក French, *Ambassadors For Christ*, Chicago: Moody Press, មិនដឹងកាលបរិច្ឆេទ។

**ជំពូកទី១២**

១. លោក ចន និង លោកស្រី ប៉ែធី ស្ទែម (John and Betty Stam) ជាបេសកជននៅប្រទេស ចិន ដែលពួកកុម្មុយនីស្ដបានសម្លាប់ នៅឆ្នាំ ១៩៣៤។

២. មកពី Elisabeth Elliot, *Shadow of the Almighty*, New York: Harper & Brothers, ឆ្នាំ១៩៥៨, ទំព័រ២៤០។

បើលោកអ្នកចង់ដឹងព័ត៌មានពីសៀវភៅគ្រីស្ទបរិស័ទជាភាសាខ្មែរផ្សេងៗទៀត

សូមចូលទៅកាន់គេហទំព័រៈ

Looking for more Christian resources in the Khmer language?

Visit: http://www.cambodianchristianresources.com